សូមប្រសិទ្ធពរមហាប្រសើរជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏មហានក្តីត្បូងក្សត្រនៃទិវាគម្រប់ជន្មាយុ ៦៦ ឈានចូល ៦៧ វស្សារបស់សម្តេច

*យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោ** អគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា ដែលបានលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាញាណក្នុងការដឹកនាំមាតុភូមិកម្ពុជា សម្រេចបាន ជោគជ័យ ដ៏ធំធេងជាប្រវត្តិសាស្ត្រជូនជាតិ និងប្រជាជន តាំងពីដំណាក់កាលសង្គ្រោះជាតិ ពីរបបប្រល័យពូជសាសន៍ រហូតមក ដល់ដំណាក់កាលសន្តិភាព បង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍នាបច្ចុប្បន្ននេះ ។*

*សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតានានាថ្មី រុក្ខជាតិសិទ្ធិទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមីនៃវិញ្ញាណក្ខន្ធរបស់បុព្វជនវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមជួយប្រោះព្រំ គាំពារ ថែរក្សា **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី បានប្រកបនូវសុខភាពល្អបរិបូរ កាយពលមាំមួន បញ្ញាញាណ-ភ្លឺថ្លា ដើម្បីបន្តដឹកនាំប្រទេសកម្ពុជាសម្រេចបានជោគជ័យធំៗថ្មីៗទៀត ។*

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ទស្សនាវដ្ដីប្រជាជន

សួស្តីឆ្នាំថ្មី

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
ឆ្នាំរកា ឯកស័ក ពុទ្ធសករាជ ២៥៦១

សូមប្រសិទ្ធពរ បវរសួស្តី សិរីមង្គល មហាប្រសើរ ថ្វាយ និងជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តមលោកឧកញ៉ា លោក-ជំទាវ លោក លោកស្រី មន្ត្រី-រាជការ កងយោធពលខេមរ-ភូមិន្ទ កងនគរបាលជាតិ ជន រួមជាតិនៅគ្រប់ទិសទី ព្រម ទាំងអង្គទូត និង អង្គការអន្តរ-ជាតិនានា ដែលកំពុងបំពេញ បេសកកម្មនៅព្រះរាជាណា-ចក្រ កម្ពុជា សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបី ឃ្លៀងឃ្លាត ឡើយ ។

គោរពជូនពរ

ទស្សនាវដ្តីប្រជាជន

វិចារណកថា EDITORIAL

ការរីកចម្រើនរបស់ឃុំ សង្កាត់ គឺជាកាលានុវត្តភាពដ៏ធំធេងសម្រាប់ ២គណបក្សប្រជាជនកម្ពុជា បន្ត៣ត្រឹមត្រូវនាទីដឹកនាំនៅមូលដ្ឋាន

Communal/Sangkat Progresses – A Tremendous Opportunity for CPP to Continue Local Leadership Role

ឆ្នាំ២០១៧ គឺជាឆ្នាំទី៤ នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធ-សាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ព្រមជាមួយនេះក៏ជាឆ្នាំទី៥របស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ និងជាឆ្នាំត្រូវរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ សម្រាប់ដឹកនាំឃុំសង្កាត់រយៈពេល៥ឆ្នាំបន្តទៀត ។

នៅក្នុងរយៈពេលនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខបានដឹកនាំប្រទេសជាតិឲ្យមានការរីកចម្រើនយ៉ាងខ្លាំង សម្រេចបានសមិទ្ធផលធំៗយ៉ាងច្រើនលើគ្រប់វិស័យនៅទូទាំងប្រទេសប្រកបដោយមោទនភាពបំផុត។ ដំណើរការនៃសង្គមជាតិទាំងមូលកំពុងប្រព្រឹត្តទៅយ៉ាងល្អប្រសើរ, សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមកាន់តែរឹងមាំ ដែលបានធានានូវបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកែលម្អជីវភាពរបស់ប្រជាជន ។ ប្រជាជនគ្រប់ច្រកល្ហកបានរស់នៅយ៉ាងសុខសាន្ត សុខដុមរមនាដោយពុំមានការភ័យបារម្ភពីការគំរាមគំហែងនៃសង្គ្រាម, អស្ថិរភាព ឬ ចលាចលសង្គមផ្សេងៗ ហើយកំពុងប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តដើម្បីចូលរួមក្នុងការកសាងប្រទេសជាតិ ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលបាននិងកំពុងតែបន្តអនុវត្តប្រកបដោយផ្លែផ្កានូវបណ្ដាទិសដៅជាអាទិភាពគឺ : ការបណ្ដុះបណ្ដាលធនធានមនុស្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនតម្លៃក្នុងវិស័យកសិកម្ម ព្រមទាំងការពង្រឹងអភិបាលកិច្ចល្អ និងសមត្ថភាពនៃស្ថាប័ន ។ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយមួយចំនួន ដើម្បីពង្រឹងសកម្មភាពគាំទ្រគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការលើកកម្ពស់ការគាំពារសង្គមចំពោះជនរងគ្រោះ និងងាយរងគ្រោះ ព្រមទាំងការបង្ហិត ការផ្ដល់សេវាសាធារណៈមកកាន់តែកៀកជាមួយនឹងប្រជា-ជន ។ ជាពិសេសការអនុវត្តវិធានការគោលនយោបាយមួយចំនួននៅក្នុងវិស័យនានា ដែលបម្រើផលប្រយោជន៍ផ្ទាល់របស់ប្រជាជនឲ្យបានកាន់តែច្រើនឡើងនោះ បានទទួលការអបអរសាទរពីប្រជាជនគ្រប់ស្រទាប់ ។

នៅក្នុងដំណើរវិវត្តន៍ប្រកបដោយភាពវិជ្ជមាននេះ ក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៣ នៅគ្រប់មូលដ្ឋាន ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជាកាន់តួនាទីដឹកនាំនៅក្នុងឃុំ សង្កាត់ ចំនួន៩៧,៤៩% នៃចំនួនឃុំ សង្កាត់សរុប បានបំពេញតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ក្នុងការបម្រើប្រជាជននៅតាមមូលដ្ឋានរបស់ខ្លួន។ គួរបញ្ជាក់ថា តាមរយៈដំណើរការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ មុខងារ និងធនធានត្រូវបានផ្ទេរជាបន្តបន្ទាប់កាន់តែច្រើនឡើង ពីថ្នាក់ជាតិទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិសំដៅធានាឲ្យមានការអភិវឌ្ឍដ៏ទូលំទូលាយ និងប្រកបដោយនិរន្តរភាព។ ក្នុងនោះ ធនធានហិរញ្ញវត្ថុដែលត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលឃុំ សង្កាត់ បានកើនឡើងជាង ១២ដង គិតពីឆ្នាំ២០០២

The year 2017 is the fourth year of implementation of the political platform and rectangular strategy phase iii of the Royal Government Cambodia of the fifth legislative term of the National Assembly. It is also the fifth year of the implementation of the third-term Communal Councils and the organization of the fourth-term elections of the Communal Councils for the next five-year local leadership.

In this period, the Royal Government of Cambodia led by Samdech Akka Moha Sena Padei Techo Hun Sen has proudly made tremendous achievements in numerous fields in the whole country. the whole nation proceeds well, peace and political stability, security, public order and social safety has grown firm guaranteeing favorable environment for socio-economic development and improvement of people's living condition. People of all walks of life live in peace and harmony, free from fear and concerns of war threat, instability or social upheavals, and are making efforts physically and spiritually to take parts in national construction.

At present, the Royal Government has been continuing to implement fruitfully prioritized objectives such as human resource training, physical infrastructure construction, increase value of agricultural produces and strengthening of good governance and institutional capacity. The Royal Government puts out certain policies that are strengthening activities to support goals of poverty alleviation, to raise high social protection for the victims and vulnerable, and to channel public services close to people. Implementation of certain policies in different sectors serving directly people's interests has grown up and enjoyed our people's welcome.

In this positive development, the third-term communal councils, in which CPP has been holding up to 97.49% of all the communes/Sangkats, fulfilled their tasks and exercised their rights and power with responsibility serving people at local level. It should be an affirmation that through process of sub-national administrative reforms, functions and resources have been transferred more and more gradually manner from national to sub-national level administration aimed at guaranteeing wide scale and sustainable developments. Financial resources transferred to communal/Sangkat administration has increased 12 folds in between 2002 and 2016, or more than 500 million USD over fourteen years.

Simultaneously, based upon decentralization policy, communes/Sangkats have gathered resources from development partners, civil society, charitable persons, and local communities in hundreds million USD. Therefore, the communal/Sangkats councils are able to provide public services and construction of thousands of infrastructural projects per year. That has responded to local needs and reduced people's poverty. It is on this basis that people see clearly indispensable leadership role of the Cambodian People's Party at communal/Sangkat and national levels.

មកដល់ឆ្នាំ២០១៦ គឺមានចំនួនជាង ៥០០លានដុល្លារ ក្នុងរយៈពេល១៤ ឆ្នាំមកនេះ។ ទន្ទឹមនេះ ផ្អែកលើគោលនយោបាយវិមជ្ឈការ ឃុំ សង្កាត់ បានកៀរគរធនធានពីបណ្ដាដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សប្បុរសជន និងសហគមន៍មូលដ្ឋានបានច្រើនរយលានដុល្លារថែមទៀត។ អាស្រ័យហេតុនេះ រដ្ឋបាលឃុំ សង្កាត់កាន់តែមានលទ្ធភាពផ្ដល់សេវាសាធារណៈ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបានរាប់ពាន់គម្រោងក្នុង១ឆ្នាំ១ ដែលបានឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ លើមូលដ្ឋាននេះ ប្រជាជនបានឃើញច្បាស់នូវតួនាទីដឹកនាំ ដែលមិនអាចខ្វះបានរបស់គណបក្សប្រជាជនកម្ពុជា ទាំងនៅថ្នាក់ឃុំ សង្កាត់ ទាំងនៅថ្នាក់ជាតិ។

ឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ គណបក្សចំនួន១២ ដែលបានចូលរួមប្រកួតប្រជែងកំពុងខិតខំផ្សព្វផ្សាយនូវគោលនយោបាយរបស់ខ្លួន ដើម្បីទាក់ទាញការគាំទ្រពីប្រជាជនក្នុងបរិយាកាសនយោបាយប្រកបដោយភាពសុខសាន្ត អព្យាក្រិត សេរី និងប្រជាធិបតេយ្យ។ ប៉ុន្តែនៅទន្ទឹមនឹងដំណើរការដ៏ល្អនេះ គណបក្សប្រឆាំងបានផ្សព្វផ្សាយនូវសារនយោបាយ«ដកមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ» ដែលខ្លឹមសារមានចរិតញុះញង់ បង្ករហេតុ និងប្រមាថមើលងាយយ៉ាងធ្ងន់ធ្ងរដល់មន្ត្រីឃុំ សង្កាត់ នៅទូទាំងប្រទេសដែលបានខិតខំបម្រើប្រជាជន ស្របតាមតួនាទីរបស់ខ្លួនដោយមិនមានការរើសអើងនិន្នាការនយោបាយ។ គណបក្សប្រជាជនកម្ពុជាបានទាមទារឲ្យថ្នាក់ដឹកនាំគណបក្សប្រឆាំងធ្វើការកែតម្រូវជាបន្ទាន់នូវខ្លឹមសារនេះ ដើម្បីរក្សាបរិយាកាសល្អ និងសុខសន្តិភាពរបស់ប្រទេសជាតិ។ ទោះបីយ៉ាងក្ដីនេះ ក៏ខ្លឹមសារដែលពោរពេញដោយទំនាស់នេះ នៅតែត្រូវសកម្មជន និងមន្ត្រីរបស់គណបក្សប្រឆាំងបន្តឃោសនានៅមូលដ្ឋានដដែល ព្រោះថាវាបានផ្សព្វផ្សាយរួចទៅហើយ។ ប៉ុន្តែការឃោសនាមូលបង្ការ ចោកប្រាស់ ប្រជាភិថុតិ មិនអាចបិទបាំងការពិតបានឡើយ ព្រោះថាប្រជាជន គឺជាសាក្សីនៃការរីកចម្រើនរបស់មូលដ្ឋាន ហើយគឺប្រជាជននោះហើយ ដែលជាអ្នកបានបង្កើតនូវក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់។

ទាក់ទងនឹងបញ្ហានេះដែរ នៅក្នុងសេចក្ដីជូនដំណឹងទៅគណបក្សសង្គ្រោះជាតិថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានណែនាំឲ្យគណបក្សនេះដកចេញនូវចំណងជើង«ដកមេឃុំបម្រើបក្សដាក់មេឃុំបម្រើរាស្ត្រ» នេះ ព្រោះជាខ្លឹមសារដែលផ្ទុយពីស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយច្បាប់ស្ដីពីគណបក្សនយោបាយ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ពិសេសរបបប្រជាធិបតេយ្យ សេរីពហុបក្ষ និងគោលការណ៍នៃប្រព័ន្ធបោះឆ្នោតសមាមាត្រ។

សរុបមកការរីកចម្រើនរបស់ឃុំ សង្កាត់នៅទូទាំងប្រទេស បានផ្ដល់កាលានុវត្តភាពដ៏ធំធេងដល់គណបក្សប្រជាជនកម្ពុជា ក្នុងការបន្តពង្រឹងការដឹកនាំរបស់ខ្លួននៅឃុំ សង្កាត់ទៅមុខទៀត។ ទន្ទឹមនេះ ក៏គប្បីឃើញច្បាស់ថា រយៈពេលពីនេះរហូតដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ គឺជាដំណាក់កាល តស៊ូយ៉ាងតានតឹង ស្មុគស្មាញ់លើសមភូមិសាធារណមតិ។ អាស្រ័យហេតុនេះ អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ ក៏ដូចមន្ត្រីគណបក្សគ្រប់រូបគប្បីយកចិត្តទុកដាក់កាន់តែខ្លាំង ក្នុងការធ្វើសកម្មភាពឆ្ពោះទៅមូលដ្ឋានខិតខំបង្ហាញលទ្ធផលជាក់ស្ដែង ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងកែលម្អចំណុចខ្វះខាតដែលនៅសេសសល់ជាពិសេសបេក្ខជនក្រុមប្រឹក្សា ឃុំ សង្កាត់របស់គណបក្សប្រជាជនកម្ពុជាត្រូវចុះជាប់ជាមួយប្រជាជន ខិតខំផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សឲ្យប្រជាជនបានយល់ច្បាស់ និងធ្វើអ្វីៗគ្រប់យ៉ាងឲ្យប្រជាជនមានភាពកក់ក្ដៅ ស្រឡាញ់ និងជឿទុកចិត្តមកលើខ្លួន ដើម្បីដណ្ដើមជ័យជម្នៃ:ក្នុងការបោះឆ្នោតនេះ រក្សានូវតួនាទីដឹកនាំរបស់គណបក្សនៅឃុំ សង្កាត់ និងឈានទៅពង្រីកប្រៀបឈ្នះក្នុងការបោះឆ្នោតសកលនាឆ្នាំ២០១៨ ។

ទស្សនាវដ្ដីប្រជាជន

Moving towards the communal/Sangkat councils for the fourth term on 4 June 2017, twelve political parties have raised awareness of own policies to attract people's supports in a peaceful, neutral, free and democratic political environment. However, while the whole process has been good, the opposition party has put out its political message - "withdrawing communal heads that serve the Party, and replace them with ones that will serve the people." The content bears instigating nature and serious insults on communal/Sangkat officials in the whole country who have been serving people in conformity with their roles irrespective of political tendency.

The Cambodian People's Party demands the leaders of the opposition party to rectify the content to maintain good and peaceful environment of the country. Despite such demand, activists and officials of the opposition party continue to use the conflict-provoking slogan in their propaganda at local level. They have already done so, indeed. However slanderous and demagoguery propaganda cannot hide the truth because our people are witnessing local progresses, and because they are the ones that create every communal/Sangkat councils.

In its 22-March-2017 letter addressing to CNRP, the Ministry of Interior instructed removal of the slogan - "withdrawing communal heads that serve the party, and replace them with ones that will serve the people." It is because the content is contrary to the Constitution, the Law on Political Party, the Law on Elections of the Communal/Sangkat Councils, and the Law on Management of Communal/Sangkat Administration, especially democracy, freedom, multiparty and proportional electoral systems.

In conclusion, progresses made by communal/Sangkat councils in the whole country provide great opportunity for the Cambodian People's Party to continue strengthening its leadership in every commune/Sangkat. While so, it should be obvious that from now to 4 June 2017 that the communal/Sangkat council elections hold, it will be a tough public battle. Therefore, political party organization committees and officials at every level should pay more attention on taking activities to local level, while making efforts to illustrate concrete achievements in the implementation of the Royal Government's political platform, and to rectify remaining shortcomings. Especially, the CPP candidates for the post of communal/Sangkat councils must make efforts to raise people's awareness of the CPP's policies and do everything for their trust, love, and confidence aimed at winning the forthcoming elections, maintaining leadership of the Party at communal/Sangkat level, and advancing to expanding winning advantage in the 2018 general elections./.

THE PRACHEACHUN MAGAZINE

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន ជួបសំណេះសំណាលជាមួយសមាជិក ក្រុមប្រឹក្សាស្រុក/ឃុំ នៃខេត្តត្បូងឃ្មុំ

✲ ជួយសម្រួលរាល់ការលំបាកក្នុងកិច្ចការផ្តល់សេវាសាធារណៈអោយបានត្រឹមត្រូវ និងទាន់ពេលវេលាដល់ប្រជាពលរដ្ឋ

***សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ជួបសំណេះសំណាលជាមួយសមាជិក ក្រុមប្រឹក្សាស្រុក/ឃុំ នៃខេត្តត្បូងឃ្មុំ*

កាលពីថ្ងៃទី ១៨ មីនា ឆ្នាំ២០១៧ **សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជួបសំណេះសំណាល ជាមួយ ថ្នាក់ដឹកនាំមន្ត្រីរាជការស្រុក/ក្រុងចំនួន ០៤ ក្នុង នោះរួមមានស្រុក ត្បូងឃ្មុំ ក្រុងសួង ស្រុកមេមត់ និងស្រុកក្រូចឆ្នារ ខេត្តត្បូងឃ្មុំ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកក្រូចឆ្នារ។

មានប្រសាសន៍នៅក្នុងឱកាសនោះ **សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** បានផ្តាំផ្ញើរដល់សមាជិក ក្រុមប្រឹក្សាស្រុក/ឃុំ ទាំង ០៤ ស្រុក នៃខេត្តត្បូងឃ្មុំ ត្រូវធ្វើការផ្លាស់ប្តូរ ឥរិយាបថក្នុងការប្រើប្រាស់ពាក្យសម្តីទៅកាន់ប្រជាជនឲ្យបានសមរម្យ និងជួយសម្រួលរាល់ការលំបាកក្នុងកិច្ចការផ្តល់សេវាសាធារណៈ អោយបានត្រឹមត្រូវ និងទាន់ពេលវេលា។

ក្នុងនោះ **សម្តេចពញ្ញាចក្រី ហេង សំរិន** បានជំរុញដល់ក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុក/ឃុំ នីមួយៗ អោយចុះជាប់ជាមួយប្រជាជន និងក្តាប់ជាប់នូវរាល់បញ្ហាមូលដ្ឋានអោយបានច្បាស់លាស់។

ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំមន្ត្រីរាជការស្រុក/ក្រុងនោះដែរសម្តេចពញ្ញាចក្រីហេងសំរិនបានជូនពរដល់សមាជិកចូលរួមទាំងអស់ទទួលបានតែសេចក្តីសុខ សុភមង្គល ក្នុងក្រុមគ្រួសារ និងប្រកបការងារជោគជ័យគ្រប់ភារកិច្ច ។



សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព
សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្ដីប្រជាជន
ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ

សម្តេចតេជោ ហ៊ុន សែន : ត្រូវតែហ៊ាននិយាយអំពីប្រទេសដែលបង្ក សោកនាដកម្មលើកុមារ, ត្រូវមានអភិបាលខេត្តជាស្ត្រីមួយយ៉ាងតិច, កម្ពុជាចាំបាច់ ត្រូវធ្វើទំនើបកម្មឧស្សាហកម្ម

***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ នៅក្នុងសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០១៧*

***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋាន សាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី២ កំណាត់ទី២ និង សម្ពោធដាក់ឲ្យ ប្រើប្រាស់ផ្លូវក្រុងខ្សែទី២ កំណាត់ទី១*

ក្នុងខែមីនា ឆ្នាំ២០១៧ នេះ មានព្រឹត្តិការណ៍ធំៗនៅក្នុងប្រទេសជាច្រើនបានកើតឡើង ហើយក៏មានវត្តមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមព្រឹត្តិការណ៍ទាំងមានការសម្ពោធសមិទ្ធផល ការប្រារព្ធសន្និសីទកម្រិតអន្តរជាតិ និងការចូលរួមបិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងនានា។

❋ ព្រឹកថ្ងៃទី១ ខែមីនា **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និសីទអន្តរជាតិថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកស្តីពីការអភិវឌ្ឍកុមារតូច ដែលប្រារព្ធនៅខេត្តសៀមរាប។ សន្និសីទនេះ រៀបចំដោយក្រសួងអប់រំ យុវជននិងកីឡា សហការជាមួយបណ្ដាញការងារតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអភិវឌ្ឍកុមារតូច។

មានប្រសាសន៍ក្នុងឱកាសនោះ សម្តេចតេជោបានអំពាវនាវឲ្យមានការគិតគូចំពោះកុមារ ដែលមិនត្រឹមតែអាហារូបត្ថម្ភប៉ុណ្ណោះទេ តែក៏គិតគូដល់សិទ្ធិរស់រានរបស់កុមារផងដែរ។ សម្តេចតេជោបញ្ជាក់ថា សន្និសីទនាពេលនេះ បានយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍកុមារតូចតាមរយៈការមើលថែទាំកុមារ ការផ្ដល់អាហារូបត្ថម្ភ និងពលកម្មកុមារ។ ជាមួយគ្នានេះ ក៏ត្រូវតែនិយាយដល់បញ្ហាសិទ្ធិរស់រានរបស់កុមារផងដែរ ។ ការគិតគូអំពីកុមារតូច យើងមិនគួរនិយាយតែបញ្ហាអាហារូបត្ថម្ភ និងពលកម្មកុមារ ហើយភ្លេចនិយាយអំពីសិទ្ធិរស់រានមានជីវិតរបស់កុមារនោះទេ ។ បើមានសន្និសីទអន្តរជាតិកាន់តែច្រើន យើងគួរតែដំឡើងសម្លេងឲ្យកាន់តែច្រើនផង ដែរអំពីបណ្ដាប្រទេសដែលដើរឈ្លានពានគេ ដែលគិតតែពីសម្លាប់កុមារនោះ។ សម្តេចតេជោបានលើកជាសំនួរថា អ្នកណាបានធ្វើច្រើនជាងគេនៅលើពិភពលោកនេះដែលបង្កើតឲ្យមានសោកនាដកម្មទៅលើកុមារ? សម្តេចបន្ថែមថា ប្រទេសណាដែលនាំកងទ័ពទៅឈ្លានពានប្រទេសគេច្រើនជាងគេនោះ គឺជាប្រទេសដែលធ្វើបាបកុមារច្រើនជាងគេ ។ មិនត្រឹមទៅធ្វើបាបកុមារនៅក្នុងប្រទេសគេប៉ុណ្ណោះទេ ធ្វើបាបទាំងកុមារនៅក្នុងប្រទេសខ្លួនផងដែរ ព្រោះបានបញ្ជូនឪពុករបស់គេឲ្យទៅស្លាប់នៅប្រទេសដទៃ និងធ្វើឲ្យមានស្ត្រីមេម៉ាយ, ក្មេងកំព្រា ជាច្រើន ។ សម្តេចតេជោបន្ថែមថា យើងនិយាយតែពលកម្មកុមារ អាហារូបត្ថម្ភកុមារ និងការថែទាំកុមារ ប៉ុន្តែយើងមិនសូវបាននិយាយអំពីសិទ្ធិរស់រានមានជីវិតរបស់កុមារនោះទេ ។ តើមួយថ្ងៃ១ស្លាប់កុមារអស់ប៉ុន្មាននាក់ នៅប្រទេសអ៊ីរ៉ាក់ នៅលីប៊ី នៅស៊ីរី? តើអ្នកណាជាអ្នកធ្វើរឿងនេះ? ត្រូវហ៊ាននិយាយត្រង់ៗកុំខ្លាចពួកចក្រពត្តិនិយមដែលដើរតែឈ្លានពានគេ ។ សម្តេចតេជោបានបន្ថែមថា ខ្លួនសម្តេចផ្ទាល់ជាកុមាររងគ្រោះម្នាក់នៅក្នុងអតីតកាល ដែលបារាំងត្រួតត្រានៅកម្ពុជា។ តាមឪពុកម្តាយប្រាប់ សម្តេចកាលពីតូចត្រូវបានឪពុកម្តាយទាញទម្លាក់ទៅក្នុងលេណដ្ឋានរៀងរាល់ពេល កងទ័ពបារាំងវ៉ៃគ្នាជាមួយកងទ័ពតស៊ូ ។ បន្ទាប់ទៅនៅពេលអាមេរិកឈ្លានពានកម្ពុជា តើមានកុមារប៉ុន្មានទៅដែលបានស្លាប់? របួសពិការ? នៅឥណ្ឌូចិនទាំងកម្ពុជា ទាំងឡាវ និង វៀតណាម គឺមានច្រើនណាស់រហូតមកដល់ពេលនេះមិនទាន់អស់ផង ។ សម្តេចតេជោបានបន្ថែមថា គ្រាន់តែជាតិគីមីក៏បានធ្វើឲ្យកុមារកម្ពុជារងគ្រោះពិការយ៉ាងច្រើន? តើយើងបាននិយាយពីវាទេ? យើងគួរមានសម្លេងរួមមួយ ដើម្បីប្ដឹងទោសពួកឈ្លានពាន ។ ពួកដែលដើរសម្លាប់គេ ។ សព្វថ្ងៃនាំគ្នាដើរឆែកតាមរោងចក្ររកកុមារមិនគ្រប់អាយុ ប៉ុន្តែយើងមានដែលបានដើរទៅឆែកនៅប្រទេសស៊ីរី ប្រទេសលីប៊ី និងប្រទេសអ៊ីរ៉ាក់ទេ ដែលពួកឈ្លានពានចូលទៅឈ្លានពានផ្ដួលរំលំគេ ឬគាំទ្រមជិវត្តន៍ពណ៌នៅទីនោះ។

❋ ព្រឹកថ្ងៃទី២ ខែមីនា **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងសន្និសីទចក្ខុ វិស័យកម្ពុជាឆ្នាំ២០១៧ ដែលរៀបចំឡើងដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងធនាគារអេអ៊ិនហ្ស៊ីតរ៉ូយ៉ាល់ ក្រោមប្រធានបទ "ការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃសម្រាប់ឧស្សាហូបនីយកម្មកំណើន និងការអភិវឌ្ឍក្នុងសម័យឌីជីតាល់"។ សម្តេចតេជោបញ្ជាក់ថា ទោះបីសេដ្ឋកិច្ចកម្ពុជាមានកំណើនថេរក្តី ប៉ុន្តែហានិភ័យ និងបញ្ហាប្រឈមដែលអាចកើតមានឡើងចំពោះមុខដូចជា ភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្ដាលសហរដ្ឋអាមេរិក, ការចាកចេញរបស់អង់គ្លេស និងអនាគតរបស់សហភាពអ៊ីរ៉ុប, ហានិភ័យនៃការធ្លាក់ចុះកំណើនសេដ្ឋកិច្ចចិន និងការថមថយកំណើនរបស់បណ្ដាសេដ្ឋកិច្ចនៃប្រទេសកំពុងរីកលូតលាស់, ភាពចម្រូងចម្រាសក្នុងការធ្វើពាណិជ្ជកម្មរវាងប្រទេសចិន និងរដ្ឋការរបស់ប្រធានាធិបតីអាមេរិកថ្មី ក៏ដូចជាការកើនឡើងនូវកម្ដៅភូមិសាស្ត្រនយោបាយជាដើម ។ល។ លើសពីនេះ ការរំពឹងទុកនូវការងើបឡើងវិញនូវតម្លៃប្រេង និងទំនិញលើទីផ្សារអន្តរជាតិក៏ជាហានិភ័យសម្រាប់សេដ្ឋកិច្ចកម្ពុជាផងដែរ ។ សម្តេចតេជោបានបន្ថែមថា ហេតុផលខាងលើជំរុញឲ្យកម្ពុជា ត្រូវធ្វើការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងពិពិធកម្មក្នុងគោលដៅស្វែងរកតម្លៃបន្ថែមខ្ពស់ដល់សេដ្ឋកិច្ចដើម្បីបន្ត

ស្ថិរភាពកំណើនក្នុងរយៈពេលមធ្យមនិងវែង ។ ដើម្បីសម្រេចគោលដៅនេះយើងត្រូវរួមគ្នាខិតខំ អនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ ដែលរាជរដ្ឋាភិបាលបានដាក់ចេញនិងត្រូវចាត់ទុកថាជា **"យុទ្ធសាស្ត្រកំណើនថ្មី"** ដែលជាមគ្គុទ្ទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា, ការធ្វើពិពិធកម្មសេដ្ឋកិច្ច,ការពង្រឹងសមត្ថភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពដើម្បីឈានឡើងទៅកាន់ទួលថ្មីមួយទៀត ក្នុងខ្សែចង្វាក់នៃតម្លៃបន្ថែមក្នុងតំបន់ និងសកលលោក ។

❋ ព្រឹកថ្ងៃចន្ទ ទី៦ ខែមីនា សម្តេចតេជោបានអញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី២ កំណាត់ទី២ និងសម្ពោធដាក់ឲ្យប្រើប្រាស់ផ្លូវក្រុងខ្សែទី២ កំណាត់ទី១ (មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ) ពីទ័ន្ទប៉ាកប់ស្រូវ-មហាវិថីសហព័ន្ធរុស្សី។ នៅពេលនោះ សម្តេចតេជោ បានថ្លែងអំពីផែនការមួយចំនួនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធស្ពានថ្នល់នៅកម្ពុជា។

សម្តេចតេជោមានប្រសាសន៍ថា "យើងត្រូវការសាងសង់ស្ពានចំនួន ២ ទៀត។ស្ពានមួយឆ្លងទន្លេមេគង្គលើពីជ្រោយចង្វា ទៅស្វាយជ្រុំ និងស្ពានមួយទៀតឆ្លងទន្លេមេគង្គក្រោមពីអរិយក្សត្រមកក្តីតាកុយ"។សម្តេចតេជោ បានស្នើទៅមិត្តចិន ឲ្យបន្តជួយដល់គម្រោងសាងសង់ស្ពានទាំងពីរនេះ ដើម្បីឲ្យស្របទៅយុទ្ធសាស្ត្រផ្លូវសូត្ររបស់ប្រទេសចិន ។ សម្តេចបានបន្ថែមថា នៅក្នុងខែឧសភា ខាងមុខសម្តេចនឹងទៅចូលរួមក្នុងសន្និសីទទាក់ទងនឹងយុទ្ធសាស្ត្រផ្លូវមួយ ខ្សែក្រវ៉ាត់មួយ នៅទីក្រុងប៉েকាំង ប្រទេសចិន ដូចនេះសង្ឃឹមថា សំណើនេះនឹងត្រូវបានដាក់ជូនទៅមិត្តចិន ។ ពាក់ព័ន្ធការសម្ពោធផ្លូវក្រវ៉ាត់ក្រុងសម្តេចមានប្រសាសន៍ថា ផ្លូវខ្សែក្រវ៉ាត់ក្រុងនេះនឹងសម្រួលព្រមទាំងកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងអាចឲ្យប្រជាពលរដ្ឋជំរុញការដឹកជញ្ជូនទំនិញពីផ្លូវជាតិលេខ ៥ ទៅផ្លូវជាតិលេខ២ និងទៅផ្លូវជាតិលេខ ១ បានឆាប់រហ័ស និង កាន់តែងាយស្រួលបន្ថែមទៀត ។ ជាផ្លូវយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបកំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញដែលកំពុងកើនដល់ជិត៣ លាននាក់និងកំណើនយានយន្តជាង២លានគ្រឿង។

❋ ថ្ងៃទី ៨ ខែមីនា សម្តេចតេជោ បានអញ្ជើញជាអធិបតីក្នុងទិវានារី ៨ មីនា ឆ្នាំ២០១៧ ដែលប្រារព្ធនៅសាលមហោស្រពកោះពេជ្រដោយមានការចូលរួមពីកម្មករ កម្មការិនី មន្ត្រីស្ថាប័ន និងនិស្សិតប្រមាណ ៣ ០០០ នាក់ ។

មានប្រសាសន៍ក្នុងឱកាសនោះសម្តេចតេជោបានបញ្ជាក់ថា រាជរដ្ឋាភិបាលបានកំណត់រួចមកហើយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានអភិបាលរងខេត្ត អភិបាលរងស្រុកជាស្ត្រី ។ យើងចង់ឲ្យមានស្ត្រីជាអភិបាលខេត្តណាមួយនៅក្នុងចំណោមរាជធានី ខេត្តទាំង ២៥ នៅទូទាំងប្រទេស និងជាអភិបាលស្រុកផងដែរ ។ សម្តេចតេជោបន្តថា មិនមានការលំបាកនោះទេ ក្នុងការតែងតាំងស្ត្រីជាអភិបាលខេត្ត ព្រោះថាមិនមែនជាការបោះឆ្នោតនោះឡើយ។ នេះជាការចាត់តាំង ។ ដូចនេះនៅពេលខាងមុខប្រសិនជាមានអភិបាលខេត្តជាបុរសណាមួយត្រូវចូលនិវត្តន៍ យើងអាចដាក់ស្ត្រីជំនួសបាន។ សម្តេចតេជោបញ្ជាក់ថា ត្រូវមានអភិបាលខេត្តជាស្ត្រីមួយយ៉ាងតិច។ ដូចនេះបើមានច្រើនជាងមួយគឺកាន់តែល្អហើយនៅតាមស្រុកក៏ដូចគ្នាចាំបាច់ត្រូវតែមាន ។

❋ ព្រឹកថ្ងៃទី២០ ខែមីនា **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំតុមូលចិនលើកទី៥ ស្តីពីការចូលរួមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO) ក្រោមប្រធានបទ "ការអនុវត្តល្អបំផុតស្តីពីការចូលរួមជាសមាជិករបស់ប្រទេសអភិវឌ្ឍន៍តិចតួច" ។ កិច្ចប្រជុំនេះបានប្រព្រឹត្តិទៅនៅសណ្ឋាគារសុខាខេត្តសៀមរាប ដោយមានការចូលរួមពីប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋប្រជាមានិតចិន,ប្រទេសអភិវឌ្ឍន៍តិចតួច(LDCs) និងតំណាងអង្គការពាណិជ្ជកម្មពិភពលោក ។

មានប្រសាសន៍ក្នុងឱកាសនោះ សម្តេចតេជោបានស្នើសុំទៅលោកនាយករងអង្គការពាណិជ្ជកម្មពិភពលោក និងបណ្តាប្រទេសជាសមាជិកចាស់នៃអង្គការពាណិជ្ជកម្មពិភពលោក គប្បីមានការយោគយល់ និងអធ្យាយស្រ័យចំពោះប្រទេសជាសមាជិកអភិវឌ្ឍន៍តិចតួច ដែលកំពុងសុំចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ សម្តេចតេជោបានបន្តថា ប្រទេសអភិវឌ្ឍន៍តិចតួច ដែលបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក សុទ្ធតែគោរពចំពោះវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកបានយ៉ាងល្អជាងប្រទេសអភិវឌ្ឍន៍ និងប្រទេសអ្នកមានទៅទៀត។ ដូចជាការឧបត្ថម្ភទុនសម្រាប់វិស័យកសិកម្ម តើមានប្រទេសអ្នកមានណាបានគោរពនោះ?។ ប្រទេសអ្នកមានតែងដាក់ប៉ារ៉ាស់ចំពោះប្រទេសអភិវឌ្ឍន៍តិចតួច តាមរយៈភូតគាមអនាម័យ ឬចត្តាឡីស័ក្ត ធ្វើឲ្យប្រទេសអភិវឌ្ឍន៍តិចតួចមិនអាចនាំចូលទៅបាន ។

❋ ព្រឹកថ្ងៃទី២២ ខែមីនា សម្តេចតេជោ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីចែកសញ្ញាបត្រដល់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ។ នៅពេលនោះសម្តេចតេជោបានថ្លែងអំពីការផ្ទេរអាជ្ញាធរ និងគណៈកម្មាធិការមួយចំនួនដែលមុននេះស្ថិតនៅក្រោមគណៈរដ្ឋមន្ត្រីឲ្យទៅស្ថិតនៅក្រោមក្រសួងជំនាញវិញ។

សម្តេចតេជោបានបញ្ជាក់ថា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋដែលមានសម្តេចជាប្រធាន ត្រូវបានរំសាយចោលទាំងអស់កាលពីរដ្ឋាភិបាលអាណត្តិថ្មីនេះចាប់ផ្តើម ក្នុងនោះកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានប្រគល់ទៅឲ្យក្រសួងមុខងារសាធារណៈនិងបានដំឡើងទៅជាក្រសួង, ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធ៌មត្រូវបានប្រគល់ទៅឲ្យក្រសួងយុត្តិធ៌ម ។ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធក៏បានប្រគល់ទៅផ្នែកពាក់ព័ន្ធអស់ដែរ ។ សម្តេចតេជោបានបន្តថា ការងារទាំងអស់មិនបានប្រគល់ទៅឲ្យឯកឧត្តម **ប៊ិន ឈិន** ទទួលទាំងអស់នោះទេ ។ បើតាមការបញ្ជាក់របស់សម្តេចតេជោ គឺការងារទាក់ទង នឹងកិច្ចការកាត់ទោសខ្មែរក្រហម ក្រុមការងារនៅដដែលដោយបន្ថែមមនុស្សខ្លះ និងប្រគល់ឲ្យឯកឧត្តម **ប៊ិន ឈិន** ទទួលការងារនេះព្រោះមានទំនាក់ទំនងជាមួយអន្តរជាតិផង និង ទំនាក់ទំនងរវាងកម្ពុជានិងអង្គការសហប្រជាជាតិផងដែរ ។ រាជបណ្ឌិត្យសភាកម្ពុជា និងអាជ្ញាធរ អាកាសចរស៊ីវិល ក៏ត្រូវរក្សាទុកនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីដដែល។ អាជ្ញាធរជាតិអប្សរាដោយសារតែស្ថិតនៅក្នុង ចង្កោមជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្ប: ដូចនេះប្រធានអាជ្ញាធរជាតិអប្សរាគឺលោកស្រី **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប:ធ្វើជាប្រធាន ។ ដោយឡែកអាជ្ញាធរព្រះវិហារមានប្រធានស្រាប់, គណៈកម្មាធិការជាតិយូណេស្កូកម្ពុជា និងគណៈកម្មាធិការបេតិកភណ្ឌជាតិពិភពលោក ក៏ត្រូវដាក់ឲ្យនៅក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្ប:ជាអ្នកគ្រប់គ្រងផងដែរ ។ ចំពោះគណៈកម្មាធិការគ្រប់គ្រងផ្លូវដែក ត្រូវប្រគល់ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនឯកឧត្តម **ស៊ុន ចាន់ថុល** ជាអ្នកគ្រប់គ្រង ។ រីឯស្ថាប័នគណៈវិស្វកម្មត្រូវប្រគល់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ: ជាអ្នកគ្រប់គ្រងព្រោះជាសំណុំបញ្ហាមិនមែនផ្តោតតែលើវិស័យសាងសង់នោះទេ ។ ចំណែកកាយឫទ្ធិជាតិកម្ពុជាត្រូវប្រគល់ទៅឲ្យឯកឧត្តម **ហង់ ជួន** ណារ៉ុនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា ធ្វើជាប្រធាន និងគ្រប់គ្រងបន្ត ។

❋ ព្រឹកថ្ងៃទី២៧ ខែមីនា ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារសិក្សាចំនួន ៣ខ្នង នៅវិទ្យាល័យ**សម្តេចតេជោ ហ៊ុន សែន** ក្រុងក្រចេះ **សម្តេចតេជោ ហ៊ុន សែន** បានអំពាវនាវឲ្យអាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ និងប្រជាជនចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមឲ្យបានល្អ ដើម្បីបម្រើឲ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រព្រឹត្តទៅក្នុងបរិយាកាសសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សារ ។

សម្ដេចក្រឡាហោម: ប្រទេសចិនជាដៃគូដ៏ពិសេស ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា

❋ ពាក្យស្លោករបស់គណបក្សប្រឆាំងបង្ហាញមានការបែកបាក់ ការបែងចែក និងញុះញង់

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអញ្ជើញជា អធិបតីភាពក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវលេខ៥១

កាលពីព្រឹកថ្ងៃទី១៤ ខែមីនា **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សុង ប៉ា** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា បានអញ្ជើញជា អធិបតីភាពក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវលេខ៥១ ប្រវែង៣៧, ៩៦០គីឡូម៉ែត្រ ចាប់ពីឧត្តុង្គដល់ដំណាក់អំពិលតភ្ជាប់ពីផ្លូវលេខ៤ និងលេខ៥ជាផ្លូវហាយវ៉ៃទី២ ក្រោមហិរញ្ញប្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ។

សម្ដេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា បច្ចុប្បន្ន ចិន គឺជាដៃគូដ៏ពិសេសដែលបានផ្ដល់ជំនួយឥតសំណង និងផ្ដល់ឥណទានកម្ចីជាច្រើន ដោយពុំមានលក្ខខណ្ឌ និងឆាប់រហ័សទាន់ពេលវេលាសម្រាប់ស្ពាន និងអភិវឌ្ឍន៍ប្រទេសកម្ពុជាលើគ្រប់វិស័យ ជាពិសេសលើវិស័យសំខាន់៤ គឺទឹក ភ្លើង ផ្លូវ និងធនធានមនុស្ស។ ចិនបានយកធនធានមនុស្សលើគ្រប់វិស័យជាច្រើនទៅបណ្ដុះបណ្ដាល និងដកបទពិសោធន៍នៅសាធារណរដ្ឋប្រជាមានិតចិនជារៀងរាល់ឆ្នាំ។ សម្ដេចក្រឡាហោមបានបញ្ជាក់ថា សាធារណ-រដ្ឋប្រជាមានិតចិនក៏បានផ្ដល់ជំនួយឥតសំណងចំនួន ១០០០លានយេន ស្មើនឹង ១៥៧លាន ដុល្លារអាមេរិក ដើម្បីយកទៅសាងសង់ពហុកីឡដ្ឋានសម្រាប់ការប្រកួតស៊ីហ្គេមនៅឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។ សម្ដេចក្រឡាហោម បានមានប្រសាសន៍ទៀតថា លើវិស័យសាធារណការ និង ដឹកជញ្ជូនក្នុងរយៈពេលជាង ១០ឆ្នាំនេះ ចិនបានផ្ដល់ហិរញ្ញប្បទានជាជំនួយឥតសំណង និងកម្ចីសម្បទានសម្រាប់ការស្ពាន និងអភិវឌ្ឍន៍ផ្លូវ ស្ពាន និងកំពង់ផែ សរុបទឹកប្រាក់ប្រមាណជាង ២ពាន់លានដុល្លារ។ បើគិតលើប្រវែងផ្លូវដែលសាងសង់មានចំនួន២៩ ខ្សែ ប្រវែង ២ ៩០៤ គីឡូម៉ែត្រ អស់ថវិកាប្រមាណ ១ ៧៤៧ លានដុល្លារ និងស្ពានវែងៗ ដែលបានសាងសង់រួច និងត្រៀមសាងសង់ចំនួន ៨កន្លែង មានប្រវែងសរុប ៧ ៩៥៥ ម៉ែត្រ អស់ទឹកប្រាក់ប្រមាណ ២៧៣ លានដុល្លារ។

ក្នុងឱកាសនោះដែរ **សម្ដេចក្រឡាហោម ស ខេង** បានថ្លែងថា ក្រសួងមហាផ្ទៃ កំពុងតែពិនិត្យមើលរបាយការណ៍ធ្វើសមាជរបស់គណបក្សសង្គ្រោះជាតិ ដែលបានដាក់មកក្រសួង ដើម្បីផ្ដល់ភាពស្របច្បាប់ ឬសុពលភាពឲ្យសមាជរបស់គណបក្សនេះ។ ក្រសួងនឹងឆ្លើយតបជាលាយលក្ខអក្សរទៅគណបក្សសង្គ្រោះជាតិវិញនៅពេលដែលពិនិត្យរួច ។

ពាក់ព័ន្ធករណីនេះដែរ **សម្ដេចក្រឡាហោម ស ខេង** បានមានប្រសាសន៍ថា គណបក្សសង្គ្រោះជាតិបានលើកឡើងនូវពាក្យស្លោក "ជូរមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ" ដែលបញ្ហានេះ សម្ដេចអត់ទាន់សម្រេចថាយ៉ាងម៉េចទេ ព្រោះសមត្ថកិច្ចក្រសួងមហាផ្ទៃនឹងឆ្លើយទៅគណបក្សសង្គ្រោះជាតិវិញ បើគាត់ដាក់មកក្រសួងមហាផ្ទៃ។ ប៉ុន្តែក្នុងនាមជាបុគ្គលផ្ទាល់ខ្លួនសម្ដេចយល់ឃើញថា យើងគួរតែចេះថ្លឹងថ្លែងដែរ ខ្មែរយើងបែកបាក់គ្នាហើយ កុំនាំគ្នាបែងចែកនាំគ្នាញុះញង់ វាមិនសូវស្រួលប៉ុន្មានទេ។ ដូច្នេះគួរតែចេះជ្រើសរើសពាក្យណាដែលសមរម្យ ក៏ប៉ុន្តែកុំឲ្យហួសទៅដល់ការបែកបាក់ផ្ទៃក្នុងជាតិ។ កម្ពុជាប្រកាន់យករបបប្រជាធិប-តេយ្យសេរីពហុបក្សមានន័យថាមានគណបក្សនយោបាយច្រើន។ ប៉ុន្តែច្បាប់បោះឆ្នោតគេកំណត់ពីប្រព័ន្ធបោះឆ្នោតគឺប្រព័ន្ធបោះឆ្នោតមិនមែនឯកត្តនាមទេ តែគឺជាប្រព័ន្ធសមាមាត្រ បានន័យថា

តទៅទំព័រទី ១០

សម្តេចភក្ដី សាយ ឈុំ ជួបសំណេះសំណាលជាមួយ គណៈប្រតិភូស្ត្រី ក្នុងទិវានារីអន្តរជាតិ ៨ មីនា

សម្តេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល គណៈប្រតិភូនារីក្នុងទិវានារីអន្តរជាតិ៨មីនា

ក្នុងឱកាសអបអរសាទរខួបលើកទី១០៦ នៃទិវានារីអន្តរជាតិ ៨ មីនា នាព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០១៧ **សម្តេចវិបុលសេនាភក្ដីសាយ ឈុំ**ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឲ្យគណៈប្រតិភូនារីចំនួន ១៦៥ នាក់ ដឹកនាំដោយលោកជំទាវ **អ៊ុំ ១ កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចូលជួបសម្តែងការគួរសមនៅវិមានព្រឹទ្ធសភា។ ទិវានារីអន្តរជាតិ៨មីនានេះ ប្រារព្ធធ្វើឡើងក្រោមប្រធានបទ **«ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព»**។

សម្តេចវិបុលសេនាភក្ដី សាយ ឈុំ ប្រមុខរដ្ឋស្តីទីបានមានប្រសាសន៍ថា សង្គ្រាមនៅប្រទេសកម្ពុជាពីអតីតកាលបានបន្សល់ទុកនូវភាពក្រីក្រ និងសោកនាដកម្មជាច្រើនរាប់មិនអស់រហូតមកដល់សព្វថ្ងៃនេះ មកលើប្រជាជនកម្ពុជា ជាពិសេសស្ត្រីក៏ដូចជាកុមារដូចជា: ការរៀនសូត្រមិនបានខ្ពស់ ការផ្ដល់សេវាសុខភាពមិនបានគ្រប់គ្រាន់ធ្វើឱ្យអត្រាមរណភាពនៅមានកម្រិតខ្ពស់ ជាពិសេសអត្រាមរណភាពមាតា និងកុមារ។ ទន្ទឹមនេះ កាលានុវត្តភាពសេដ្ឋកិច្ចនៅមានកម្រិត មិនអាចផ្ដល់ការងារ និងមុខរបរជូនប្រជាពលរដ្ឋគ្រប់រូបវប្បធម៌អំពើហិង្សានៅតែបន្ត ប៉ះពាល់ដល់ស្ត្រី និងកុមារ ដែលរារាំងស្ត្រីក្នុងការចូលរួមក្នុងកិច្ច អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេល ៣៨ ឆ្នាំកន្លងមកនេះ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានពុះពារដឹកនាំប្រទេសដោយជំនះរាល់ឧបសគ្គ និងការលំបាករាប់ម៉ឺនជំពូក និងសម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រ ដែលបាននាំប្រជាជាតិឱ្យចេញផុតពីស្រមោលខ្មៅងងឹត និងឈឺចាប់ ។ បច្ចុប្បន្ននេះការភ័យខ្លាច សោកនាដកម្ម ការបែកបាក់ជាតិ និងការបាត់បង់យ៉ាងធំធេងពីអតីតកាលត្រូវបានបញ្ចប់ ។ តាមរយៈការដាក់ចេញនយោបាយឈ្នះ ឈ្នះ នៅឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបាននាំមកនូវការបង្រួបបង្រួមជាតិដែលធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ សន្តិសុខ សណ្ដាប់ធ្នាប់ល្អ និងសុវត្ថិភាពសង្គម។ បច្ចុប្បន្នកម្ពុជា កំពុងបោះជំហានទៅមុខយ៉ាងស្វាហាប់លើមាគ៌ាសន្តិភាព ប្រជាធិបតេយ្យ សហប្រតិបត្តិការ និងការអភិវឌ្ឍន៍។ កិត្យានុភាព និងកិត្តិយសជាតិ ត្រូវបានលើកកម្ពស់ឡើងវិញ ដោយស្មើភាព និងស្មើសិទ្ធិក្នុងកិច្ចការអន្តរជាតិជាមួយប្រទេសនានាលើសកលលោក ។ **សម្តេចភក្ដី សាយ ឈុំ** បានថ្លែងទៀតថា៖ ព្រឹទ្ធសភាគាំទ្រ និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ជាពិសេសក្រសួងកិច្ចការនារីក្នុងការអនុវត្តគោលនយោបាយជាតិ និងបន្ថយកចិត្តទុកដាក់ពិនិត្យ និងផ្ដល់យោបល់លើអត្ថបទច្បាប់នានាដែលពាក់ព័ន្ធផ្ទាល់នឹងបញ្ហាស្ត្រី ដើម្បីជាឧបករណ៍គតិយុត្តិសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ និងកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ស្ត្រី ក៏ដូចជាអនុសញ្ញា និងពិធីសារអន្តរជាតិពាក់ព័ន្ធ នឹងបញ្ហាស្ត្រីមួយចំនួនទៀត ឱ្យមានប្រសិទ្ធភាព។ សម្តេចប្រមុខរដ្ឋស្តីទី បានថ្លែងបញ្ជាក់ថា ព្រឹទ្ធសភាបានចូលរួមយ៉ាងសកម្ម ក្នុងការលើកកម្ពស់ឋានៈ សិទ្ធិ និងតួនាទីរបស់ស្ត្រីតាមរយៈការបញ្ជ្រាបសមភាព

យេនឌ័រនៅក្នុងមុខងារស្នូលទាំងបីរបស់ខ្លួនគឺមុខងារនីតិកម្ម មុខងារតាមដាន ការអនុវត្តច្បាប់ និងមុខងារតំណាង។ ព្រឹទ្ធសភាបានបង្កើតក្រុមសមាជិកា តាមរយៈក្រុមសមាជិកានេះ បានចុះរកព័ត៌មានតាមមូលដ្ឋាន ក្រសួង ស្ថាប័ន ដើម្បីប្រមូលបញ្ហាប្រឈមនានា អំពីស្ថានភាព ជីវភាព សិទ្ធិ ហ៊ានៈរបស់ស្ត្រី ហើយបានធ្វើសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយដៃគូពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានការលើកកម្ពស់វប្បធម៌ អហិង្សា លើកកម្ពស់តួនាទីស្ត្រី ចូលរួមអភិវឌ្ឍសង្គមលើគ្រប់វិស័យទាំងនៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

លោកជំទាវ **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ដែលបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ស្ត្រី កម្ពុជាក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិ ។ លោកជំទាវបានថ្លែងទៀតថា ប្រធានបទស្ដីពី «**ស្ត្រីដើម្បីសន្ដិភាព និងវឌ្ឍនភាព**» នាពេលនេះ បង្ហាញឲ្យឃើញនូវការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលដែលបាននិងកំពុងគាំទ្រជំរុញ ឱ្យមានការចូលរួមពីគ្រប់ស្ថាប័នទាំងបុរស ទាំងស្ត្រី ដើម្បីវឌ្ឍនភាពសង្គម ឆ្ពោះទៅលើកកម្ពស់សិទ្ធិ ស្ថានភាព ជីវភាព ហ៊ានៈតួនាទីរបស់ស្ត្រី ក៏ដូចជាសុខុមាលភាពសង្គម។ លោកជំទាវ បានថ្លែងថា ទោះបីជាមានការគាំទ្រយ៉ាងណាក្ដី ក៏តម្រូវឲ្យមានការចូលរួមពីប្រជា-ជនគ្រប់មជ្ឈដ្ឋានរួមគ្នា កាត់បន្ថយការលំបាកក្នុងសង្គម រួមគ្នាដោះស្រាយជម្លោះដោយសន្ដិភាព និងលើកកម្ពស់លទ្ធិ-ប្រជាធិបតេយ្យស្របតាមសេចក្ដីត្រូវការរបស់សន្ដិភាពពិភពលោក។ លោកជំទាវបានបន្ថែមថា ក្រោយពីប្រទេសជាតិមានសុខសន្ដិភាព កំណើនសេដ្ឋកិច្ចខ្ពស់ធ្វើឲ្យប្រជាជនមានជីវភាពល្អប្រសើរ ក្នុងនោះស្ត្រីក៏ទទួលបានផលពីការអភិវឌ្ឍលើគ្រប់វិស័យផងដែរ។ លោកជំទាវបញ្ជាក់ថា «កំលាំងពលកម្មរបស់ស្ត្រីក្នុងវិស័យកសិកម្មមានចំនួន ៤៥.៣% វិស័យឧស្សាហកម្ម ៣៧.៤% វិស័យសេវាកម្មមាន ៣៥.៤ %។ ការចូលរួមរបស់ស្ត្រី ក្នុងវិស័យសេដ្ឋកិច្ចមានសារៈសំខាន់ណាស់ ដោយស្ត្រីបានចូលរួមកាត់បន្ថយភាពក្រីក្រនិងភាពងាយរងគ្រោះក្នុងគ្រួសារ និងសង្គម»។

តមកពីទំព័រទី ៨

ចោះឆ្នោតលើបញ្ជី គណបក្ស។ ដូច្នេះ បេក្ខជនទាំងឡាយ ត្រូវស្ថិតនៅក្នុងបញ្ជីនៃបក្សណាមួយ ពីព្រោះអត់មានបេក្ខជនស្វ័យរិនទេ។ បេក្ខជនឯករាជ្យអត់ មានបក្ស គឺអត់មានទេតាមច្បាប់សព្វថ្ងៃនេះ។ បើចង់ឈរ ឈ្មោះចោះឆ្នោត ត្រូវតែស្ថិតនៅក្នុងបញ្ជីរបស់បក្សណាមួយ ហើយបើមាននៅក្នុងបញ្ជីរបស់បក្សណាមួយ ហើយនោះមនុស្សនោះនឹងត្រូវជាមនុស្សរបស់បក្សហ្នឹង ហើយបើមិនមែនជាមនុស្សរបស់បក្សហ្នឹងម៉េចគេឲ្យឈរ។

សម្ដេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថា "ការដែលគណបក្សសង្គ្រោះជាតិលើកឡើង មិនស្របជាមួយប្រព័ន្ធចោះឆ្នោតទេ។ ប្រព័ន្ធចោះឆ្នោតត្រូវចោះឆ្នោតសមាមាត្រមនុស្សរបស់គណបក្សទើបឈរបាន បើយើងមិនចងឲ្យមនុស្សបម្រើបក្សគេ វានឹងប៉ះពាល់ទៅដល់ប្រព័ន្ធចោះឆ្នោត។ បើតាមច្បាប់គឺរារាំងទៅដល់សិទ្ធិរបស់គេទៀត មិនឲ្យគេជឿទៅលើគណបក្សណាមួយ។ មេឃុំរបស់គណបក្សណា គឺបម្រើគណបក្សហ្នឹងហើយ។ ប៉ុន្តែទន្ទឹមនេះគេមានកម្មវិធីនយោបាយរបស់គេ ដើម្បីបម្រើប្រជា-ពលរដ្ឋទូទៅ។ ម៉េចក៏ចោទថា មេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ? នេះគឺជាបញ្ហាមួយ ដែលនិយាយពីទិដ្ឋភាពនយោបាយវាម៉ាង និយាយពីទិដ្ឋភាពច្បាប់វាម៉ាង វាទាល់តែសិក្សាទិដ្ឋភាពច្បាប់ឲ្យបានគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែបញ្ហាគណបក្សសង្គ្រោះជាតិគាត់ថា "ដកមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ" ដល់ខ្លួនឯងមេឃុំណា ជំទប់ណា ចាត់ទុកថា ក្បត់គាត់ មិនស្មោះត្រង់ជាមួយបក្សគាត់ គាត់ដកស្ទើរអស់។ ខ្ញុំជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខ្ញុំមិនដឹងរឿងឬ?

គួរបញ្ជាក់ដែរថា ការសាងសង់ផ្លូវនេះគ្រោងចំណាយ ថវិកា ៤០,៨៨០លានដុល្លារ ជាហិរញ្ញប្បទានពីរដ្ឋាភិបាលចិនរួមជាមួយថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ដោះស្រាយផលប៉ះពាល់ និងបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ គម្រោងនេះអនុវត្តសាងសង់ដោយក្រុមហ៊ុនសាជីវកម្មស្ពានថ្នល់ ចិន (CRBC) ដោយប្រើរយៈពេលសាងសង់ចំនួន៣៦ខែហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២០។

ការដ្ឋានសាងសង់ ផ្លូវលេខ៥១ ប្រវែង៣៧,៩៦០ គីឡូម៉ែត្រ ចាប់ពីខេត្តដ្ឋដល់ដំណាក់អំពិលតភ្ជាប់ពីផ្លូវលេខ៤ និងលេខ៥

ចងចាំជានិច្ចនូវស្នាដៃ និងគំរូចរិតភាពដ៏ថ្លៃថ្លារបស់ សម្តេចវិបុលបញ្ញា សុខ អាន

សម្តេចវិបុលបញ្ញា សុខ អាន សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាល គណបក្សប្រជាជនកម្ពុជា សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានទទួលមរណភាពនៅថ្ងៃ ៣ រោច ខែផល្គុន ឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១៨:៣២ នាទី នៅមន្ទីរពេទ្យទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ដោយរោគាពាធ ក្នុងជន្មាយុ ៦៦ឆ្នាំ ។

ការទទួលមរណភាពរបស់**សម្តេចវិបុលបញ្ញា សុខ អាន** គឺជាការបាត់បង់នូវបញ្ញាវន្តដ៏ឆ្នើមម្នាក់ និងជាឥស្សរជនខាងនយោបាយដ៏ប៉ិនប្រសព្វម្នាក់របស់គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ដែលកន្លងមកសម្តេចបានរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុបម្រើប្រជាជន និងសង្គមជាតិដោយស្មោះត្រង់ ព្រមទាំងបានបូជាអស់កម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញាស្មារតី ចូលរួមក្នុងដំណើរការស្វែងរកសន្តិភាព ការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី លើកកម្ពស់កិត្យានុភាពជាតិ លើឆាក អន្តរជាតិ និងនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា។

សម្តេចវិបុលបញ្ញាជាបញ្ញាវន្តពោរពេញដោយចំណេះ ហើយសម្តេច ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ច និងតួនាទីជាច្រើនផ្សេងទៀតរហូតដល់ជីវិតចុងក្រោយ។ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានប្រោសព្រះរាជទានគោរមងារដល់សម្តេចជា «**សម្តេចវិបុលបញ្ញា សុខ អាន**» ដោយសារសម្តេចមានស្នាដៃចូលរួមកសាងសន្តិភាពជាតិ ឯកភាពជាតិ សេដ្ឋកិច្ចជាតិ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ ការពារលទ្ធិប្រជាធិបតេយ្យ និងសន្តិសុខសង្គមបានយ៉ាងល្អប្រសើរ ។

សម្តេចវិបុលបញ្ញា សុខ អាន កើតនៅថ្ងៃទី ១៦ ខែមេសា ឆ្នាំ១៩៥០ ស្ថិតក្នុងភូមិកំពង់ ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ។ **សម្តេច សុខ អាន** បានបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ១៩៦៧។ មកដល់អំឡុងឆ្នាំ ១៩៧២ សម្តេចវិបុលបញ្ញាបានទទួលសញ្ញាប័ត្រជាបន្តបន្ទាប់ដូចជា ផ្នែកភូមិវិទ្យា ប្រវត្តិវិទ្យា សង្គមវិទ្យា នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៥ សម្តេចបានចូលរួមកម្មវិធីបណ្តុះបណ្តាលផ្នែកការ

សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន សំដែងការអាឡោះអាល័យចំពោះការបាត់បង់ សម្តេចវិបុលបញ្ញា សុខ អាន

ទូតជាន់ខ្ពស់នៅសាលាជាតិរដ្ឋបាលជាន់ខ្ពស់។ ពាក់ព័ន្ធនឹងបទពិសោធន៍ការងារនៅឆ្នាំ១៩៦៨ ដល់ឆ្នាំ១៩៧២ **សម្តេចវិបុលបញ្ញា សុខ អាន** បានធ្វើជាសាស្ត្រាចារ្យនៃក្រសួងអប់រំជាតិនៅខេត្តតាកែវ ជានាយកអនុវិទ្យាល័យព្រះបាទជាន់ជុំខេត្តតាកែវ និងជាសាស្ត្រាចារ្យទុតិយភូមិនៅខេត្តសៀមរាប ។

កាលពីអំឡុងទសវត្ស៍ ៨០ **សម្តេចវិបុលបញ្ញា សុខ អាន** ត្រូវបាន **សម្តេចតេជោ ហ៊ុន សែន** ជ្រើសរើសឲ្យធ្វើជាលេខាធ្លាប់នៅពេលដែលសម្តេចតេជោធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៨ សម្តេចបានធ្វើជាប្រធានមន្ទីរនៃក្រសួងការបរទេស និងជាអគ្គ-លេខាធិការនៃគណៈកម្មាធិការសន្តិភាពកម្ពុជា និងជាឯកអគ្គរាជ-ទូតកម្ពុជាប្រចាំប្រទេសឥណ្ឌា ។ ពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩១ សម្តេចធ្វើជាអនុរដ្ឋមន្ត្រីក្រសួងការបរទេស និងជាប្រធានគណៈកម្មាធិការជាតិយូណេស្កូ (UNESCO) កម្ពុជា។ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ២០០៤ សម្តេចបានធ្វើជាប្រធានខុទ្ទកាល័យនៃគណៈ-កម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា, អនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាអគ្គលេខាធិការនៃគណៈកម្មាធិការនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC), ជាសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ ពីឆ្នាំ១៩៩៣ មកដល់ ឆ្នាំ២០១៧ ជាសមាជិករដ្ឋសភាមណ្ឌលតាកែវ ជាប្រធានអាជ្ញាធរជាតិអប្សរានិងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ កាលពីឆ្នាំ ២០១៣ **សម្តេច សុខ អាន** ត្រូវបានមហាសន្និបាតអង្គការ

សម្ដេចក្រឹ ហេង សំរិន ប្រទានភ្លើងជាកិត្តិយស
*បូជាសព**សម្ដេចវិបុលបញ្ញា សុខ អាន***

*មរណភាព**សម្ដេចវិបុលបញ្ញា សុខ អាន** គឺជាការបាត់បង់ដ៏ធំធេង*
សម្រាប់ប្រជាជនកម្ពុជា និងសហគមន៍ពិភពលោក

យូណេស្កូ ជ្រើសរើស ធ្វើជាប្រធានមហាសន្និបាតសម័យប្រជុំលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។

សម្ដេចវិបុលបញ្ញា នៅមានតួនាទីជាច្រើនទៀតដូចជា ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល, ប្រធានអាជ្ញាធរជាតិប្រេងកាតកម្ពុជា, ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា, ប្រធានក្រុមប្រឹក្សាភិបាលរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ, ប្រធានក្រុមការងារចរចា ដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប្រធានក្រុមប្រឹក្សាភិបាលសាលាភូមិន្ទរដ្ឋបាលជាដើម។ **សម្ដេចវិបុលបញ្ញា សុខ អាន** បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការចរចាជាមួយអង្គការសហប្រជាជាតិ ដើម្បីកៀរគរជំនួយពីបស្ចិមប្រទេសបង្កើតតុលាការខ្មែរក្រហម និងបានធ្វើឱ្យតុលាការនេះដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៩ មក។ ក្រៅពីនេះ សម្ដេចក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្នើឱ្យដាក់បញ្ចូលប្រាសាទព្រះវិហារក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ និងបានជួយខ្នុះខ្នែងប្តឹងតវ៉ារហូតទទួលបានជ័យជម្នះ លើការបកស្រាយសំណុំរឿងជម្លោះប្រាសាទព្រះវិហារ ជាមួយប្រទេសថៃ នៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ សម្ដេចគឺជាអ្នកការទូតខាងវប្ប៉ធ៌ម ដ៏មានប្រជាប្រិយភាពក្នុងការការពារសម្បត្តិវប្ប៉ធ៌ជាតិ ដោយចរចានាំយកត្រឡប់មកវិញ នូវរូបបដិមាករជាច្រើនដែលត្រូវបានលួចយកចេញទៅក្រៅប្រទេស។ សម្ដេចក៏ជាស្ថាបនិកនៃ ICC អង្គរ (International Coordination Committee for The Safeguarding and Development of Historic Site of Angkor) និង ICC ព្រះវិហារ ដែលនាំមកនូវជំនួយយ៉ាងច្រើនសម្រាប់ការអភិរក្ស និងអភិវឌ្ឍតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោក។

ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជានិងរាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្ដេចតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដ៏ឈ្លាសវៃ ជាអ្នកគូសវាសផែនការយុទ្ធសាស្ត្រ និងយុទ្ធវិធីដ៏ប៉ិនប្រសព្វផងនោះ **សម្ដេចវិបុលបញ្ញា សុខ អាន** បានខិតខំប្រឹងប្រែងជាមួយឥស្សរជន និងសហការី ដ៏ឆ្នើមដទៃទៀតអនុវត្តធ្វើឲ្យបានជោគជ័យនូវផែនការទាំងអស់នោះ ដើម្បីបានជាប្រយោជន៍ដល់ប្រទេសជាតិ និងប្រជាជន។ លោកជំទាវ **អ៊ីរ៉ីណា បូកូ**ម៉ា អគ្គនាយិកាអង្គការយូណេស្កូ បានសម្ដែងការគោរពចំពោះ **សម្ដេចវិបុលបញ្ញា សុខ អាន** ដោយលោកជំទាវចាត់ទុកថា មរណភាពរបស់សម្ដេច គឺជាការបាត់បង់ដ៏ធំធេងសម្រាប់សហគមន៍ពិភពលោក ដែលយកចិត្តទុកដាក់លើការងារអភិរក្សបេតិកភ័ណ្ឌ។ សម្ដេចគឺជាស្ថាបនិកដ៏សំខាន់មួយរូប ក្នុងបណ្ដាឥស្សរជនក្នុងយុទ្ធនាការអន្តរជាតិ ដើម្បីសង្គ្រោះស្រោចស្រង់ និងគាំពារអភិរក្សរមនីយដ្ឋានបុរាណអង្គរ។

សម្ដេចតេជោ ហ៊ុន សែន បានចារនៅលើក្រាំងមាសនៃសៀវភៅមរណៈទុក្ខថា៖ «**យើងនៅចងចាំមិនភ្លេចឡើយនូវអនុស្សាវរីយ៍ ដែលសម្ដេចវិបុលបញ្ញា សុខ អាន បានឆ្លងកាត់ជាមួយយើងជាង ៣៨ឆ្នាំ ក្នុងបុព្វហេតុបម្រើជាតិ សាសនា និងព្រះមហាក្សត្រនៅពេលដែលសម្ដេចនៅមានជីវិត ។ សំខាន់ជាងនេះទៅទៀត គឺយើងខ្ញុំសូមចងក្រងទុកនៅក្នុងចិត្ត នូវគុណបំណាច់ទាំងឡាយ ដែលសម្ដេចបានបន្សល់ទុកចំពោះប្រទេសជាតិ ហើយត្រូវបានចារឹកទុកនៅក្នុងទំព័រប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជាយើង**» ។

ស្នាដៃ និងគំរូវីរភាពដ៏ថ្លៃថ្លារបស់**សម្ដេចវិបុលបញ្ញា សុខ អាន** នឹងបានជាចំណេះដឹង និងបទពិសោធន៍ដ៏មានសារៈសំខាន់សម្រាប់កូនខ្មែរជំនាន់ក្រោយបន្តរៀនសូត្រតាម និងប្រើប្រាស់ដើម្បីជាឧត្តមប្រយោជន៍ជាតិតទៅអនាគត។

សូមឱ្ទិស បួងសួងសុំឲ្យដួងវិញ្ញាណក្ខន្ធ **សម្ដេចវិបុលបញ្ញា សុខ អាន** បានស្ថិតស្ថេរក្នុងស្ថានបរមសុខជារៀងដរាប។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ព្រឹកថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៧ នេះ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតជាជ័យលាភី នៅវិទ្យាស្ថានក្រុងអង្គរ ខេត្តកំពង់ធំ ។ ឯកឧត្តមបណ្ឌិត **ឌួន ញ៉ិល** មានប្រសាសន៍ផ្តាំផ្ញើរដល់ក្មួយៗនិស្សិតជ័យលាភីទាំងអស់មិនត្រូវគិតថា ការសិក្សារបស់ខ្លួនបញ្ចប់នៅត្រឹមនេះទេ គឺយើងរៀនសូត្ររហូត រៀនសូត្រពីសាលា រៀនសូត្រពីគ្រួសារ រៀនសូត្រពីសង្គម និងរៀនសូត្រដោយខ្លួនឯង តាមរយៈការឧស្សាហ៍អាន ឧស្សាហ៍សង្កេត ដើម្បីអភិវឌ្ឍន៍ខ្លួន និងទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀត ។ បើយើងបោះបង់ការសិក្សា រៀនសូត្រចោល បានសេចក្ដីថាយើងឈរនៅមួយកន្លែង និងមិនទទួលបានចំណេះដឹងថ្មីៗ និងដើរទាន់សភាពការណ៍វិវឌ្ឍន៍រីកចំរើនរាល់ថ្ងៃឡើយ ។

នៅថ្ងៃទី០៤ ខែមិនា ឆ្នាំ២០១៧ លោកជំទាវ **ម៉ែន សំអុន** សមាជិកគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្ដាល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានអញ្ជើញចូលរួមក្នុងកម្មវិធីបុណ្យផ្កាសាមគ្គី នៅវត្តធម្មត្រ័យ ដែលមានទីតាំង ស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីប្រមូលបច្ច័យយកទៅកសាងផ្លូវបេតុង និងចាក់សាប ទីធ្លាក្នុងបរិវេណវត្ត ជ័យមង្គលារាម ហៅវត្តត្រពាំងស្នា ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងស្នា ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ លោកជំទាវមានប្រសាសន៍ថា ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិត របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រទេសពីបាតដៃទទេ រហូតដល់មានការអភិវឌ្ឍន៍ដូចសព្វថ្ងៃនេះ ក្នុងនោះវិស័យព្រះពុទ្ធសាសនាក៏មានការរីកចម្រើន និងអភិវឌ្ឍន៍ជឿនលឿនផងដែរ ។

ថ្មីៗនេះឯកឧត្តមឧបនាយករដ្ឋមន្ត្រី **កែ គឹមយ៉ាន** ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តបន្ទាយមានជ័យ មានការចូលរួមអមដំណើរដោយឯកឧត្តម**ស្ងួនបវរ**ប្រធានយុវជនគណបក្សខេត្ត ឯកឧត្តម **អន ស៊ុំ** ឯកឧត្តម **អ៊ុំ រាត្រី** និងក្រុមការងារខេត្តបានជួបសំណេះសំណាលជាមួយសមាជិកបក្សឃុំអូរបីជាន់ ស្រុកអូរជ្រៅ។

រសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ឆាយ ថន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ទេសរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តអមដំណើរ ដោយឯកឧត្តម **រិន ឌីរ:** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកក្រុមការងារយុវជនថ្នាក់កណ្ដាល អនុប្រធានក្រុមការងារគណៈកម្មាធិការកណ្ដាលជួយស្រុក និងប្រធានក្រុមការងារជួយឃុំ ឯកឧត្តម **សួស គង់** សមាជិកគណៈកម្មាធិការកណ្ដាល និងជាប្រធានក្រុមការងារចុះជួយស្រុក បានអញ្ជើញជួបសំណេះ-សំណាលជាមួយលោកគ្រូ អ្នកគ្រូ និងគ្រូពេទ្យចំនួន ៧៧៧នាក់ នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ក្នុងឱកាសនោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ឆាយ ថន** បានឧបត្ថម្ភជូនពួកគាត់ក្នុងម្នាក់ៗទទួលបានថវិកាម្នាក់ ២០០០០រៀល និងសារុងមួយ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ព្រឹកថ្ងៃទី១៧ ខែមីនា ឯកឧត្តមនាយឧត្តមសេនីយ៍ **ហាស សុតា** សមាជិកគណៈអចិន្ត្រៃយ៍ កម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក អមដំណើរដោយឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត កោះកុង បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខកងកម្លាំងវិស្វកម្មកងទ័ពជើងគោក ដែលកំពុងស្ថាបនាផ្លូវក្រាលក្រួសក្រហមប្រវែង ១៨.០០០ ម៉ែត្រពីសាលាស្រុកថ្មបាំងចូលទៅអារ៉ែងស្ថិតក្នុងស្រុកថ្មបាំងខេត្តកោះកុង។

ព្រឹកថ្ងៃទី២០ ខែមីនា ឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ តំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បានអញ្ជើញជាអធិតីក្នុងពិធីសម្ពោធឆ្លង និងបញ្ចុះខណ្ឌសីមាព្រះវិហារ វត្តឧត្តុងមានជ័យ ហៅវត្តស្រែតានង ឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយបាននាំយកថវិការបស់សម្ដេចតេជោចូលរួមចំណែកកសាងព្រះវិហារចំនួន២០.០០០ដុល្លារផងដែរ។

ព្រឹកថ្ងៃទី ១៥ ខែមីនា ឯកឧត្តម **លឹម គានហោ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម បានអញ្ជើញចុះពិនិត្យការដ្ឋានសាងសង់ប្រព័ន្ធធារាសាស្ត្ររាមគុន ស្ថិតក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ប្រព័ន្ធធារាសាស្ត្ររាមគុន នេះ ត្រូវបានសាងសង់ឡើងក្រោមហិរញ្ញប្បទានពីប្រទេសជប៉ុន និងអនុវត្តគម្រោងដោយក្រុមហ៊ុន Tidal Marine Engineering SDN, BHD ដែលជាក្រុមហ៊ុនសាងសង់មកពីប្រទេសម៉ាឡេស៊ី ។

ព្រឹកថ្ងៃទី ១២ ខែមីនា បន្ទាប់ពីបានជួបសំណេះសំណាលជាមួយបងប្អូនក្រុមម៉ូតូឌុបរួចមក ឯកឧត្តម **ស៊ុយ សែម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជានិងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្ត ពោធិ៍សាត់ បានបន្ដជួបសំណេះសំណាលជាមួយយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់ស្រុក និងថ្នាក់ឃុំ ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។

ព្រឹកថ្ងៃទី១១ ខែមីនា ឯកឧត្តម **ឌន សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា ឯកឧត្តម **ប៉ា សុជាតិវង្ស** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងឯកឧត្តម **ម៉ៅ ភិរុណ** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជានកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកណ្ដាលបានរួមគ្នាក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារមួយខ្នង ម្រាប់ធ្វើជាមជ្ឈមណ្ឌលទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី នៅមជ្ឈ-មណ្ឌលកុមារកំព្រាបារាំងហុងគ្រី ស្ថិតក្នុងភូមិបាគូ ឃុំបាគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។អគារដែលត្រូវសាងសង់នាពេលនេះមានទំហំ៩ម៉ែត្រគុណនឹង៤៦ម៉ែត្រ និងមានកម្ពស់២ ជាន់ស្មើនឹង១០ បន្ទប់។ ថវិកាសាងសង់មួយចំនួនធំជារបស់សាលារាជធានីភ្នំពេញ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ក្នុងខែមីនា ឯកឧត្តម **ពេជ្រ ឫទ្ធិន** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តក្រចេះ បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំស្រែជិះ ស្រុកសំបូរ ខេត្ត-ក្រចេះ ដែលអញ្ជើញមកពី៦ ភូមិ ។

ថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៧ នេះ នៅវិទ្យាល័យ **ហ៊ុន សែន** ចារ្ចី ភូមិចារ្ចី ឃុំចុងជាច ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ឯកឧត្តម **ភេង សាខុន** សមាជិកគណកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋានស្រុកតំបែរ ខេត្តត្បូងឃ្មុំ បានអញ្ជើញជាអធិបតីភាពក្នុងវេទិកាសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ដោយមានការចូលរួមពីប្រជាពលរដ្ឋប្រមាណ ៧០០នាក់។

ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែមីនា គណៈប្រតិភូវិស្វកម្មអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ដឹកនាំដោយឯកឧត្តមនាយឧត្តមសេនីយ៍ **ខ្ជាន់ ស៊ាម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងមេបញ្ជាការវិស្វកម្មអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ បានអញ្ជើញទៅ ពិនិត្យស្ថានភាព និងលក្ខណៈភូមិសាស្ត្រសម្រាប់សង់ស្ពានបេតុងចំនួនប្រាំកន្លែង ក្នុងស្រុកមួយចំនួននាទិសខេត្តបាត់ដំបង។

ថ្ងៃទី៤ មីនា ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជាមេបញ្ជារងកងទ័ពជើងគោក មេបញ្ជាការ នៃបញ្ជាការដ្ឋានជាតិកងកម្លាំងពិសេសប្រឆាំងភេរវកម្ម ដោយមានការអញ្ជើញចូលរួមពីមន្ត្រីអាជ្ញាធរដែលពាក់ព័ន្ធផងដែរបានចុះទៅត្រួតពិនិត្យមើលការស្ថាបនាផ្លូវខ្សែក្រវាត់ព្រំដែនកម្ពុជា - វៀតណាម ខណៈពេលដែលកងកម្លាំងកងវិស្វកម្មនៃកងខេមរភូមិន្ទធ្វើការឈូសឆាយផ្លូវចាប់ពីបង្គោលព្រំដែនលេខ៣០ ចំណុចច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តម **ចាន់ ចេស្ដា** អភិបាលនៃគណៈអភិបាលខេត្តកំពត បានដឹកនាំមន្ត្រីនៃមន្ទីរសង្គមកិច្ចក្រុមការងារខេត្ត ស្រុក និងយុវជន ចុះចែកអំណោយជូនបងប្អូនប្រជាពលរដ្ឋរងគ្រោះដោយភ្លើងឆេះផ្ទះចំនួន៧ គ្រួសារនៅភូមិត្រពាំងរពៅ ឃុំព្រៃកន្ទោត ស្រុកទឹកឈូ ខេត្តកំពត។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

*ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **នាយ ឌន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលទេសរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្ត អមដំណើរដោយ ឯកឧត្តម **រិន ទិរៈ** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកក្រុមការងារយុវជនថ្នាក់កណ្ដាល អនុប្រធានក្រុមការងារគណៈកម្មាធិការ កណ្ដាលជួយស្រុក និងជាប្រធានក្រុមការងារជួយឃុំ បានអញ្ជើញចូលរួមសំណេះសំណាលជាមួយភ្នាក់ងារសង្កេតការបោះឆ្នោតរបស់គណបក្ស នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។*

គណៈប្រតិភូក្រុមការងារយុវជនគណបក្ស ថ្នាក់កណ្ដាល ដែលដឹកនាំដោយ ឯកឧត្តម **កែ ឫទ្ធនខៀង** ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ឯកឧត្តម **ហ៊ុន ម៉ាណេត** អនុប្រធានក្រុមការងារ យុវជនគណបក្ស ថ្នាក់កណ្ដាល និងសមាជិក ២៣រូប បានបំពេញទស្សនកិច្ចផ្លាស់ប្ដូរបទពិសោធការងារយុវជន ពីថ្ងៃទី១៩ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៧ នៅ សាធារណរដ្ឋប្រជាមានិតចិន។ គណៈប្រតិភូបាន៖

-ជួបសម្ដែងការគួរសមជាមួយ ឯកឧត្តម Zheng Xiaosong អនុរដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិបក្សកុម្មុយនីស្ដចិន។

-ជួបពិភាក្សាការងារជាមួយ លោកជំទាវ Wang Hongyan សមាជិក លេខាធិការដ្ឋាននៃគណៈកម្មាធិការកណ្ដាលសម្ព័ន្ធយុវជនកុម្មុយនីស្ដចិន។

-ជួបសំណេះសំណាលអាហារសាមគ្គីជាមួយនិស្សិតអាហារូបករណ៍ និងយុវជនខ្មែរដែលសិក្សានៅរដ្ឋធានីប៉েকាំង សាធារណរដ្ឋប្រជាមានិតចិន។

*ព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ហ៊ុន ម៉ាណេត** សមាជិកគណៈកម្មាធិការកណ្ដាល និងជាអនុប្រធានក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល បានជួបសំណេះសំណាលជាមួយក្រុមការងារយុវជនគណបក្សខេត្ត ស្រុក ក្រុង និងសកម្មជនយុវជនគណបក្សឃុំ ភូមិ ទូទាំងខេត្តស្វាយរៀង ដោយមានការចូលរួមពី ឯកឧត្តម **ម៉ែន ទិព្ធុល** ប្រធានគណៈកម្មាធិការគណបក្សខេត្ត ឯកឧត្តម **ឌី ទិញ្ញា** អនុប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តទទួលបន្ទុកការងារយុវជនឯកឧត្តម**ហេង សុខណាង**ប្រធានក្រុមការងារយុវជនគណបក្សខេត្ត ឯកឧត្តមលោកជំទាវ លោក លោកស្រីអ្នកនាង កញ្ញា ភ្ញៀវកិត្តិយសក្រុមការងារយុវជនរាជធានី-ខេត្ត ក្រុមការងារសមាជិក សមាជិកា សកម្មជនយុវជនប្រមាណ ១២០០នាក់ ។*

រសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តម **ស សុខា** អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជា ជាយុវជនគណបក្សចំនួន ៥២៧ នាក់ ស្រុកស៊ីធរកណ្ដាល ស្រុកពោធ៍រៀង និងក្រុងព្រៃវែង និងបានចែកសញ្ញាបត្រវគ្គខ្លី១ កុំព្យូទ័រ ជូនដល់សមាជិកបក្សដែលបានបញ្ចប់វគ្គសិក្សា នៅមន្ទីរគណបក្សខេត្តព្រៃវែង ។

*នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ឌី ទិញ្ញា** អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្ដាល ចុះជួយខេត្តស្វាយរៀងទទួលការងារយុវជន បានអញ្ជើញជាគណៈអធិបតីក្នុងពិធីប្រកាសទទួលស្គាល់ក្បាលម៉ាស៊ីនយុវជនគណបក្សស្រុក ឃុំនិងភូមិ ដោយមានការចូលរួមពី ឯកឧត្តម **ទុំ សារ៉ាឌុច** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាអនុប្រធានយុវជនគណបក្សខេត្ត និងលោក **ភូត ប៉ូលីកា** អនុប្រធានក្រុមការងារយុវជនគណបក្សខេត្ត រួមទាំងមានការចូលរួមពីអស់លោក លោកស្រី ជាសមាជិក សមាជិកា ក្រុមការងារ អស់លោកប្រធាន អនុប្រធាន សមាជិក សមាជិកា គណបក្សប្រជាជនកម្ពុជា ទាំង១១ឃុំ ព្រមទាំងក្រុមការងារយុវជនគណបក្ស ស្រុក និងសកម្មជនយុវជនគណបក្ស ឃុំ និងភូមិ សរុប៤៣៥នាក់។*

ព្រឹកថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ឆួន ផារ៉ែត** សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល អនុប្រធានគណៈកម្មាធិការគណបក្សខេត្ត ប្រធានក្រុមការងារយុវជនគណបក្សខេត្ត បានរៀបចំវគ្គបណ្ដុះបណ្ដាលជុំទី ២ ដល់ក្រុមការងារយុវជន និងសកម្មជនយុវជនគណ-បក្សក្រុងច្បារមន និងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

*ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តម **អ៊ុង រឿន** ប្រធានគណបក្ស ខេត្តបន្ទាយមានជ័យ ឯកឧត្តម **សួន បវរ** អនុប្រធានគណបក្សខេត្ត សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត បានដឹកនាំក្រុមការងារយុវជនគណបក្សខេត្ត យុវជនស្រុកមង្គលបូរី ចូលពិនិត្យមើលរោងចក្រកាត់ដេរនៅភូមិខ្លាកូនថ្មី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ដែលមានកម្មករកាត់ដេរប្រមាណជាង១៣០០ នាក់ និងបានចូលរួមពិធីចែករនេះរុញជូនដល់ជនពិការ ១០០នាក់ និងចែកអំណោយជូនជនគ្រួសារក្រីក្រ ១០០គ្រួសារនៅស្រុកមង្គលបូរី ជាអំណោយសប្បុរសជនមកពីសហរដ្ឋអាមេរិក និងប្រទេសបារាំង នៅភូមិជំទាវ ឃុំឫស្សីក្រោក ។*

ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **ឡាយ គឹមលី** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល និងក្រុមការងារថ្នាក់កណ្ដាល ក្រុមការងារស្រុក ឃុំ បានលើកស្លាកគណបក្សប្រជាជនកម្ពុជា នៅឃុំស្រះជីក ស្រុកភ្នំស្រុក ។

*ព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពត បានបើកកិច្ចប្រជុំក្បាលម៉ាស៊ីនថ្នាក់ដឹកនាំខេត្ត ស្រុក ក្រុងត្រួតពិនិត្យ ការរៀបចំរចនាសម្ព័ន្ធក្រុមការងារយុវជនបច្ចុប្បន្នភាពយុវជន ក្រោមអធិបតី ឯកឧត្តម **ភុន សារពេជ្ជ** សមាជិកក្រុមការងារយុវជនថ្នាក់កណ្ដាល និងជាប្រធានក្រុមការងារយុវជនខេត្តកំពត។ ជាលទ្ធផលក្រុមការងារសម្រេចបាន ៨០% ហើយទូទាំងខេត្ត ដែលជាតួលេខកម្លាំងជាក់លាក់ច្បាស់លាស់ សំរាប់ការពារគណបក្ស និង បោះឆ្នោតជូនគណបក្ស ។*

នារសៀលថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តម **ទុំ សារាឫទ្ធ** សមាជិកក្រុមការងារយុវជនថ្នាក់កណ្ដាល និងជាអនុប្រធានក្រុមការងារយុវជនគណបក្សខេត្តស្វាយរៀង បានបើកនិងឧទ្ទេសនាមវគ្គចែករំលែកចំណេះដឹងព័ត៌មានវិទ្យា ស្ដីពីបណ្ដាញសង្គម (Social Network) ដោយមានការចូលរួមពីជនបង្គោលគណបក្ស ខេត្ត ក្រុង ស្រុក ទទួលខុសត្រូវការងារបណ្ដាញទំនាក់ទំនងសង្គម។

*ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ លោក ស្រី សុភ័ក្ត្រ សមាជិកក្រុមការងារយុវជនគណបក្សថ្នាក់កណ្ដាល ប្រធានក្រុមការងារយុវជនគណបក្សខេត្ត បានធ្វើបទបង្ហាញពីប្រវត្តិស្នាដៃគណបក្ស ក្នុងវគ្គបណ្ដុះបណ្ដាល ស្ដីពីវិធីសាស្ត្រប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គម ដល់យុវជនគណបក្ស ប្រជាជនកម្ពុជា ស្រុកចំការលើ ខេត្តកំពង់ចាម ដែលមានយុវជនចូលរួមចំនួន ១៥០ នាក់ ដោយមានការចូលរួមជាអធិបតី និងឧបត្ថម្ភពីសំណាក់ ឯកឧត្តម **ហួត ហាក់** សមាជិកក្រុមការងារយុវជនថ្នាក់កណ្ដាល និងជាប្រធានជនបង្គោលយុវជនស្រុកចំការលើ និងសហការី។*

នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ លោក គង់ ឫទ្ធារ៉ុង យុវជនជាបេក្ខជនក្រុមប្រឹក្សាសង្កាត់ព្រៃកលៀប អាណត្តិទី៤ រួមជាមួយលោកស្រី ស្ងៀន សង្កាត់ ប្រធានក្រុមសកម្មជនយុវជនគណបក្សសង្កាត់ព្រៃកលៀប ខណ្ឌជ្រោយចង្វារ បានចុះសាកសួរសុខទុក្ខ និងប្រគល់សំបុត្រកំណើតជូនកូន លោក អ៊ិត ពិសិដ្ឋ យុវជនភូមិព្រៃកលៀប ដែលប្រពន្ធទើបសំរាលកូន រួមជាមួយថវិកា ៥០.០០០ រៀល និងទឹកដោះគោ ១ឡូ (សរុប ៧០.០០០ រៀល)។ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ ក្រុមការងារនេះក៏បានបន្ដនាំយកថវិកា និងទឹកដោះគោ ជារបស់យុវជនសង្កាត់ ទៅសួរសុខទុក្ខលោក ហុង គឹមហ៊ឿង អនុប្រធានយុវជនភូមិគៀនឃ្លាំង ដែលម្ដាយកំពុងសំរាកព្យាបាលជម្ងឺ នៅមន្ទីរពេទ្យ ព្រះកេតុមាលា ថវិកា ១០០.០០០ រៀល និងទឹកដោះគោ ១ឡូ។

កម្ពុជា-វៀតណាម ខិតខំពង្រឹងទំនាក់ទំនងលើគ្រប់វិស័យ ដើម្បីផលប្រយោជន៍ទៅវិញទៅមក

*ឯកឧត្តម **ជាម ប៊ីញមិញ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម និង**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា*

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសភូមិរបងជាមួយ ដោយមានព្រំដែនគោកជាប់គ្នាជាងមួយពាន់គីឡូម៉ែត្រនោះ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រទេសទាំងពីរបានពង្រឹងពង្រីកទំនាក់ទំនងជាមួយគ្នាលើគ្រប់ថ្នាក់ គ្រប់វិស័យ។ផ្តើមចេញពីចំណុចខិតខំនេះ ប្រជាជននៃប្រទេសទាំងពីក៏បានទទួលនូវផលប្រយោជន៍ដូចគ្នា ។ ទន្ទឹមនេះប្រទេសទាំងពីរក៏បានពិនិត្យរួមគ្នាផងដែរ លើលទ្ធផលទទួលបាន និងកែលំអចំណុចដែលអនុវត្តពុំទាន់បានល្អ ដែលក្នុងនោះលើនយោបាយ ព្រំដែន សេដ្ឋកិច្ច វប្បធម៌ សង្គម។ល។

លទ្ធផលនៃទំនាក់ទំនងនិង ការពិនិត្យសកម្មភាពការងាររវាងប្រទេសទាំងពីរបានបង្ហាញឡើងនៅក្នុងខែមីនា កន្លងទៅ តាមរយៈនៃកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា(ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧)និងកិច្ចប្រជុំលើកទី១៥ របស់គណៈកម្មការចំរុះ កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា(ថ្ងៃទី ១៣ -១៥ ខែមីនា ឆ្នាំ២០១៧) ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។

តាមរយៈកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម ប្រទេសទាំងពីរបានវាយតម្លៃខ្ពស់ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក៏ដូចជាប្រជាជនទាំងពីរ ក្នុងការកសាងខ្សែបន្ទាត់ព្រំដែន និងតំបន់ព្រំដែនមិត្តភាព សហប្រតិបត្តិការ និងមានការអភិវឌ្ឍ និងមានផលប្រយោជន៍ទាំងសងខាង សម្រាប់ប្រជាជននៃប្រទេសទាំងពីរ។

ដោយឡែកទាក់ទង នឹងការជួលដីនៅតាមតំបន់ព្រំដែន រវាងប្រទេសទាំងពីរ គឺភាគីទាំងសងខាងបានឯកភាពគ្នារួចហើយ ដោយបញ្ឈប់ការជួលដីទាំងសងខាង ដែលប្រជាជនប្រទេសមួយជួលដីឲ្យប្រទេសមួយ ហើយអាជ្ញាធរទាំងពីរបន្តសហការគ្នា ដើម្បីធ្វើកិច្ចការងារនេះឲ្យកាន់តែជាក់ស្តែងថែមទៀត។

ផ្តើមចេញពីស្មារតីនៃកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាមនេះដែរ ភាគីទាំងពីរវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ ដែលត្រូវបានបន្តពង្រឹងនិងលើកកម្ពស់ជាប្រចាំ។ ទំហំពាណិជ្ជកម្មសរុបកម្ពុជា វៀតណាម ឆ្នាំ២០១៦ សម្រេចបានប្រមាណ ២ ៩២០លានដុល្លារអាមេរិកថយចុះ ១៣,១% ធៀបនឹងឆ្នាំ២០១៥។ ទំនិញវៀតណាមនាំចូលកម្ពុជាសម្រេចបានប្រមាណ២ ២០០លានដុល្លារ ថយចុះ៨,៨%។ ទំនិញកម្ពុជានាំចូលវៀតណាមសម្រេចបានប្រមាណ ៧២៥,៨លានដុល្លារ ថយចុះ២៤% ធៀបនឹងឆ្នាំ២០១៥។ សហការជំរុញដំណើរការសាងសង់ផ្សារគំរូព្រំដែនកម្ពុជាក្នុងតំបន់សេដ្ឋកិច្ចពិសេសថាវី ស្ថិតក្នុងភូមិដារកណ្តាល ឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ(កម្ពុជា)។

ភាគីកម្ពុជា-វៀតណាម បានវាយតម្លៃខ្ពស់ចំពោះក្រុមការងារបច្ចេកទេសនិងគណៈកម្មការចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរ ដែលបានខិតខំប្រឹងប្រែងក្នុងការកំណត់ខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរ ដែលរហូតមកដល់ពេលបច្ចុប្បន្នសម្រេចបានប្រមាណ ៨៤%។សហការគ្នាថែរក្សាបង្គោលព្រំដែន និងបង្គោលតម្រុយព្រំដែន ដែលបានបោះរួចមិនឲ្យមានការបំផ្លិចបំផ្លាញ។ មិនអនុញ្ញាតឲ្យកម្លាំងអមិត្តណាមួយប្រើប្រាស់ទឹកដីរបស់ខ្លួន ដើម្បីបំពានបំផ្លាញសន្តិសុខ ស្ថិរភាពរបស់ប្រទេសម្ខាងទៀតបានជាដាច់ខាត។

ដោយឡែក តាមរយៈលទ្ធផលនៃកិច្ចប្រជុំលើកទី១៥ របស់គណៈកម្មការចំរុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រនិងបច្ចេកវិជ្ជា(ថ្ងៃទី ១៣-ថ្ងៃទី១៥ ខែមីនា)វិញក៏បានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរផងដែរ។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីម្តងទៀត ពីជំហរប្រទេសរបស់ខ្លួន ក្នុងការធ្វើឲ្យចំណងមិត្តភាពនៃប្រទេសទាំងពីរកាន់តែស៊ីជម្រៅ និងពង្រឹងបន្ថែមទៀតនូវយន្តការសកម្មភាពសហប្រតិបត្តិការដែលមានស្រាប់ ដែលប្រទេសទាំងពីរបាននិងកំពុងតែអនុវត្តដើម្បីជាផលប្រយោជន៍ទៅវិញទៅមក ។ នៅលើវិស័យអប់រំ និងបណ្តុះបណ្តាល កម្ពុជាបានយល់ព្រមផ្តល់អាហារូបករណ៍មួយចំនួនដល់និស្សិតវៀតណាមក្នុងកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សាភាសាខ្មែរ។ វៀតណាមក៏បានយល់ព្រមផ្តល់អាហារូបករណ៍ចំនួន១១៦០ កន្លែង (អាហារូបករណ៍រយៈពេលវែង និងរយៈពេលខ្លី) ដល់និស្សិតកម្ពុជាលើមុខវិជ្ជាជាច្រើន។ ភាគីទាំងពីរបានឯកភាពក្នុងការដំឡើងប្រាក់បៀវត្សដល់និស្សិតអាហារូបករណ៍ដែលកំពុងសិក្សានៅក្នុងប្រទេសនីមួយៗ ដើម្បីមានការរស់នៅល្អជាងមុន។ ចំពោះកិច្ចសហប្រតិបត្តិការផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភាគីទាំងពីរបានយល់ព្រមបន្តពង្រឹង

កិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ប្រយុទ្ធ និងរឹតបន្ដឹងពាណិជ្ជកម្មខុសច្បាប់ឆ្លងកាត់ព្រំដែន ដូចជាឈើ សត្វព្រៃ ផលិតផលកៅស៊ូធម្មជាតិ តាមរយៈការផ្លាស់ប្ដូរព័ត៌មានជាទៀងទាត់រវាងមន្ដ្រីអនុវត្តច្បាប់ និងអាជ្ញាធរខេត្តតាមព្រំដែន។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកថាមពល ភាគីវៀតណាមបានសន្យាធានាការធ្វើពាណិជ្ជកម្មថាមពលអគ្គីសនី ក្នុងគោលបំណងប្រើប្រាស់អគ្គិសនី ស្របទៅតាមសមត្ថភាព និងកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ ។ ភាគីវៀតណាម នឹងពិចារណាបង្កើនការផ្គត់ផ្គង់អគ្គិសនីមកកម្ពុជាតាមការស្នើសុំរបស់កម្ពុជា ដោយស្របទៅតាមស្ថានភាពពិតរបស់ភាគីវៀតណាម ។ ភាគីទាំងពីរបានយល់ព្រមសហការឲ្យបានជិតស្និទ ក្នុងការដោះស្រាយវិធានការបច្ចេកទេស និងការធ្វើវិនិយោគដើម្បីធានាឲ្យបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព អាចជឿជាក់បាននិងទៀងទាត់នៃការតភ្ជាប់ប្រព័ន្ធបណ្ដាញអគ្គិសនីរវាងប្រទេសទាំងពីរ ជាពិសេសខ្សែបណ្ដាញបែងចែកចូដុក-តាកែវ ដែលមានកម្លាំង២២០គីឡូវ៉ុល។

កម្ពុជា-វៀតណាម នឹងលើកទឹកចិត្តសម្របសម្រួលការស្រាវជ្រាវ និងប្រើប្រាស់វិធានការបច្ចេកទេសក្នុងការទទួលយកការផ្គត់ផ្គង់អគ្គិសនីនៅរដូវភ្លៀងប្រហែល១០០ មេហ្គាវ៉ាតពីកម្ពុជាទៅវៀតណាម ក្នុងឥរិយាបទដែលធានានូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព អាចជឿជាក់បានប្រកបដោយភាពទៀងទាត់ដល់ការផ្គត់ផ្គង់ថាមពលអគ្គីសនីសម្រាប់ប្រព័ន្ធអគ្គិសនីរបស់ប្រទេសទាំងពីរ។

លើវិស័យពាណិជ្ជកម្ម និងវិនិយោគ ភាគីទាំងពីរបានវាយតំលៃខ្ពស់ចំពោះកិច្ចប្រឹងប្រែងសម្របសម្រួល ដើម្បីជំរុញការវិនិយោគនៅក្នុងប្រទេសនីមួយៗ និងយល់ព្រមផងដែរ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ភាគីទាំងពីរបានប្រគល់ភារកិច្ចដល់ក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម នូវភារកិច្ចមួយចំនួនក្នុងនោះដូចជា ១. ពង្រឹងកិច្ចសហការក្នុងការទប់ស្កាត់ការរត់ពន្ធឆ្លងកាត់ព្រំដែន និងការកេងបន្លំពាណិជ្ជ-កម្មរួមមាន ការផលិត និងការរត់ពន្ធទំនិញក្លែងក្លាយ និងទំនិញខូចគុណភាព ២.យល់ព្រមដោះស្រាយការខ្វែងគំនិតដើម្បីឈានទៅបញ្ចប់ការចរចា និងចុះហត្ថលេខានៅឆ្នាំ២០១៧ នេះ លើកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មព្រំដែនរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម ដែលកិច្ចព្រមព្រៀងនេះនឹងចូលមកជំនួសកិច្ចព្រមព្រៀងស្ដីពី ពាណិជ្ជកម្ម និងការផ្លាស់ប្ដូរទំនិញ និងសេវាកម្ម នៅតំបន់ព្រំដែនរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម ៣.បញ្ចប់ការសិក្សាពីការរៀបចំផែនការមេស្ដីពីការអភិវឌ្ឍពាណិជ្ជកម្មព្រំដែនកម្ពុជា-វៀតណាម រហូតដល់ឆ្នាំ២០២៥ ដោយមានចក្ខុវិស័យឆ្ពោះទៅឆ្នាំ២០៣៥ និងអភិវឌ្ឍបទបញ្ជាស្ដីពីការគ្រប់គ្រងផ្សារតាមព្រំដែនរវាងប្រទេសទាំងពីរ ៤.រៀបចំសន្ទិសីទលើកទី៦ ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមព្រំដែនកម្ពុជា-វៀតណាម នៅឆ្នាំ២០១៨ នៅកម្ពុជា។

ភាគីទាំងពីរបានយល់ព្រមបញ្ចប់និតិវិធីឲ្យបានឆាប់ ដើម្បីបង្កើតផ្សារគំរូនៅឃុំដា ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ប្រទេសកម្ពុជា។

លើវិស័យដឹកជញ្ជូនភាគីទាំងពីរបាន: ១.ឯកភាព បង្កើនល្បឿនបញ្ចប់ការសាងសង់ស្ពានជ្រៃធំ-ឡុងឃ្ចិញនៅខែមេសាឆ្នាំ២០១៧ និងរៀបចំពិធីសម្ពោធនៅត្រីមាសទី២ នៃឆ្នាំ២០១៧ ២.បញ្ចប់ និងចុះហត្ថលេខានៅឆ្នាំ២០១៧ អនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងសាធារណការ និងដឹកជញ្ជូនរបស់កម្ពុជា និងក្រសួងដឹកជញ្ជូនរបស់វៀតណាមស្ដីពីការសិក្សា និងការកសាងផ្លូវល្បឿនលឿនរវាងទីក្រុងហូជីមីញ និងទីក្រុងភ្នំពេញ។

លើបញ្ហាព្រំដែន ភាគីទាំងពីរបានបញ្ជាក់ជាថ្មីពីការគោរព និងការអនុវត្តយ៉ាងពេញលេញសន្ធិសញ្ញាស្ដីពីការកំណត់ព្រំដែន និងកិច្ចព្រមព្រៀងព្រំដែនពាក់ព័ន្ធ ដែលត្រូវបានចុះហត្ថលេខាដោយប្រទេសទាំងពីរ។ ភាគីទាំងពីរបានកត់សម្គាល់ទៅលើសមិទ្ធផលថ្មីៗ ដែលសម្រេចបានក្នុងការកំណត់ខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែននិងបានសម្ដែងនូវការកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការចំរុះខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម (the Joint Commission on Demarcation and Abornment for Land Boundary-JBC) ក្នុងការសម្រេចការកំណត់ខ័ណ្ឌសីមាព្រំដែនគោក និងការបោះបង្គោលព្រំដែនបានប្រមាណ ៨៤% យោងទៅតាមសន្ធិសញ្ញាស្ដីពីការកំណត់ព្រំដែនរវាងប្រទេសទាំងពីរ។

ភាគីទាំងពីរ បានយល់ព្រមក្នុងការណែនាំដល់អាជ្ញាធរខេត្តជាប់តាមព្រំដែនរបស់ខ្លួន ក្នុងការរក្សាកិច្ចសហការជិតស្និទ្ធជាមួយគណៈកម្មការចំរុះខណ្ឌសីមានិងការបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាមក្នុងការសាងសង់សសរព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែម និងបង្កើនការយល់ដឹងរបស់ប្រជាជនដែលរស់នៅតាមតំបន់ព្រំដែន អំពីសារសំខាន់នៃការកំណត់ព្រំដែនខ័ណ្ឌសីមា និងការការពារសសរព្រំដែន។ ភាគីទាំងពីរក៏មានបំណងរៀបចំកិច្ចពិភាក្សាស្ដីពីការកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរក្នុងពេលដ៏ខ្លីខាងមុខតាមតែអាចធ្វើបាន បន្ទាប់ពីបញ្ចប់ការកំណត់ព្រំដែនគោក។

ក្រៅពីចំណុចដែលបានលើកឡើងខាងលើនេះ ភាគីទាំងពីរបានឯកភាពបង្កើនល្បឿន ការអនុវត្តសកម្មភាព ឬគម្រោងពាក់ព័ន្ធផ្សេងទៀតដែលមានភាពយឺតយ៉ាវក្នុងការអនុវត្ត ហើយក្នុងពេលជាមួយគ្នានេះដែរនឹងរិះរកវិធានការថ្មី និងប្រាកដប្រជា ដើម្បីកែលំអសកម្មភាពនានាថែមទៀត ការធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគោលបំណងសំខាន់បំផុត គឺការសម្រេចឲ្យបាននូវលទ្ធផលកំរិតខ្ពស់ដើម្បីបម្រើផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជនទាំងពីរ ។

តាមរយៈលទ្ធផលនៃកិច្ចប្រជុំទាំងពីរខាងលើនេះ អាចបញ្ជាក់បានថារាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និង**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ដ្រីនៃព្រះរាជាណាចក្រកម្ពុជា កំពុងសម្រេចបាននូវសមិទ្ធផលជាសារវន្ដជូនដល់ប្រជាជនកម្ពុជា និងកសាងប្រទេសកម្ពុជាមួយលើមាគ៌ានៃការអភិវឌ្ឍ ការកសាងកិត្យានុភាពជាតិនៅក្នុងតំបន់និងលើពិភពលោក។

សមិទ្ធផលសេដ្ឋកិច្ច-សង្គម ឆ្នាំ២០១៦

វិស័យសំណង់កំពុងមានការរីកចម្រើនខ្លាំងនៅរាជធានីភ្នំពេញ

នៅក្នុងឆ្នាំ២០១៦ កន្លងទៅនេះ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្ដេចតេជោ ហ៊ុន សែន** ជាប្រមុខប្រទេសកម្ពុជាយើង សម្រេចបាននូវស្នាដៃធំៗជាច្រើនដូចខាងក្រោម៖

១- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច: ចំណូលថវិកាជាតិអនុវត្តបានប្រមាណ ១៤.៣៩៣,៩ ប៊ីលានរៀល ស្មើនឹង ១០៥% នៃផែនការហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលមាន ១៣.៧៤១,១ប៊ីលានរៀល និងចំណាយ ថវិកាជាតិអនុវត្តបានប្រមាណ ១២.០៨៥,៦ប៊ីលានរៀល ស្មើនឹង ៨៩% នៃផែនការហិរញ្ញវត្ថុឆ្នាំ ២០១៦ ដែលមាន ១៣.៥៩១,១ប៊ីលានរៀល។ តុល្យភាពនៃថវិកាជាតិក្នុងឆ្នាំ២០១៦នេះ មានឧត្តម ភាព ២.៣០៨,៣ប៊ីលានរៀល។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខបានកើនឡើង ៣% បើធៀប នឹងឆ្នាំមុន។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកគឺ ៤.០៣៧រៀល ក្នុង១ដុល្លារអាមេរិក បើធៀបនឹងឆ្នាំមុនប្រាក់រៀលឡើងថ្លៃ ០,៣%។

២- កសិកម្ម: លទ្ធផលប៉ាន់ស្មានជំហានដំបូងលើការងារបង្កបង្កើនផលស្រូវឆ្នាំ២០១៦-២០១៧ អាចសម្រេចបានលើផ្ទៃដីបង្កបង្កើនផល ៣.០៩៧.៦៤៧ ហ.ត. ក្នុងនោះស្រូវសដូវវស្សា ២.៥៩៩.៥៨៦ហ.ត. និងស្រូវរដូវប្រាំង ៤៩៨.០៦១ហ.ត. លើសឆ្នាំមុន ៤៦.២៣៥ហ.ត. (ឆ្នាំមុនអនុវត្តបាន ៣.០៥១.៤១២ហ.ត.)។ ផ្ទៃដីប្រមូលផលសរុបអាចទទួលបាន ៣.០៧៩.៤៤៥ហ.ត.ក្នុងនោះស្រូវរដូវវស្សា ២.៥៨១.៤៤៥ ហ.ត. និងស្រូវរដូវប្រាំង ៤៩៨.០០០ហ.ត. លើសឆ្នាំមុន ៥៣.៨១៥ហ.ត. (ឆ្នាំមុន ៣.០២៥.៦៣០ហ.ត.)។ បរិមាណផលប៉ាន់ស្មានសរុប ៩.៨១៤.១៩៨តោន លើសឆ្នាំមុន ៤៧៨.៩១៤តោន (ឆ្នាំមុន ៩.៣៣៥.២៨៤តោន) និងទិន្នផលមធ្យមទូទាំងប្រទេស ៣,១៨៧តោន/ហ.ត. (ឆ្នាំមុន ៣,០៨៥ តោន/ហ.ត.)។ ដូច្នេះបើគិតពីតុល្យភាពស្បៀងរវាងសេចក្ដីត្រូវការ និងបរិមាណផលស្រូវទទួលបានឃើញថា អាចនៅសល់បរិមាណស្បៀងគិតជាស្រូវជាង ៤.៩៩៧.២០៥ តោន (ឆ្នាំមុនសម្រេចបាន ៤,៥លានតោន) និងគិតជាអង្ករប្រមាណជាង ៣.១៩៨.២១១តោន (ឆ្នាំមុនជាង ២,៩១លានតោន) សម្រាប់នាំចេញ។

- ក្នុងឆ្នាំ២០១៦ ការនាំចេញអង្ករមានបរិមាណ៥៤២.១៤៤តោន កើនឡើង ៣.៧៤៨តោន ស្មើនឹង ០,៧% បើធៀបនឹងឆ្នាំមុនមានបរិមាណនាំចេញត្រឹមតែ ៥៣៨.៣៩៦តោន។

- សរុបផ្ទៃដីចំការកៅស៊ូរដ្ឋ និងឯកជន ព្រមទាំងក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចំការកៅស៊ូគ្រួសារមានផ្ទៃដីអាជីវកម្ម ១២៦.៩៩៦ហ.ត. លើផ្ទៃដីចំការកៅស៊ូ ៤៣១.០៥៣ហ.ត. ផលិតផលអនុវត្តបាន ១២៧.៨៥២ តោន និងបញ្ចេញលក់ ១២៨.០១១តោន។ នៅដើមឆ្នាំ២០១៦ តម្លៃកៅស៊ូមានការធ្លាក់ចុះរហូតដល់ ១.០៤២ដុល្លារអាមេរិកក្នុង១តោនប៉ុន្តែចាប់ពីខែកញ្ញាឆ្នាំ២០១៦តម្លៃកៅស៊ូគិតជាមធ្យម ១.២៤៧ដុល្លារអាមេរិក ក្នុង១តោន។ នៅចុងឆ្នាំ២០១៦ តម្លៃកៅស៊ូកើនឡើងវិញ ក្នុងរង្វង់ ១.៧០៣ដុល្លារអាមេរិកក្នុង១តោន។

៣- ការងារវិនិយោគ: រាជរដ្ឋាភិបាលបានសម្រេចអនុញ្ញាតឲ្យក្រុមហ៊ុនធ្វើការវិនិយោគលើគម្រោងថ្មី និងពង្រីកផលិតកម្មលើគម្រោងចាស់ ដែលមានស្រាប់ ១៧១គម្រោង ដែលមានទុនវិនិយោគ ៣.៦០៩.៦៤៥.៨០៩ដុល្លារអាមេរិក និងអាចបង្កើតការងារបាន ១៦៤.៦៧៩កន្លែង។

ចំនួនគម្រោងវិនិយោគក្នុងឆ្នាំ២០១៦នេះ ថយចុះ ១០គម្រោង និងទំហំទុនវិនិយោគថយចុះ ២២% បើធៀបនឹងឆ្នាំមុន ក្នុងនោះវិស័យកសិកម្ម និងកសិឧស្សាហកម្មថយចុះ១% វិស័យឧស្សាហកម្ម និងកម្មន្តសាលកើនឡើង ២៩% វិស័យទេសចរណ៍កើនឡើង ១២,៥ដង និងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗទៀតថយចុះ ៨៣%។ ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេសវិញមានការកើនឡើងទាំងចំនួនគម្រោង និងទុនវិនិ-យោគ គឺកើនឡើង១៥គម្រោង និងទុនវិនិយោគកើនឡើងប្រមាណ ១៦៨ លានដុល្លារអាមេរិក។

៤- ដីធ្លី និងសំណង់: ផ្ដល់លិខិតអនុញ្ញាតសាងសង់ទូទាំងប្រទេស ២.៦៣៥គម្រោងមានផ្ទៃក្រឡាសំណង់សរុប ១២.១៥៨.២៦៨ម៉ែត្រការ៉ែ មានទុនវិនិយោគ ៥.៥៧៩.៧០៩.៩៨៩ដុល្លារអាមេរិក បើធៀបនឹងឆ្នាំមុនកើនឡើង ៦៧,១៥%។ ឬនៅរាជធានីភ្នំពេញ គិតពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៦ ស្ថិតនៅក្នុង១០ខណ្ឌ ក្នុងចំណោម១២ខណ្ឌ មាន១៤២ កន្លែង។ សំណង់អគារខ្ពស់ៗចាប់ពី ៥ជាន់ ទៅ៤០ ជាន់ឡើង ក្នុងរាជធានីភ្នំពេញមាន១៤២កន្លែង។

៥- ឧស្សាហកម្ម: រោងចក្របង្កើតថ្មីមាន១៤១រោងចក្រ បង្កើតការងារដល់ពលករ ៦២.៣១២ នាក់។ គិតត្រឹមដំណាច់ឆ្នាំ២០១៦នេះ រោងចក្រដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្មមាន ១.៥៧៩ និងប្រើប្រាស់ពលករសរុប ៩២១.៨៥៨នាក់ ក្នុងនោះផ្នែកឧស្សាហកម្ម តម្បាញ ចាក់ កាត់ដេរ ស្បែកជើង និងកាបូប មាន ១.០៧៩រោងចក្រ (រោងចក្រកាត់ដេរ និងចាក់មាន ៨២៤ និងមានពលករបម្រើការងារ ៧៩៨.៨១៥នាក់)។ មូលដ្ឋានឧស្សាហកម្មតូច និងសិប្បកម្មបង្កើតថ្មីមាន

ព្រះរាជាណាចក្រកម្ពុជា សំបូរទៅដោយរមណីដ្ឋានទេសចរណ៍ វប្ផធម៌ដ៏ទាក់ទាញបំផុតក្នុងពិភពលោក

៣១០មូលដ្ឋាន និងបង្កើតការងារថ្មីដល់ពលករ ៣.០០០នាក់។ គិតមកដល់ដំណាច់ឆ្នាំ២០១៦ នេះ មូលដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម នៅទូទាំងប្រទេសមាន ៣៩.១៤១មូលដ្ឋាន និងមានពល ករបម្រើការងារ ១៩៧.០៥៣នាក់។

៦- គមនាគមន៍: ផ្លូវជាតិ និងផ្លូវខេត្ត មកទល់បច្ចុប្បន្នសម្រេចស្ថាបនាបានប្រវែង ១៥.៣៧៦,២៤ គ.ម.ដែលចាក់កៅស៊ូ និងបេតុងហើយប្រវែង ៦.៩០១,៤៩គ.ម.(កើនឡើងប្រវែង២៧៨,៤១គ.ម.)ស្មើនឹង៤៤,៨៨% នៃប្រវែងសរុប។ គិតត្រឹមដំណាច់ឆ្នាំ២០១៦នេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានស្ពារ និងជួសជុល: កំណាត់ផ្លូវជាតិលេខ១ ពីគល់ស្ពានព្រះមុនីវង្ស ដល់វត្តក្តីតាកុយ រាជធានីភ្នំពេញ មានប្រវែង ៤គ.ម. សម្រេចបាន ៧០,១០%។ ផ្លូវជាតិលេខ៣ ពីកំចាយមារ ខេត្តព្រៃវែង ដល់ក្រុងស្វាយរៀង ខេត្តស្វាយរៀង មានប្រវែង ៦២,៤០គ.ម. សម្រេចបាន ៨៣,៣០%។ ផ្លូវជាតិលេខ២១ ដំណាក់កាលទី១ ពីរង្វង់មូលក្រុងតាខ្មៅ ដល់ជ្រៃធំខេត្តកណ្ដាលមានប្រវែង ៥៥គ.ម.ទទឹង ១០ម៉ែត្រដល់២១ម៉ែត្រ សម្រេចបាន ៣៨%។ កំណាត់ផ្លូវជាតិលេខ៥ ចាប់ពីស្ពានជ្រោយចង្វារ ដល់ស្ពានព្រែកក្តាមមានប្រវែង ៣០,៣៣គ.ម.ទទឹង២៥ម៉ែត្រមាន ៤គន្លង សម្រេចបាន ៩៧,២០%។ ផ្លូវជាតិលេខ៥៣ ផ្លូវខេត្តលេខ១៥០B និងផ្លូវខេត្តលេខ១៥១B ពីតាជេស ខេត្តកំពង់ឆ្នាំង ទៅអមលាំង ខេត្តកំពង់ស្ពឺ មានប្រវែង ៨៧,៩០គ.ម. សម្រេចបាន ៣៨,៥០%។ ផ្លូវជាតិលេខ ៥៥ ចាប់ពីចំណុចប្រសព្វនៃផ្លូវជាតិលេខ៥ (គ.ម. ១៩១) កាត់ស្រុកភ្នំក្រវាញ-ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដល់ច្រកទ្វារព្រំដែនថ្មដារ (ព្រំប្រទល់កម្ពុជា-ថៃ) មានប្រវែង ១៨២,១៦៦គ.ម. សម្រេចបាន ៦៨,៦១%។ ផ្លូវជាតិលេខ៥៨ ពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តមានជ័យ ប្រវែង ១៧៤,១៦គ.ម. សម្រេចបាន ៤៨,៩៧%។ កំណាត់ផ្លូវជាតិលេខ៦ ចាប់ពីថ្នល់កែង ស្រុកបាធាយ ខេត្តកំពង់ចាម ដល់ស្រុកបាគង ខេត្តសៀមរាប ប្រវែង២៤៨,៥២គ.ម. សម្រេចបាន ៩៨,១២%។ ស្ពានកោះធំ ប្រវែង ៤១៥ម៉ែត្រ សម្រេចបាន ១% ស្ពានជ្រៃកធំឆ្លងកាត់ទន្លេបាសាក់ ប្រវែង៤២៨គ.ម. ពីស្រុកកោះធំ ខេត្តកណ្ដាល (កម្ពុជា) ទៅស្រុកឡុងចិញ ខេត្តអាងយ៉ាង (វៀតណាម) សម្រេចបាន ៨៧,២៦%។ ស្ពានបេតុង (កំពង់ត្រុំ) មានប្រវែង ៧៧៩ម៉ែត្រ ឆ្លងកាត់ទន្លេមេគង្គ ពីក្រុងកំពង់ចាម ទៅឃុំកោះមិត្ត (កោះប៉ែន) ស្រុកកំពង់សៀម ខេត្តកំពង់ចាម សម្រេចបាន ៨២,៦០%។ ស្ពានអាកាសធ្យារដីហុយ មានប្រវែង ៩០៥ម៉ែត្រ ក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌសែន សុខ សម្រេចបាន ៣៥%។

- គិតពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៦ ការចុះបញ្ជីយានយន្តសរុប ៣.៦៦៩.៨២០ គ្រឿង ក្នុងនោះរថយន្ត ៥៣៧.៤៥៩គ្រឿង និងម៉ូតូ ៣.១៣២.៣៦១គ្រឿង។

- ក្រុមហ៊ុនអាកាសចរកម្ពុជាក្នុងប្រទេសមានចំនួន ៤ កំពុងហោះហើរ ធ្វើសកម្មភាពអាជីវកម្ម និងក្រុមហ៊ុនអាកាសចរអន្តរជាតិមានចំនួន ២៨។

៧- ធនធានទឹក: ជួសជុលសាងសង់ប្រព័ន្ធធារាសាស្ត្រនៅ ២៥ រាជធានីខេត្ត ដែលមានលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុប ៥៥.២១៣ហ.ត. ក្នុងនោះស្រូវរដូវវស្សា ៤០.៨៥០ហ.ត. ស្រូវរដូវប្រាំង ១៤.៣៦៣ហ.ត. ដំណាំរួមផ្សំ ៦១២ហ.ត. ការពារទឹកប្រៃ ១៧៥ហ.ត. ការពារទឹកជំនន់ ២៧៦,២២ហ.ត. និងការពារប្រាំងទន្លេ ១៨០ម៉ែត្រ។

៨- ទឹកស្អាត: បរិមាណផលិតទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកសាធារណៈ និងរដ្ឋាករទឹកឯកជន ទូទាំងប្រទេសផលិតបានសរុប ២៥៦.៤៨៩.៣៧៣ម៉ែត្រគូប។

៩- ថាមពល: ការផលិតថាមពលអគ្គិសនីក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាសម្រេចបាន ៦.២១៩.១៨០.៤៤៣Kwh បើធៀបនឹងឆ្នាំមុន ដែលមាន ៥.២៦៨.៤៩៦.៤១៦Kwh កើនឡើង១៨% ក្នុងនេះ ថាមពលបញ្ជូនពីវារីអគ្គិសនី និងរោងចក្រផលិតថាមពល ដើរដោយធ្យូងថ្ម សរុប ៤.៧៩១.៨៩៨.២០៨Kwh។ ការនាំចូលអគ្គិសនីពីវៀតណាមសម្រេចបាន ១.០២៣.៥០០.៧៧៣Kwh ថយចុះ ៣,៤៣% បើធៀបឆ្នាំមុន។ ការនាំចូលអគ្គិសនីពីប្រទេសថៃសម្រេចបាន ៧៩៣.៤៩២.៤៣៣.Kwh កើនឡើង ៤,៣៤% ធៀបឆ្នាំមុន។ ការនាំចូលអគ្គិសនីពីប្រទេសឡាវសម្រេចបាន ៣៦.៥២១.៣៤៥Kwh ធៀបឆ្នាំមុន កើនឡើង ១០៥,៩៧%។

១០- អភិវឌ្ឍន៍ជនបទ: ថៃទាំផ្លូវខួប ២៦គម្រោង លើគម្រោងឆ្នាំ២៨ គម្រោង ស្មើនឹង ៥៧ខ្សែ ប្រវែង ៤៨១,៣៨គ.ម. លទ្ធផលជាមធ្យមសម្រេចបាន ៨៥% នៅ២៥រាជធានីខេត្ត។ ថៃទាំផ្លូវប្រចាំ ២៤គម្រោង លើគម្រោងឆ្នាំ ៣១គម្រោង ស្មើនឹង ៩២ខ្សែ ប្រវែង ៩៨៩,៥៦គ.ម. លទ្ធផលជាមធ្យមសម្រេចបាន ៧៧% នៅ២៥រាជធានីខេត្ត។

១១- ពាណិជ្ជកម្ម: ក្នុងឆ្នាំ២០១៦នេះ ការនាំចេញមាន ៤០.៨៧២ ប៊ីលានរៀល និងការនាំចូលមាន ៥២.១៤៩,៥ ប៊ីលានរៀល។ ប្រតិបត្តិការជញ្ជីងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាមានឱនភាព ១១.២៧៧,៥ ប៊ីលានរៀល។

១២- ទេសចរណ៍: ភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាមានចំនួន ៥.០១១.៧១២នាក់ កើនឡើង ៥% ធៀបនឹងឆ្នាំ២០១៥។ គិតត្រឹមឆ្នាំ២០១៦ នេះ កម្ពុជាមានសណ្ឋាគារ ៧០៩ ស្មើនឹង ៤៤.១៦១ បន្ទប់

តទៅទំព័រទី ២៨

កំណើនប្រចាំឆ្នាំក្នុងវិស័យពាណិជ្ជកម្មធ្វើឲ្យការប្រមូលចំណូលថវិកាជាតិក្នុងវិស័យនេះបានកើនឡើង

ពិធីតាំងពិពណ៌ពាណិជ្ជកម្មនៅខេត្តកំពង់ចាម

វិស័យពាណិជ្ជកម្ម គឺជាគំនាស់មួយដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចការ អភិវឌ្ឍសង្គម និងការប្រមូលចំណូលចូលថវិកាជាតិ។ ជាក់ស្ដែងក្នុងឆ្នាំ២០១៦ កន្លងមកនេះ ទំហំពាណិជ្ជកម្មកម្ពុជាកើនឡើងលើសឆ្នាំមុន ហើយក្រសួងពាណិជ្ជកម្មបានប្រមូលចំណូលចូលថវិកាជាតិបានជាង២០០ ពាន់លានរៀល ។ នេះជាមោទនភាពមួយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ ដឹកនាំដោយ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានធ្វើឲ្យប្រទេសជាតិឈានដល់ដំណាក់កាលមួយដែលសេដ្ឋកិច្ចកាន់តែមានភាពរឹងមាំឆ្ពោះ ទៅសម្រេចគោលដៅធំៗក្នុងការអភិវឌ្ឍប្រទេស។

តាមរបាយការណ៍ក្រសួងពាណិជ្ជកម្មបានអោយដឹងថា ការដោះដូរទំនិញរបស់កម្ពុជាក្នុងឆ្នាំ២០១៦ សម្រេចបានទឹកប្រាក់ជាង ២០ ប៊ីលានដុល្លារ ដោយមានកំណើនជាង ៧ % បើធៀបនឹងការនាំចេញ-នាំចូលក្នុងឆ្នាំ២០១៥ ដែលមានតម្លៃជាង ១៨ ប៊ីលានដុល្លារ។ ក្នុងឆ្នាំកន្លងទៅកម្ពុជាបានអនុញ្ញាតឲ្យមានការនាំចូលទំនិញ និងផលិតផលសំខាន់ៗគិតជាទឹកប្រាក់សរុបជិត ១១ ប៊ីលានដុល្លារ កើនឡើងជាង ៧ % បើធៀបនឹងឆ្នាំ២០១៥ មានត្រឹមជាង ១០ ប៊ីលានដុល្លារតែប៉ុណ្ណោះ។ ផលិតផលដែលកម្ពុជាធ្វើការនាំចូលមានជាអាទិ៍៖ រថយន្តគ្រឿងចក្រកសិកម្ម គ្រឿងបន្លាស់ប្រេងឥន្ធនៈ គ្រឿងអេឡិចត្រូនិក និងអគ្គិសនី វត្ថុធាតុដើម បម្រើក្នុងវិស័យឧស្សាហកម្មកាត់ដេរ ឱសថនិងសម្ភារៈបរិក្ខារពេទ្យ ម្ហូបអាហារ ភេសជ្ជៈ សម្ភារៈ និងរបស់របរប្រើប្រាស់ប្រចាំថ្ងៃជាច្រើនមុនទៀត។

ដោយឡែកទំហំនៃការនាំចេញរបស់កម្ពុជា ក្នុងរយៈពេលដូចគ្នានេះ សម្រេចបានក្នុងទឹកប្រាក់ជិត ៩ ប៊ីលានដុល្លារ ដោយមានកំណើន ៨ % បើធៀបនឹងការនាំចេញកាលពីឆ្នាំ២០១៥ ដែលមានទឹកប្រាក់ត្រឹមជាង ៨ ប៊ីលានដុល្លារ។ ផលិតផលសំខាន់ៗរបស់កម្ពុជា ដែលបាននាំចេញមានដូចជា៖ សម្លៀកបំពាក់ ស្បែកជើង កង់ អង្ករ ម្រេច ជ័រកៅស៊ូ ពោតចំណិតដំឡូងមីគ្រឿងបង្អុំរថយន្ត។ល។ ទីផ្សាររបស់កម្ពុជាមាន៖ សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក ចិន ជប៉ុន កូរ៉េខាងត្បូ សហគមន៍អាស៊ាន ជាដើម។ ក្រសួងពាណិជ្ជកម្មបានឲ្យដឹងថា ជប៉ុនគឺជាវិនិយោគិនធំជាងគេដែលបានបោះទុនវិនិយោគនៅតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា (SEZ) ចំនួនទឹកប្រាក់ជិត៣០០ លានដុល្លារអាមេរិកបន្ទាប់មកគឺចិនជិត២០០ លានដុល្លារអាមេរិក កោះតៃវ៉ាន់ជាង ១០០ លានដុល្លារអាមេរិក សឹង្ហបូរីជាង ១០០ លានដុល្លារអាមេរិក កូរ៉េខាងត្បូងជិត ៦០ លានដុល្លារអាមេរិក និងថៃជាង៥០ លានដុល្លារអាមេរិក។ ដោយឡែកទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជា-អាមេរិក ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ មានការកើនឡើងពី ៣.០១២,៤លានដុល្លារ ដល់ ៣.១៧៤,៣លានដុល្លារ ដែលក្នុងនោះ ទំហំនៃការនាំចេញទំនិញពីកម្ពុជាទៅសហរដ្ឋអាមេរិក មានការកើនឡើងពី ២ ៧៧១.២០លានដុល្លារ ដល់ ២.៨១២,៥ លានដុល្លារ។

ក្នុងឆ្នាំ២០១៦ កន្លងមកនេះ ក្រសួងពាណិជ្ជកម្មបានរៀបចំ និងចូលរួមការតាំងពិព័រណ៍ក្រៅ ប្រទេសបានជាង៣០ លើក និងសម្របសម្រួលរៀបចំព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេសជាង១០០ លើក។ ចំពោះការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្រៅវិញ ប្រទេសកម្ពុជាបានចូលរួមពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ីខាងត្បូងលើកទី៤ ពិព័រណ៍ពាណិជ្ជកម្មផលិតផលនាំចេញ-នាំចូល គុនមីញចិនលើកទី២៤ នៅទីក្រុងគុនមិញ និងចូលរួមពិព័រណ៍ចិន-អាស៊ានលើកទី១៣ នៅទីក្រុងណាននីងប្រទេសចិន។ នៅក្នុងឱកាសពិព័រណ៍នោះ ក្រុមហ៊ុនវិនិយោគកម្ពុជា និងចិនបានចុះហត្ថលេខាលើលិខិតផ្ទាស់ប្តូរស្តីពីការវិនិយោគរួមគ្នារវាងធនាគារ BeibuGulf ខេត្តក្វាងស៊ី ជាមួយធនាគារកាណាឌីយ៉ា ហើយនៅពេលចប់ពិព័រណ៍ គណៈកម្មការរៀបចំពិព័រណ៍ បានផ្ដល់ពានរង្វាន់ដល់កម្ពុជាចំនួន៣ គឺពានរង្វាន់ល្អប្រសើរលើការរៀបចំអ្នកស្វែងរកដៃគូធ្វើធុរកិច្ច ពានរង្វាន់ល្អប្រសើរលើការរៀបចំពន្លាជាតិ និងពានរង្វាន់ល្អប្រសើរស្តីពីការជំរុញសហប្រតិបត្តិការវិនិយោគ។ ដោយឡែកការរៀបចំពិព័រណ៍ និងព្រឹត្តិការណ៍ពាណិជ្ជកម្មក្នុងស្រុកក្នុងឆ្នាំ ២០១៦ កន្លងមកនេះ ក្រសួងពាណិជ្ជកម្មបានរៀបចំយុទ្ធនាការទិញផលិតផលខ្មែរក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយបានរៀបចំនៅខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។ គោលបំណងនៃការរៀបចំយុទ្ធនាការទិញផលិតផលខ្មែរ គឺដើម្បីពញ្ញាក់ស្មារតីអ្នកប្រើប្រាស់ឲ្យងាកមកប្រើប្រាស់ទំនិញក្នុងស្រុក កាត់បន្ថយការនាំចូលទំនិញពីបរទេសនិងជំរុញការនាំចេញ។

ឯកឧត្តម **ម៉ាន សូរស័ក្ដិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានថ្លែងក្នុងសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ ថា ដើម្បីជំរុញកំណើនទំហំពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្មបាន និងកំពុងធ្វើកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ជាមួយបណ្ដាប្រទេសជាមិត្ត ទាំងក្នុងក្របខណ្ឌអាស៊ាន អនុតំបន់ និងទ្វេភាគី។ លើសពីនេះ ក្រសួងបានបង្កើតនាយកដ្ឋានថ្មីៗដូចជា នាយកដ្ឋានអាមេរិក នាយកដ្ឋានអឺរ៉ុប-

មជ្ឈឹមបូព៌ា-អាហ្វ្រិក ដែលបាននិងកំពុងធ្វើការយ៉ាងសកម្មក្នុងការជំរុញប្រតិបត្តិការពាណិជ្ជកម្ម និងពង្រីកទីផ្សារថ្មីៗជាមួយបណ្ដាប្រទេសនៅទ្វីបទាំងនោះផងដែរ។ ជាមួយគ្នានេះ ដើម្បីធានាដល់ការអភិវឌ្ឍវិស័យឯកជននៅកម្ពុជាក្រសួងពាណិជ្ជកម្មបានដាក់ឲ្យអនុវត្តន៍នូវប្រព័ន្ធស្វ័យប្រវត្តិកម្មសំខាន់ៗ ដើម្បីលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច បង្កភាពងាយស្រួលដល់ធុរជន និងវិនិយោគិនក្នុងការធ្វើប្រតិបត្តិការអាជីវ-កម្មនៅក្នុងប្រទេស ។ ក្រសួងកំពុងសិក្សាស្រាវជ្រាវ និងអភិវឌ្ឍខ្សែចង្វាក់តម្លៃសម្រាប់ផលិតផលក្នុងស្រុកមួយចំនួន ដែលមានសក្តានុពលនាំចេញ ដូចជា សូត្រ អំពៅ ស្វាយ ចេក ស្ករស ស្ករត្នោត ថ្មចម្លាក់ និងផ្កាចំបី ។ល។ ដោយឡែកចំពោះផលិតផលស្រូវ សូត្រ ក្រសួងបានបញ្ចប់ឯកសារស្រាវជ្រាវស្ដីពីការជំរុញ និងអភិវឌ្ឍវិស័យសូត្រកម្ពុជាជាស្ថាពរ ។

តាមរបាយការណ៍បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០១៦ បានអោយដឹងថាឆ្នាំ២០១៦ មានក្រុមហ៊ុនថ្មី ២៩៣៧ ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា ដែលតួលេខនេះបានធ្លាក់ចុះ ២៦% បើធៀបនឹងឆ្នាំ២០១៥។ នៅឆ្នាំ២០១៦ ការចុះបញ្ជីថ្មីសម្រាប់សហគ្រាសឯកបុគ្គលមានចំនួន៧៨៦ សហគ្រាសថយចុះ ៤០ % ខណៈសហគ្រាស ឯកបុគ្គលចំនួន១ ត្រូវបានលុបឈ្មោះចេញ ពីបញ្ជីពាណិជ្ជកម្ម។ នៅឆ្នាំ២០១៦ មានក្រុមហ៊ុនចំនួន១០.៩០៤ ក្រុមហ៊ុន និង១.២៤១ សហគ្រាសបានធ្វើការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញ។

ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនាំចេញ នាំចូល និងគាំទ្រដល់ផលិតផល និងទំនិញផលិតក្នុងស្រុកឱ្យបានកាន់តែប្រសើរឡើងនោះ ឯកឧត្តម **ប៉ាន សូរស័ក្តិ** អះអាងថា ក្រសួងចាំជួយដោះស្រាយគ្រប់ពេលវេលាដល់កសិករ ពាណិជ្ជករ និងផលិតករ ទាក់ទងនឹង បញ្ហាទីផ្សារលក់ផលិតផលក្នុងស្រុក និងការនាំចេញទៅក្រៅប្រទេស។ ឯកឧត្តមបានបញ្ជាក់ថា កន្លងមក ការនាំចេញតែងតែមានបញ្ហាដោយសារតែបងប្អូនប្រជាពលរដ្ឋ ដែលជាអ្នកផលិតនៅមិនទាន់យល់ដឹងអំពីតម្រូវការពីបណ្ដាប្រទេសផ្សេងៗ ដែលចាំបាច់ត្រូវការរៀនសូត្រផ្លាស់ប្ដូរបទពិសោធន៍ និងទំនាក់ទំនងពីគ្នាទៅវិញទៅមក ដើម្បីឱ្យផលិតផល និងទំនិញកម្ពុជាកាន់តែមានការវិវត្តជាបន្តបន្ទាប់ ដើម្បីបានការទទួលស្គាល់ និងកម្រិតស្តង់ដារខ្ពស់។ ទន្ទឹមនឹងនេះពីមួយឆ្នាំទៅមួយឆ្នាំ យើងនឹងបន្តខិតខំប្រឹងប្រែងឱ្យផលិតផលខ្មែរមានគុណភាព និងបរិមាណកាន់តែច្រើនឡើងទាំងការវេចខ្ចប់ សោភ័ណភាពក្នុងការទាក់ទាញ ពិសេសតាមរយៈព្រឹត្តិការណ៍ពាណិជ្ជកម្មនេះនឹងធ្វើឱ្យអ្នកប្រើប្រាស់កាន់តែបានស្គាល់និងគាំទ្រផលិតផលទំនិញក្នុងស្រុកថែមទៀត។

នៅឯកិច្ចប្រជុំកំពូលធុរកិច្ចកម្ពុជាឆ្នាំ ២០១៧ កាលពីល្ងាចថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានគូសបញ្ជាក់ថា "ទោះបីប្រទេសកម្ពុជាតូច ប៉ុន្តែការដាក់ចេញគោលនយោបាយ និងចក្ខុវិស័យច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់អត្ថប្រយោជន៍គ្មានគូប្រៀបជាងប្រទេសដទៃ នៅក្នុងតំបន់។ ទាំងវិនិ-យោគិនបរទេស និងក្នុងស្រុក ពួកគេនឹងទទួលបាននូវការគាំពារស្មើភាពគ្នា នៅក្រោមច្បាប់វិនិយោគរបស់យើង"។ ឯកឧត្តម **ប៉ាន សូរស័ក្តិ** បានបន្ថែមទៀតថា "ជាមួយកម្លាំងពលកម្មវ័យក្មេងពោរពេញដោយថាមពល, ធនធានធម្មជាតិសម្បូរបែប, ការគាំទ្រធុរកិច្ច ពីរាជរដ្ឋាភិបាល, ទីតាំងភូមិសាស្ត្រ មានលក្ខណៈយុទ្ធសាស្ត្រ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មពិសេសៗ ជាមួយដៃគូប្រទេសធំៗ និងនៅក្នុងតំបន់ កម្ពុជាគឺជាទីកន្លែងដ៏ប្រសើរសម្រាប់វិនិយោគ និងធ្វើធុរកិច្ច"។ អនុលោមតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ឆ្នាំ២០១៥-២០២៥ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវក្របខណ្ឌការងារយុទ្ធសាស្ត្រថ្មី ដើម្បីអភិវឌ្ឍន៍វិស័យឧស្សាហកម្មសំដៅធ្វើពិពិធកម្មកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជា។

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា ដើម្បីជាធាតុចូលសម្រាប់អនុវត្តការងារនៅក្នុងឆ្នាំ២០១៧ ខាងមុខ ក្រសួងពាណិជ្ជ-កម្មនឹងបំពេញការងារសំខាន់ៗ ជាច្រើននៅក្នុងកិច្ចការរបស់ខ្លួនដែលបានប្រគល់ជូនដោយរាជរដ្ឋាភិបាល។ ឯកឧត្តមរដ្ឋមន្ត្រីបានផ្ដល់អនុសាសន៍ដល់មន្ត្រីទាំងអស់ត្រូវខិតខំប្រឹងប្រែង បន្ថយពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យកាន់តែខ្លាំងថែមទៀតជាពិសេសលើជំនាញភាសាអង់គ្លេស និងព័ត៌មានវិទ្យាដែលជាជំនាញចាំបាច់បំផុតក្នុងការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ។ ត្រូវពង្រឹងថែមទៀតក្នុងការងារបង្កើតសមាគមនានា ដើម្បីជួយជំរុញផលិតផលកម្ពុជាឱ្យមានទីផ្សារ និងគុណភាពខ្ពស់ដើម្បីប្រកួតប្រជែងជាមួយនឹងផលិតផលបរទេស។ ភ្ជាប់នឹងការងារនេះដែរ ការតាំងពិព័រណ៍ផលិតផលនានាទាំងក្នុង និងក្រៅប្រទេសត្រូវតែបន្តធ្វើឱ្យបានច្រើនជាការផ្សព្វផ្សាយ និងជំរុញផលិតផលក្នុងស្រុកលើកស្ទួយផលិតផលខ្មែរ និងស្វែងរកទីផ្សារបន្ថែមសម្រាប់ផលិតផលអាទិភាពរបស់កម្ពុជា។ ជាមួយនឹងការស្វែងរកទីផ្សារថ្មីៗ ក្រសួងពាណិជ្ជកម្មក៏កំពុងតែពិភាក្សាជាមួយប្រទេសមួយចំនួនបន្ថែមទៀត ដូចជាសហភាព សេដ្ឋកិច្ចអឺរ៉ុប-អាស៊ី តួកគី បេឡារុស ជាដើម ដើម្បីធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ ក្រសួងក៏បានដាក់ចេញនូវផែនការថ្មីៗសម្រាប់ឆ្នាំ២០១៧ ដើម្បីជំរុញការ អភិវឌ្ឍវិស័យពាណិជ្ជកម្មរបស់កម្ពុជា សំដៅរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖

សកម្មភាពលើកដាក់ទំនិញនាំចេញនាំចូលនៅកំពង់ផែ ខេត្តព្រះសីហនុ

ពង្រឹងវិស័យព័ត៌មាន ដោយខិតខំពង្រីកវិសាលភាព គុណភាពនិងប្រសិទ្ធភាពនៃការផ្សព្វផ្សាយ

*ឯកឧត្តម **ខៀវ ភាណារ៉ា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានណែនាំឲ្យមន្ត្រីព័ត៌មានបំពេញភារកិច្ចឲ្យវិស័យព័ត៌មាន និងសោតទស្សន៍កាន់តែមានការរីកចម្រើន*

ឆ្នាំ២០១៦ កន្លងទៅជាឆ្នាំដែលមានទាំងភាពអនុគ្រោះ ទាំងបញ្ហាប្រឈមផង តែភាពអនុគ្រោះមានភាពលើសលប់ ដោយផ្អែកលើមូលដ្ឋានសមិទ្ធផលធំៗដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបានពេញមួយឆ្នាំកន្លងទៅនេះ។ ជាក់ស្តែងខឿនការពារប្រទេស និងសន្តិសុខជាតិត្រូវបានពង្រឹងដែលបានលើកកម្ពស់សមត្ថភាពនៃកិច្ចការការពារជាតិការពារអធិបតេយ្យ និងបូរណភាពទឹកដីនៃមាតុភូមិ ធានាបានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងភាពសុខដុមរមនារបស់ប្រជាជនយើង។ តាមរយៈនេះពង្រីកផ្តល់ភាព អនុគ្រោះដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក៏ដូចជាការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យដោយដើរទន្ទឹមនិងការអនុវត្តនីតិរដ្ឋ។

ជោគជ័យនិងសមិទ្ធផលដ៏ធំធេងទាំងអស់នេះត្រូវបានក្រសួងព័ត៌មានដែលមានប្រព័ន្ធផ្សព្វផ្សាយទាំង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងរដ្ឋ និងឯកជន ធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយប្រកបដោយស្មារតីទទួលខុសត្រូវ និងការច្នៃប្រឌិតខ្ពស់ ធ្វើឲ្យប្រជាជនគ្រប់មជ្ឈដ្ឋានទាំងនៅក្នុងប្រទេស និងក្រៅប្រទេសបាន យល់ដឹងច្បាស់ជាក់ច្បាស់ពីព័ត៌មានពិតគ្រប់វិស័យ និងទទួលបាននូវចំណេះដឹង ការអប់រំ ការកំសាន្តសប្បាយ ប្រកបដោយសមធម៌ និងគុណធម៌។ បច្ចុប្បន្ននេះ ដោយសារការជឿនលឿននៃបច្ចេកវិទ្យា ការយល់ដឹងកាន់តែច្រើនរបស់ប្រជាជនគ្រប់ស្រទាប់ក្នុងសង្គមជាតិយើងបានតម្រូវឲ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន ត្រូវខិតខំពង្រឹងពង្រីកវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃការផ្សាយរបស់ខ្លួនឲ្យកាន់តែមានលក្ខណៈជ្រាលជ្រៅ គ្រប់ជ្រុងជ្រោយ និងប្រជាប្រិយភាពប្រកួតប្រជែងលើទីផ្សារក្នុងសេវាផ្តល់ព័ត៌មាន សព្វបែបយ៉ាង ជូនប្រជាជនគ្រប់ទិសទី។ ជាការពិតហើយ ទោះបីប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋមិនទាន់មានសម្ភារៈបំពាក់គ្រប់គ្រាន់ក្តី ប៉ុន្តែយើងបានធ្វើការផ្សព្វផ្សាយប្រទាក់ក្រឡាគ្នា ធ្វើឲ្យវិសាលភាពនៃការផ្សព្វផ្សាយគ្របដណ្តប់ទូទាំងប្រទេស និងផ្សាយចេញទៅបរទេសថែមទៀត។ ចំណុចពិសេសមួយ គឺផ្តោតការយកចិត្តទុកដាក់ទៅលើការកែទម្រង់ទាំងរូបភាព ទាំងខ្លឹមសារ ទាំងការងារគ្រប់គ្រង និងរបៀបរបបការងារ យកចិត្តទុកដាក់ជាមួយនឹងមន្ត្រីចាស់ លើកទឹកចិត្តមន្ត្រីវ័យក្មេង ដោយខិតខំពង្រឹងឆន្ទៈការងារមន្ត្រីទាំងអស់ពិសេសមន្ត្រីដឹកនាំបន្តវេនៅគ្រប់ផ្នែកគ្រប់កម្រិត។

នៅក្នុងរបាយការណ៍នៃសន្និបាតបូកសរុបសមិទ្ធផលវិស័យព័ត៌មាន និងសោតទស្សន៍ឆ្នាំ២០១៦ និងទិសដៅការងារសម្រាប់ការអនុវត្តឆ្នាំ២០១៧ របស់ក្រសួងព័ត៌មានបានបញ្ជាក់ច្បាស់ថា ពេញមួយឆ្នាំ ២០១៦ កន្លងទៅនេះថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់ផ្នែកគ្រប់មុខជំនាញបានសាមគ្គីគ្នាបំពេញភារកិច្ចរៀងៗខ្លួនធ្វើឲ្យវិស័យព័ត៌មាន និងសោតទស្សន៍ និងវិស័យមួយចំនួនទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទទួលបានលទ្ធផលល្អតាមទិសដៅ ដែលបានដាក់ចេញស្របតាមផែនការអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មគឺ «ពង្រីកវិសាលភាព គុណភាព និងប្រសិទ្ធភាព នៃប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិគ្របដណ្តប់បានទូលំទូលាយ ទាំងនៅក្នុងប្រទេសក្នុងតំបន់ និងទ្វីបនានា.....»។ របាយការណ៍នេះក៏បានវាយ តម្លៃខ្ពស់ចំពោះបណ្តាញផ្សព្វផ្សាយឯកជន ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការផ្តល់ព័ត៌មាន ផ្តល់ចំណេះដឹង ការអប់រំ និងការកំសាន្តសប្បាយជូនប្រជាជននៅគ្រប់ទិសទីនៃមាតុភូមិ។ បណ្តាញផ្សព្វផ្សាយឯកជន មួយចំនួនបានសហការជាមួយបណ្តាញផ្សព្វផ្សាយរដ្ឋ ក្នុងការផ្សព្វផ្សាយផ្ទាល់ពីព្រឹត្តិការណ៍ធំៗរបស់ជាតិបាន យ៉ាងល្អប្រសើរ។ នៅឆ្នាំ២០១៦ នេះ ប្រព័ន្ធផ្សព្វផ្សាយដែលមានអាជ្ញាប័ណ្ណ គឺវិទ្យុផ្សាយផ្ទាល់នៅភ្នំពេញមាន ៧៧ នៅតាមខេត្តមាន១៧០ វិទ្យុផ្សាយបន្តនៅភ្នំពេញមាន៣ នៅខេត្ត៨៦ ទូរទស្សន៍ផ្សាយផ្ទាល់ នៅភ្នំពេញ មាន២២ នៅខេត្តមាន៨ ទូរទស្សន៍ផ្សាយបន្តនៅខេត្តមាន៦៤ ទូរទស្សន៍ខ្សែកាបនៅភ្នំពេញមាន២ នៅខេត្តមាន១៤៣ ទូរទស្សន៍ផ្សាយតាមប្រព័ន្ធផ្សេងៗនៅភ្នំពេញមាន២៤ កាសែតជាតិនៅភ្នំពេញមាន៣៥៨ នៅខេត្ត មាន១២៨ កាសែតអន្តរជាតិ នៅភ្នំពេញមាន៤១ នៅខេត្តមាន១ ទស្សនាវដ្ដីជាតិនៅភ្នំពេញមាន ២៣៣ នៅខេត្តមាន៨ ទស្សនាវដ្ដីអន្តរជាតិនៅភ្នំពេញមាន៥៧ នៅខេត្តមាន៣។ សមាគមន៍អ្នកសារព័ត៌មាន វិទ្យុ-ទូរទស្សន៍ នៅភ្នំពេញមាន៣៥ នៅខេត្ត មាន៥ រោងពុម្ព និងគ្រឹះស្ថានបោះពុម្ពនៅភ្នំពេញមាន១២៤ គេហទំព័រនៅភ្នំពេញមាន៨៨ នៅខេត្តមាន២៧។

ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់គឺ ការកើនឡើងនៃអ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ជាពិសេស Facebook ដែលបានក្លាយជាមធ្យោបាយទាក់ទងគ្នាយ៉ាងពេញនិយមតាមរយៈប្រព័ន្ធអេឡិចត្រូនិចនានា។ គេអាចទំនាក់ទំនងគ្នាជាសារ ជាអក្សរ ជាសំឡេង ជារូបថត ជារូបភាពវីដេអូ ដើម្បីផ្តល់ដំណឹងដល់គ្នា សួរសុខ ទុក្ខគ្នា ចែករំលែកបទពិសោធន៍ចំណេះដឹងឲ្យគ្នាទៅវិញទៅមកជាលក្ខណៈសាធារណៈ ជាលក្ខណៈមិត្តភក្តិ និងជាលក្ខណៈផ្ទាល់ខ្លួនតែ២នាក់ ឬជាលក្ខណៈក្រុម។ ប៉ុន្តែទិន្នន័យដែលបញ្ជូនមកតាមបណ្តាញទំនាក់ទំនងសង្គម នេះមិនមែនសុទ្ធតែត្រឹមត្រូវទាំងអស់នោះទេ ហើយក៏គ្មានការទទួលខុសត្រូវណាមួយជាក់លាក់ដែរ។ ការ ទទួលខុសត្រូវតែមួយគត់ គឺបើអ្នកលេង Facebook និយាយប៉ះពាល់ដល់អ្នកដទៃ (បរិហារកេរ្តិ៍) នោះនឹងត្រូវគេប្តឹង និងមានទោសតាមច្បាប់ជាធរមាន។ Facebook ប្រៀបបាននឹងសារព័ត៌មានប្រជាជន ដែលផលិតចេញពីប្រជាជននូវបញ្ហាទាំងឡាយដែលនៅជុំវិញខ្លួន ដែលសារព័ត៌មាន

ផ្សេងៗទៀតមិនបានដឹង។ ប្រជាជនទូទៅមិនបានយល់ពីវិជ្ជាជីវៈសារព័ត៌មានទេ។ ការផលិតព័ត៌មានយកមកផ្សាយ គឺផុសចេញពីអារម្មណ៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ដើម្បីរួមចំណែកចង់ឲ្យគេដឹង និងឲ្យគេដោះស្រាយ។ ដូច្នេះអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមត្រូវពិចារណាថា តើចង់ដោះស្រាយបញ្ហាពិតប្រាកដ ឬចង់បង្កបញ្ហាឲ្យមានជម្លោះបែកផ្សែងនៅក្នុងសង្គម Facebook។ ក្រសួងព័ត៌មានបានបញ្ជាក់ច្បាស់ថា ព័ត៌មាននៅក្នុងបណ្ដាញទំនាក់ទំនងសង្គមពិតជាត្រូវភ្ជាប់ជាមួយការទទួលខុសត្រូវចំពោះសង្គមក៏ដូចជាចំពោះមុខច្បាប់ជាធរមាន ។ អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងអស់គ្នាត្រូវមានសីលធម៌ មានសេចក្ដីថ្លៃថ្នូរ ជៀសវាងការប្រើពាក្យសម្ដីអសុរស អសីលធម៌ ប្រើ រូបភាពកាត់តប្រមាថមើលងាយ ញុះញង់ ធ្វើឲ្យសង្គមជាតិយើងបែកបាក់ប្រេះឆាឡើងវិញ។

ជារួមក្នុងឆ្នាំ២០១៦ កន្លងទៅនេះ ក្រសួងព័ត៌មាន សម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងនោះ គឺការធ្វើកំណែទម្រង់ទាំងខ្លឹមសារនៃការផ្សព្វផ្សាយ ទាំងលើការងារដឹកនាំគ្រប់គ្រង ពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីកែលម្អ និងពង្រឹងការងារដឹកនាំ និងគ្រប់គ្រងក្នុងវិស័យព័ត៌មាន និងសោតទស្សន៍ឲ្យកាន់តែមានប្រសិទ្ធ-ភាពថែមទៀត។

ជាមួយនឹងការរីកចម្រើននេះ ក៏នៅមានការខ្វះខាតមួយចំនួនទៀតដែលតម្រូវឲ្យធ្វើការកែប្រែ ដើម្បីឈានទៅដណ្ដើមទីផ្សារ ក្នុងស្ថានភាពដែលមន្ត្រីយើងនៅមានកម្រិតថវិកាស្ដួចស្ដើង និងទម្លាប់ចាស់ជាច្រើនមិនទាន់ត្រូវបានកែប្រែដូចជា: ទម្លាប់ធ្វើការដាច់ពីគ្នារវាងអគ្គនាយកដ្ឋាននឹងអគ្គនាយកដ្ឋាន ដោយមិនមានអារម្មណ៍ថាយើងជាអង្គភាពតែមួយដែលត្រូវគាំទ្រគ្នាទៅវិញទៅមក។ ទម្លាប់ធ្វើការដាច់ពីគ្នារវាងនាយកដ្ឋាននឹងនាយកដ្ឋានក្នុងអគ្គនាយកដ្ឋានតែមួយ។ ការមិនទទួលយកយោបល់ពីគ្នាដើម្បីផលប្រយោជន៍រួម។ រូបភាពជាអង្គភាពដែលផ្សាយដំណឹងផ្ទូមមិនទាន់បានត្រូវបានជម្រះចេញពីសតិអារម្មណ៍អ្នកផង។ យើងមានអ្នកយកព័ត៌មានដើរតាមរដ្ឋមន្ត្រីច្រើនជាងអ្នកយកពត៌មានពីបញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ច។ ការស្វះស្វែងបង្កើតកម្មវិធីថ្មី ឬឃ្លីចយកកម្មវិធីដែលជាចំណុចក្ដៅនៃបច្ចុប្បន្នភាពនៅមានភាពទន់ខ្សោយ។ ក្នុងសម័យកាលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ យើងមិនទាន់ចេះប្រើមធ្យោបាយដែលមានទាំងអស់ទេគឺធ្វើសកម្មភាពជា មុខស្ម មិនធ្វើជាមុខច្ស្ងក។ ប៉ុន្តែអ្វីដែលជាបញ្ហាប្រឈមសំខាន់បំផុតនោះ គឺកង្វះធនធានមនុស្ស ដើម្បីបន្តវេន និងកង្វះមធ្យោបាយសម្ភារៈ និងថវិកាសម្រាប់ដំណើរការ។

ទិសដៅរបស់ក្រសួងព័ត៌មានសម្រាប់ឆ្នាំ២០១៧ គឺបន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹក ចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឲ្យខិតខំពង្រីកសក្តានុពល ប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយគ្របដណ្ដប់ឲ្យបានទូលាយទាំងក្នុងប្រទេស ទាំងក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្ដល់ពត៌មានការអប់រំ និងការកំសាន្តសប្បាយ ប្រកបដោយគុណភាព សមធម៌ជូនប្រជាជនកម្ពុជានៅគ្រប់ច្រកល្ហកនៃមាតុប្រទេស និងឆ្ពោះទៅកាន់ពិភពលោកខាងក្រៅ រួមចំណែកលើកតម្កើងអត្តសញ្ញាណជាតិ មោទនភាពជាតិខ្មែរ និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ។ កសាងផែនការទំនើបកម្មមូលដ្ឋាន សម្ភារៈបច្ចេកទេសសម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ ជាតិដើម្បីឆ្លើយតបទៅនឹងសំណូមពរចាំបាច់នៃវិទ្យុជាតិ ទូរទស្សន៍ជាតិ និងទីភ្នាក់ងារសារពត៌មានកម្ពុជា ដែលជាសម្លេងផ្លូវការរបស់ជាតិ។ បន្តជំរុញការសាងសង់ស្ថានីយវិទ្យុ និងទូរទស្សន៍ថ្នាក់ក្រោមជាតិ តាមខេត្តមួយចំនួនទៀតដោយផ្ដល់អាទិភាពចំពោះបណ្ដាខេត្តនៅប៉ែកពាយ័ព្យ និងឦសាន្តនៃមាតុប្រទេស។ បើកវគ្គវិក្រឹតការដល់មន្ត្រីគ្រប់ផ្នែក គ្រប់ជំនាញ ដើម្បីបង្កើនសមត្ថភាពតាមឲ្យទាន់សភាពការណ៍រីក-ចម្រើននៃប្រទេសជាតិលើគ្រប់វិស័យ ជាពិសេសវិស័យបច្ចេកវិទ្យាព័ត៌មានទំនើប។ ពង្រឹងការអនុវត្តច្បាប់ស្ដីពីរបបសារព័ត៌មានកម្ពុជា និងក្រមសីល-ធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ដោយធានាឲ្យបាននូវសិទ្ធិសេរីភាព នៃការបញ្ចេញមតិសេរីភាព សារព័ត៌មានតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ។ ឯកឧត្តម **ខៀវ ភាណារ៉ា** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានវាយតម្លៃខ្ពស់ចំពោះមន្ត្រីព័ត៌មានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានខិតខំធ្វើការងារតាមជំនាញរៀងៗខ្លួន ប្រកបដោយការទទួលខុសត្រូវ និងផ្ទៃប្រឈិតខ្ពស់ ទោះជាត្រូវប្រឈមបញ្ហាធ្ងន់ធ្ងរមួយចំនួនដូចជាកង្វះធនធានមនុស្ស ថវិកាខ្សត់ខ្សោយ មូលដ្ឋានបច្ចេកទេសមានការខ្វះ-ខាតយ៉ាងណាក៏ដោយ តែការងារផ្សព្វផ្សាយបានដំណើរការល្អជាបង្ហូរ។ គួបផ្សំនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងការចូលរួមចំណែករបស់វិស័យឯកជនផងនោះ យើងអាចនិយាយបានថា មកទល់បច្ចុប្បន្ននេះ ពលរដ្ឋកម្ពុជានៅទូទាំងប្រទេសគ្រប់ច្រកល្ហកក្នុងប្រទេស ក៏ដូចជានៅក្រៅប្រទេសផងដែរ សុទ្ធតែអាចទទួលបានព័ត៌មានតាមច្រើនមធ្យោបាយទាំងមធ្យោបាយធម្មតា (កាសែត ទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍ .....) និងទាំងមធ្យោបាយទំនើប ។

ប្រព័ន្ធព័ត៌មានសោតទស្សន៍កំពុងពង្រីកវិសាលភាព គុណភាព និងប្រសិទ្ធភាពនៃការផ្សព្វផ្សាយទាំងក្នុងប្រទេស និងនៅលើពិភពលោក

តូបលក់កាសែតក្នុងរាជធានីភ្នំពេញ

ស្វែងយល់អំពីច្បាប់បោះឆ្នោត

ការយោសនាបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤ (ថ្ងៃទី ២០ ខែឧសភា ដល់ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០១៧)

១- ការយោសនាបោះឆ្នោតមានបំណងឲ្យគណបក្សនយោបាយ ដែលបានការអនុញ្ញាតឲ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដល់អ្នកបោះឆ្នោត ។ ការយោសនាបោះឆ្នោតគឺជាសកម្មភាពមួយចំនួនដែលធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូល អ្នកបោះឆ្នោត ឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ តាមរូបភាពផ្សេងៗមានដូចជា ៖

+ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន

+ ការជួបជុំ ឬការយោសនាតាមផ្ទះ

+ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន

+ ការផ្សព្វផ្សាយតាមរលកអាកាស ឬការយោសនាតាមឧបករណ៍បំពងសម្លេង ឬតាមរយៈការចាក់ផ្សាយ ការសែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ឬវីឌីអូសាធារណៈ ឬទីធ្លាសាធារណៈ

+ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ

+ សកម្មភាពបិទផ្សាយនូវរូបបដា ពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពយោសនានានា

+ សកម្មភាពចែកចាយខិតប័ណ្ណគណបក្សនយោបាយ

+ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារៈ ផ្សេងៗ ទៀត ដែលបានបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត

+ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្ដារបិទក្រដាសផ្សាយ

+ ការប្រគំតន្ត្រីនៅកន្លែងណាមួយ ឬការច្រៀងចម្រៀងយោសនា ឬការលេងភ្លេងយោសនាបោះឆ្នោត ឬ/និងការរៀបចំកម្មវិធីប្រកួតកីឬា ។

២- ស្លាកសញ្ញាគណបក្សនយោបាយ អាចលើកនៅទីសាធារណៈដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ ។

ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារៈយោសនា របស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាត ឲ្យលើក ឬបិទនៅក្នុងបរិវេណ ឬអគារ ឬការិយាល័យរបស់ផ្ទះ ។

ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិតប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋប្រសិនមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬមិនលើក និងបិទ ឬមិនបិទស្លាកសញ្ញា បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន ។

ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារៈយោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការយោសនាបោះឆ្នោតលើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

គណបក្សនយោបាយ ត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដាឯកសារយោសនា ទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

៣- ការយោសនាបោះឆ្នោតមានរយៈពេល ១៤ថ្ងៃ (២០ឧសភា ដល់ ០២ មិថុនា ២០១៧) ហើយគ្រប់សកម្មភាពយោសនាត្រូវបញ្ឈប់ ២៤ម៉ោងមុនថ្ងៃបោះឆ្នោត (០៣ ខែមិថុនា ឆ្នាំ ២០១៧) ។

ការដង្ហែក្ដួនយោសនាគ្រប់ប្រភេទ នៅក្នុងឃុំ សង្កាត់ ធ្វើបានយ៉ាងច្រើន ២ដង ក្នុងអំឡុងពេលយោសនា បោះឆ្នោត ។

រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវបញ្ឈប់ ៧ថ្ងៃ មុនថ្ងៃបោះឆ្នោត (២៨ ខែឧសភា ឆ្នាំ ២០១៧) ។

៤- គណបក្សនយោបាយ និងបេក្ខជនទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភ គំរាមគំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។ គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ អសីលធម៌ ប្រមាថមាក់ងាយទៅលើបេក្ខជន ឬលើបុគ្គលណាមួយ ឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែងបំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្ដិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ ។

គ្រប់គណបក្សនយោបានបេក្ខជនឬតំណាងទាំអស់មិនត្រូវផ្ដល់អំណោយជាថវិកាឬជាសម្ភារៈដែលជាវង្វាន់លើកទឹកចិត្តទោះបីតាមមធ្យោបាយឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុង គោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

៥- មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទនគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖

+ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើជំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញធ្វើឲ្យខូចខាតទ្រព្យសម្បត្ដិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្ទាវុធ ដើម្បីបំកិតបំភ័យ

+ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោត ឲ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ

+ ចូលរួមសកម្មភាពក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ ។

៦-ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ដ្រីរាជការស៊ីវិលអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់កងយោធពលខេមរភូមិន្ទ និងមន្ដ្រីតុលាការដែលកំពុងបំពេញការកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

+ ជាសមាជិកនៃគណៈកម្មការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ

+ ការជួបជុំ ឬការចូលរួមក្នុងក្ស្ជនដង្ហែ ឬក្ស្ជនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់

+ ការចូលរួមក្នុងការស្នង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់

+ ការបើកបរយានជំនិ: របស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

+ ការធ្វើសកម្មភាពចែកចាយសម្ភារៈឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណ បក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់

+ ការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សណាមួយ ឬ/និងបេក្ខជនណាម្នាក់

+ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗតាមរយៈឧបករណ៍បំពង់សំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

- បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ដ្រីរាជការស៊ីវិលអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ដ្រីតុលាការ អាចចូលរួមបានក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្ដែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់និងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។

៧- អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសហគម ឬអង្គការអន្ដរជាតិ ដែលបំពេញការងារ ក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងមិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ដូចខាងក្រោមនេះ ៖

+ ផ្ដួចផ្ដើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្ដួចផ្ដើម ឬការចូលរួមឃោសនារួមមាន ៖

• ការបញ្ជុះបញ្ជូល ឬការប្រមូលផ្ដុំប្រជាពលរដ្ឋចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយ ណាមួយ ឬបេក្ខជនណាម្នាក់

• ការចូលរួមក្នុងក្ស្ជនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ណាមួយ ឬបេក្ខជនណាម្នាក់

• ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ ។

+ ចេញសេចក្ដីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនិងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្ដីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀងរួមមាន ៖

• ការស្នង់មតិក្នុងបំណងបម្រើឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្ដល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្ដរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

+ ផ្ដល់មធ្យោបាយជាថវិកា សម្ភារៈ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ដែលរួមមាន ៖

• ការផ្ដល់យានយន្ដគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការផ្ដល់ថវិកា សម្ភារៈ និងបរិក្ខារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋសម្រាប់ចូលរួមក្នុងសកម្ម ភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់

• ការផ្ដល់ថវិកា សម្ភារៈ ឬបរិក្ខារសម្រាប់ដង្ហែក្ស្ជនឃោសនា ការជួបជុំជាសាធារណៈ ការសម្ដែង សិល្ប: និងការបោះពុម្ពសម្ភារៈឃោសនាទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

- ហាមជនបរទេស ដែលមានវត្ដមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពដោយផ្ទាល់ ឬដោយ ប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៨- កាសែត វិទ្យុ និងទូរទស្សន៍ របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មានដែលស្នើឡើងដោយគណៈកម្មាធិការ ជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំអ្នកបោះឆ្នោត ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

- អ្នកគ្រប់គ្រងរោងមហោស្រប មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណ-បក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលសុំជួល ប្រើប្រាស់ សម្រាប់ឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទ នៃការស្នើសុំ ។

គណបក្សនយោបាយ ឬបេក្ខជន ដែលមានបំណងជួលរោងមហោស្រប មណ្ឌលកីឡា ឧទ្យាន ឬ ទីសាធារណៈ ឬសាលសាធារណៈ ត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោចបីថ្ងៃមុនថ្ងៃឃោសនា ហើយត្រូវ ផ្ញើសេចក្ដីចម្លងនៃពាក្យសុំនេះមួយច្បាប់ជូនដល់គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត (គយ.សប) ។

- អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឲ្យលើស ២៤ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។

- គណបក្សនយោបាយនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ឬបេក្ខជនអាចធ្វើការឃោសនានៅតាមកន្លែងឯកជនបាន តែត្រូវមានការយល់ព្រមជាមួយម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាមុន ទៅគណៈកម្មការ ឃុំ សង្កាត់ រៀបចំការបោះឆ្នោត (គយ.សប) អំពីកាលបរិច្ឆេទនៃការឃោសនាបោះឆ្នោតនោះ ។

៩- ហាមប្រើប្រាស់ថវិកា សម្ភារៈ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាព ឃោសនាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

១០- គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រមិនត្រូវជ្រៀតជ្រែក ឬធ្វើឲ្យរាំងស្ទះដល់សកម្មភាពរបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រផ្សេងទៀត ។

១១- អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហ-ប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

តមកពីទំព័រទី ២១

ផ្ទះសំណាក់មាន ១.៧៥៥ ស្មើនឹង ២៨.៣០៣បន្ទប់ ភោជនីយដ្ឋានមាន ១.៦៣៨ កន្លែង ទីភ្នាក់ងារទេសចរមាន ៧៣០ កន្លែង សេវាកំសាន្តទេសចរ មាន ៨៨ កន្លែង។ ពលករបម្រើការ ងារឲ្យវិស័យឧស្សាហកម្មទេសចរ ដោយផ្ទាល់មានប្រមាណជាង ៦០ម៉ឺននាក់។

១៣- ប្រៃសណីយ៍ និង ទូគមនាគមន៍: គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមហ៊ុនទូរស័ព្ទចល័ត និងអចល័ត ១៤ក្រុមហ៊ុនកំពុងផ្ដល់សេវាកម្ម ទូរស័ព្ទចល័ត និងអចល័ត ដល់អ្នកប្រើប្រាស់ទូទាំងប្រទេសមាន ១៩.៦៨០.៥០៤ គ្រឿង ស្មើនឹង ១២៥,៩៤% នៃប្រជាជនសរុបទូទាំងប្រទេសប៉ាន់ស្មាន ១៥.៦២៦.៤៤៤នាក់។ ក្នុងនោះក្រុមហ៊ុន៦ កំពុងផ្ដល់សេវាកម្មទូរស័ព្ទចល័តមាន ១៩.៤៥០.៥៤២គ្រឿង ស្មើនឹង ១២៤,៤៧% និងក្រុមហ៊ុន៨ កំពុងផ្ដល់សេវាកម្មទូរសព្ទអចល័តមាន ២២៩.៩៦២ គ្រឿង ស្មើនឹង ១,៤៧%។ ក្រុមហ៊ុនអ៊ីនធើណែតចល័ត និងអចល័ត ៣៩ ក្រុមហ៊ុនកំពុងផ្ដល់សេវាកម្មជូន អតិថិជនប្រើប្រាស់ ៧.៥៧៥.៨២២នាក់ ស្មើនឹង ៤៨,៤៨% នៃប្រជាជនសរុបទូទាំងប្រទេស ប៉ាន់ស្មាន ១៥.៦២៦.៤៤៤នាក់ ក្នុងនោះក្រុមហ៊ុន៦ កំពុងផ្ដល់សេវាកម្មអ៊ីនធើណែតចល័តមានអតិថិជន ៧.៤៧៨.៤៣៦ នាក់ ស្មើនឹង ៤៧,៨៦% និងក្រុមហ៊ុន ៣៣ កំពុងផ្ដល់សេវាកម្មអ៊ីនធើណែតអចល័តមានអតិថិជន ៩៧.៣៨៦ នាក់ ស្មើនឹង ០,៦២%។

១៤- អប់រំ: សិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិបញ្ចប់ឆ្នាំសិក្សា២០១៥-២០១៦ មានបេក្ខជនប្រឡងជាប់ស្មាពរ ១១៨.០៣០ នាក់(ស្រី៦២.៣០១នាក់)ស្មើនឹង៩៣,៧២%។ សិស្សប្រឡងសញ្ញាបត្រមធ្យមទុតិយភូមិ បេក្ខជនប្រឡងជាប់ស្មាពរមាន ៥៥.៧៥៣ នាក់ (ស្រី ២៨.៨០៧ នាក់) ស្មើនឹង ៦២,១៨% (ស្រី៦៥,៤៦%) ក្នុងនោះនិទ្ទេសA មាន៤០៥ នាក់ (ស្រី២០៤នាក់)។ គ្រឹះស្ថានឧត្តមសិក្សាសរុបមាន ១២១ សាលា ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋ៤៨ សាលា និងឯកជន ៧៣ សាលា។ ការប្រឡងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតទាំងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនសរុប ៥៨.៩៨៨នាក់ (ស្រី២៦.៩២០ នាក់)។

១៥-សុខាភិបាល: មូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេសក្នុងឆ្នាំ២០១៦ នេះ មានមន្ទីរពេទ្យជាតិ៨ មន្ទីរពេទ្យរាជធានីខេត្ត២៤ (ខេត្តត្បូងឃ្មុំមិនទាន់មាន) មន្ទីរពេទ្យបង្អែកក្រុងស្រុក ៨២ មណ្ឌលសុខភាព១.១៨៦ និងប៉ុស្ត៍សុខភាព៩១ មានគ្រែសរុបទូទាំងប្រទេស ១២.៥៣៤គ្រែ ។ មានវេជ្ជបណ្ឌិតឯកទេស ៦៩០នាក់ វេជ្ជបណ្ឌិត ២.៤០៣៩ នាក់ គ្រូពេទ្យមធ្យម៨៦៦ នាក់ ឱសថការីបណ្ឌិត២២ នាក់ ឱសថការី ៥៨៩នាក់ ឱសថការីមធ្យម៩៥នាក់ ឱសថការីបឋម៥៣នាក់ ទន្ទបណ្ឌិត ២៧៥នាក់ ទន្ទពេទ្យ៥៥នាក់ គិលានុបដ្ឋាក១៣៣ នាក់ ពេទ្យធ្មេញបឋម ១៣នាក់ បរិញ្ញាបត្រគិលានុបដ្ឋាក ១១៦នាក់ គិលានុប-ដ្ឋាកមធ្យម ៧.៨៩៧នាក់ គិលានុបដ្ឋាកបឋម ៣.១៩៨នាក់ បរិញ្ញាបត្រឆ្មប ៨៩នាក់ ឆ្មបមធ្យម៤.០២២នាក់ និងឆ្មបបឋម ២.៣៦៤ នាក់។

ឃុំស្វាយស ដ៏ឆ្ងាយតែនៅកៀកបង្កើយជាមួយយើង

ភ្ញៀវទេសចរណ៍ទៅលេងរមណីយ៍ដ្ឋាននៅក្នុងឃុំស្វាយស

ចាកចេញពីក្រុងសៀមរាប ដោយចំណាយពេលប្រមាណបីម៉ោងក្នុងល្បឿនរថយន្តមធ្យម លើកំណាត់ផ្លូវក្រាលកៅស៊ូខ្មៅរលោង គឺផ្លូវជាតិលេខ៦៧ ហើយត្រូវឆ្លងកាត់កំណាត់ផ្លូវក្រាលក្រួសក្រហម យើងបានទៅដល់ឃុំស្វាយស ស្រុកវ៉ារិន ប្រកបដោយសុវត្ថិភាព។ ជំនោរខែមករា ធាតុអាកាសត្រជាក់ល្មម ដែលអាចអនុញ្ញាតឲ្យយើងធ្វើដំណើរ ដោយបើកកញ្ចក់រថយន្ត ដើម្បីបានស្រូបយកក្លិនប្រហើរនៃស្រូវស្រែដែលកំពុងទុំ ដួលរាបទៅក្នុងស្រែ និងក្លិនគល់ជញ្ជាំងនៃស្រែខ្លះ ដែលទើបនឹងច្រូតកាត់រួច។ ជួនកាលយើងឮសម្លេងភ្លេងការល្ងើយ១ពីភូមិដែលនៅឆ្ងាយពីផ្លូវ។ សម្លេងសើចក្អាកក្អាយរបស់ប្រជាពលរដ្ឋ និងកុមារ កុមារីទាំងនេះ គឺជាអ្វីដែលកំពុងតែកើតឡើងនៅឃុំជនបទដាច់ស្រយាលមួយ ដែលយើងបានទៅដល់។

ឃុំស្វាយសអតីតកាលនិងបច្ចុប្បន្ន

ស្វាយសជាឃុំមួយ ក្នុងចំណោមឃុំទាំង៥ នៃស្រុកវ៉ារិន ខេត្តសៀមរាប។ ឃុំនេះមានភូមិសាស្ត្រខាងជើងទល់នឹងឃុំប្រាសាទ, ខាងលិចទល់នឹងឃុំស្រែខ្ទាវ ស្រុកអង្គរជុំ, ខាងត្បូងទល់នឹងឃុំគោកដូងស្រុកអង្គរជុំ និងខាង កើតទល់នឹងឃុំឃុនរាម ស្រុកបន្ទាយស្រី។ ឃុំមានផ្ទៃដីសរុប ៨៨៨ ៣ ហិកតា ចែកចេញជា៧ ភូមិ មានប្រជាពលរដ្ឋប្រមាណ ៩៩% ដែលប្រកបមុខរបរធ្វើស្រែ និងមាន ១ % រកស៊ីលក់ដូរ។ ប្រជាពលរដ្ឋឃុំស្វាយស មានចំនួន ១ ២៥៣ គ្រួសារស្មើនឹងមនុស្សរាយចំនួន ៥ ៥១៣ នាក់ ក្នុងនោះស្រី២ ៨៥៦ នាក់,ស្មើនឹងខ្នងផ្ទះ ១ ១៧៤ ខ្នង។

ដើម្បីធ្វើដំណើរទៅកាន់ឃុំស្វាយស គេអាចទៅបានដោយប្រើប្រាស់ផ្លូវចំនួនពីរ ខ្សែផ្សេងគ្នា។ ខ្សែទីមួយគេអាចចាកចេញពីក្រុងសៀមរាបឆ្ពោះទៅទិសខាងលិច តាមកំណាត់ផ្លូវជាតិ លេខ ៦ ទៅដល់ស្រុកពួក និងកាត់ទៅស្រុកអង្គរធំរួចសំដៅទៅរកឃុំនេះ តែម្តងដោយធ្វើដំណើរលើចំងាយផ្លូវជាង ១០០គ.ម ដែលក្នុងនេះជាផ្លូវកៅស៊ូជាង ១៧គ.ម និងក្រៅ ពីនេះជាផ្លូវក្រួសក្រហម។ ចំណែកខ្សែទី២ គឺចាកចេញដោយឆ្ពោះទៅទិសខាងកើត ខេត្តលើកំណាត់ផ្លូវជាតិលេខ៦ រួចបត់ទៅផ្លូវជាតិលេខ ៦៧តម្រង់ទៅឃុំស្រែណូយស្រុកបន្ទាយស្រី រួចបត់ឆ្វេងហើយអាចទៅដល់ឃុំនេះតែម្តង ដែលមានចំងាយផ្លូវជាង ៨០គ.ម ក្នុងនេះជាផ្លូវកៅស៊ូប្រវែងប្រមាណ៦០គ.ម។

លោក **លាវ រីណា** ប្រធានក្រុមប្រឹក្សាឃុំស្វាយស និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ឃុំស្វាយស បានរំលឹករឿងរ៉ាវមួយចំនួនទាក់ទងនឹងអតីតកាល នៃឃុំនេះ ប្រាប់យើងថា អ្វីដែលយើងបានឃើញនៅពេលនេះគឺជាទិដ្ឋភាពដែលមិននឹកស្មានដល់ ។ ក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ និងជាច្រើនឆ្នាំ បន្តបន្ទាប់មកទៀត រហូតដល់ជិតចុងទសវត្សរ៍ឆ្នាំ ៩០ ឃុំស្វាយស គឺជាចំណុចក្តៅ មួយនៃសង្គ្រាមពិសេស នៅមុនមានសមាហរណកម្មកម្លាំងខ្មែរក្រហម។ តំបន់មួយនេះ ជួបប្រទះនឹងអសន្តិសុខខ្លាំង មិនអាចចេះតែធ្វើដំណើរចេញចូលបានតាមចិត្តនោះទេ។ ម្យ៉ាងទៀតឃុំនេះពីមុនពុំមានផ្លូវក្រាលកៅស៊ូ ផ្លូវក្រួសក្រហម ដូចពេលនេះឡើយ។ តាំងពីបរមបុរាណមកមានតែផ្លូវរទេះគោបរកាត់វាលស្រែ។ នៅខែប្រាំងដីហុយទ្រលោម ឯខែវស្សាដើរលុយទឹកកប់ភ្លៅ។ ជារួមទំនាក់ទំនងពីភូមិមួយ ទៅភូមិមួយ ពីឃុំមួយទៅឃុំមួយគឺ ធ្វើដំណើរដោយរទេះគោ ក្របី កង់ ឬដើរដោយថ្មើរជើងតែប៉ុណ្ណោះ។

បន្ទាប់ពីរំលឹកបែបនេះ លោកមេឃុំប្រែទឹកមុខជាញញឹមវិញថា បច្ចុប្បន្នប្រជាជនរស់នៅបានងាយស្រួលណាស់។ ចង់ធ្វើដំណើរទៅណាពេលណាក៏បាន។ យើងមានផ្លូវមានមធ្យោ-បាយធ្វើដំណើរទាំងផ្ទាល់ខ្លួន ឬរថយន្តតាក់ស៊ីគ្រប់គ្រាន់ឥតខ្វះ។ កាលពីមុនការធ្វើដំណើរពីខេត្តសៀមរាបមក ឃុំនេះជួនកាលត្រូវដេកផ្លូវជួនកាលចំណាយពេលស្ទើរពេញមួយថ្ងៃ ទើបមកដល់។ ពេលមកដល់មើលមនុស្សសឹងមិនស្គាល់ដោយសារតែ ធូលីដី ហុយរុំជិតជុំ ។ ឥឡូវការធ្វើដំណើរ ចំណាយពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ អ្នកឃុំស្វាយសខ្លះ ឡើងចុះទៅសៀមរាបដូចទៅផ្សារអីចឹង។

ភាពរស់រវើកនៃឃុំស្វាយស

ដូចអ៊ីវីដ លៃលាកប៉ុរធានក្រុមប៉ារ៉ូ្ក សាឃុំបានរៀបរាប់។ នៅចន្លោះភូមិនានានៃឃុំបានក្រាលពេញទៅដោយវាលស្រែ។ ស្រែខ្លះនៅចន្លោះដើមឈើ។ ជារដូវចម្រូតផង យូរៗម្តងយើងលឺសម្លេងកសិករដែលស្រែករកគ្នា។

ប៉ុន្តែនៅក្នុងភូមិ និងទីប្រជុំជនជាប់នឹងដងផ្លូវយើងបានជួបប្រទះជាញឹកញាប់នូវអគារសិក្សា

ពោលគឺ ឃុំនេះមានរហូតដល់អនុវិទ្យាល័យ ។ លោកមេឃុំប្រាប់ថា ដោយទទួលបានការយកចិត្តទុកដាក់ពីអាជ្ញាធរស្រុក ខេត្តការិយាល័យអប់រំមន្ទីរអប់រំខេត្ត ពិសេសរាជរដ្ឋាភិបាលដែលមាន**សម្ដេចតេជោ ហ៊ុន សែន** ជាប្រមុខ ឃុំស្វាយសពេលនេះ បានក្លាយជាឃុំឈានមុខមួយក្នុងវិស័យអប់រំ ។ បច្ចុប្បន្នទូទាំងឃុំមានសាលារៀនចំនួន ៨កន្លែងស្មើនឹង៨ ខ្នងនិងមានបន្ទប់ចំនួន ៣៤បន្ទប់ ។ ក្នុងចំនួននោះមានសាលាបឋមសិក្សា៨ កន្លែងនិងអនុវិទ្យាល័យ១ កន្លែងដែលមានសិស្ស សរុបចំនួន ១២៨៨ នាក់ ក្នុងនោះស្រីចំនួន៦៥៧ នាក់។ចំនួនសិស្សមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំបន្ថែមទៀត។

លោកមេឃុំបានបញ្ជាក់ថា ការប្រែប្រួលខាងជីវភាព និងការសិក្សារបស់ប្រជាជននៅក្នុងឃុំ គឺផ្ដើមចេញសំខាន់ពីវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងឃុំផងដែរ។ ក្នុងឃុំទាំងមូលមានផ្លូវខ្វាត់ខ្វែងចំនួនរាប់ពាន់ គីឡូម៉ែត្រ ។ ក្នុងចំនួននេះមានផ្លូវក្រាលកៅស៊ូចំនួន ១១គ.ម ដែលផ្លូវទាំងនោះ គឺកំពុងតែបម្រើឲ្យវិស័យដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋឆ្លងកាត់ទៅមកមានភាពងាយស្រួលបំផុត។ ជាមួយការអភិវឌ្ឍផ្លូវគមនាគមន៍នេះ ឃុំនឹងមានគម្រោងជាបន្តបន្ទាប់ទៀត ដើម្បីប្រែក្លាយផ្លូវដីសឲ្យទៅជាផ្លូវដី ក្រាលក្រួសក្រហមរាប់សិប គីឡូម៉ែត្របន្ថែមទៀត។

គិតត្រឹមដើមខែមករា ឆ្នាំ២០១៧ ឃុំទាំងមូលមានគោយន្តកន្ត្រៃចំនួន ៤៩៥ គ្រឿង, ត្រាក់ទ័រចំនួន១០ គ្រឿង, ឡានធំសម្រាប់ដឹកជញ្ជូនចំនួន៦គ្រឿង, ឡានតូចចំនួន១៣ គ្រឿង, ម៉ូតូចំនួន ៥៤៦ គ្រឿង, ម៉ាស៊ីន បោកស្រូវចំនួន ៧ គ្រឿង, និងកង់មានចំនួន៤០០ គ្រឿង។ អ្វីៗទាំងនេះ មិនមែនកើតឡើងដោយឯកឯងឡើយ តែវាបានបញ្ជាក់អំពីលទ្ធភាព និងធនធានរបស់ប្រជាជននៅក្នុងឃុំនេះផ្ទាល់ផងដែរ។

ស្ថានភាពទូទៅនៃការបង្កបង្កើនផលនៅទីនេះ មួយផ្នែកបានពឹងផ្អែកលើការខិតខំថែទាំដោយកសិករផ្ទាល់ និងមួយផ្នែកពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រដែលជួយគិតគូដោយផ្នែក៣ក-ព័ន្ធ។ លោក **លាវ រ៉ីណា** បញ្ជាក់ថា ក្នុងឃុំមានប្រព័ន្ធធារាសាស្ត្រសំខាន់ៗចំនួន ៥កន្លែង ដែលអាចស្រោច ស្រពស្រូវវស្សាបានចំនួន ១ ៤០០ ហិកតា។ ធារាសាស្ត្រនេះដែរ ក៏អាចជួយស្រោចស្រពនូវស្រូវប្រាំងបានប្រមាណ ១០ហិកតាថែមទៀត។

លោកមេឃុំបន្តថា ទឹក គឺជាបញ្ហាសំខាន់ដោយមិនមែន សម្រាប់តែការបង្កបង្កើនផលទេ តែក៏សម្រាប់ការហូបចុកប្រចាំថ្ងៃផងដែរ ។ អ្វីដែលសំខាន់គឺទឹកប្រើប្រាស់ដែលមានគុណភាពកាន់តែប្រសើរមិនប៉ះពាល់ដល់សុខភាព។លោកមេឃុំប្រាប់ថា ក្នុងឃុំមានស្រះទឹកសហគមន៍ចំនួន៥៦ កន្លែង អណ្ដូងទឹកធ្វើអំពីលូចំនួន ៧០០ កន្លែង និងអណ្ដូងស្ទប់ចំនួន១៤ កន្លែង ។ ទឹកស្អាតទាំងនេះ ក្រៅពីបម្រើឲ្យការប្រើប្រាស់ ហូបចុកប្រចាំថ្ងៃរបស់មនុស្ស សត្វពាហនៈ ក៏បានបម្រើឲ្យការស្រោចស្រព បន្លែបង្ការជាច្រើនមុខថែមទៀតផង ។

ពុទ្ធចក្រនិងទេសចរណ៍

ដោយឆ្លាស់ប្ដូរពីតំបន់ដែលមុននេះច្រើនឆ្នាំ ជាតំបន់សង្គ្រាម និងជាតំបន់ដាច់ស្រយាលមួយរបស់ ខេត្តសៀមរាបនោះ ជាបន្តបន្ទាប់នៃអាណត្តិរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធាន គណបក្ស ប្រជាជនកម្ពុជា វិស័យពុទ្ធចក្រនៅឃុំស្វាយស ក៏កំពុងមានការរីកចម្រើនគួរកត់សម្គាល់ ដោយពេលនេះឃុំមានវត្តអារាមចំនួន ៣ កន្លែងមានព្រះសង្ឆចំនួន១៩ អង្គ មានយាយជី តាជី អាចារ្យ គណៈកម្មការ កូនសិស្សលោកជាច្រើននាក់ ។ ទីអារាមក្រៅពីបំរើអោយវិស័យពុទ្ធសាសនា ក៏ជាទីស្នាក់នៅរបស់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ ដែលមកសិក្សា ឬបំពេញការងារនៅក្នុងឃុំផងដែរ ។

កុមារនៅឃុំ ស្វាយស ដ៏ឆ្ងាយដាច់ស្រយាលក៏ទទួលបានសេវាអប់រំយ៉ាងល្អប្រសើរ

លោកមេឃុំបានប្រាប់ថា ឃុំក៏មានតំបន់ទេសចរណ៍មួយកន្លែង គឺជារមណីយដ្ឋានទឹកធ្លាក់ ដែលអាចស្រូបទាញភ្ញៀវទេសចរក្នុងស្រុក និងភ្ញៀវទេសចរបរទេសបាន ប៉ុន្តែបច្ចុប្បន្នមានអ្នក ដែលមកកម្សាន្តនៅរមណីយដ្ឋាននេះ ក្នុងចំនួនតូចតួចនៅឡើយ។ លោកមេឃុំរំពឹងថា នៅពេលអនាគតរមណីយដ្ឋានមួយនេះ នឹងទទួលបាន នូវការអភិវឌ្ឍ ទៅតាមតំណាក់កាលនីមួយៗ។ ក្រៅពីរមណីយដ្ឋានខាងលើគឺឃុំមានព្រៃសហគមន៍ចំនួន ៣កន្លែងថែមទៀត ដែលមានផ្ទៃដីសរុបចំនួន៣៤៤ ហិកតា ។

ឃុំស្វាយស សង្ឃឹមបោះជំហានទៅមុខ

ដោយសារសក្តានុពលនៅក្នុងឃុំ និងលទ្ធភាពកាន់តែប្រសើរឡើងជាបន្តបន្ទាប់ របស់ប្រជាជននៅក្នុងឃុំនោះ លោកមេឃុំបានបង្ហាញនូវក្តីសង្ឃឹមយ៉ាងមុតមាំ ចំពោះការអភិវឌ្ឍនៅតំបន់ចុងកាត់មាត់ញកមួយនេះ។ លោកបញ្ជាក់ថា ឃុំមានផែនការគោលការណ៍ អភិវឌ្ឍន៍ឃុំ សម្រាប់អនុវត្តនៅអាណត្តិបន្ត ដែលនឹងធ្វើការបោះឆ្នោតនៅខែមិថុនា ខាងមុខនេះហើយ ។ ជាគោលបំណងធំរបស់អាជ្ញាធរឃុំ និងប្រជាពលរដ្ឋ គឺធ្វើយ៉ាងណាឲ្យគណបក្សប្រជាជនកម្ពុជា បន្តទទួលបានជោគជ័យក្នុងការដឹកនាំឃុំ ដោយខិតខំអនុវត្តឲ្យមានប្រសិទ្ធភាព នូវគោលនយោបាយភូមិឃុំ មានសុវត្ថិភាព ក៏ដូចជាការយកចិត្តទុកដាក់លើវិស័យអប់រំ សុខាភិបាល គមនាគមន៍ អគ្គិសនី ធារាសាស្ត្រ។ ឃុំក៏នឹងជំរុញឲ្យមានការអភិវឌ្ឍនូវរមណីយដ្ឋាន ដែលមានស្រាប់ក្នុងមូលដ្ឋានផងដែរ។

ចប់ការងារគឺជាពេលល្ងាចល្មម។ យើងចាកចេញពីឃុំស្វាយសតាមផ្លូវមួយខ្សែទៀត ដែលឆ្ពោះមករកស្រុកពួក ដែលភ្ជាប់មកផ្លូវជាតិលេខ ៦ ។ ថ្ងៃហៀបអស្តង្គត សម្លេងគោយន្តកន្ត្រៃ សម្លេងម៉ូតូ និងសម្រែកស្រែករកគ្នារបស់អ្នកភូមិនៃ ឃុំស្វាយស បានធ្វើឲ្យយើងជក់ចិត្តនឹងទិដ្ឋភាពនេះពុំអាចបំភ្លេចបាន។

កុ

១. ចាស់ទុំបុរាណ បានអប់រំ ចូរកូននាងកុំបីវាយមាយ
ពាក្យនេះទុកដូចជាសំពាយ តទៅមុខងាយ កាយសមសួន ។
២. កុំគិតរួសពេក វាបែកបាក់ កុំឲ្យថ្នាំងថ្នាក់ វាបាត់ស្នូន
កុំខ្ជិលងុយងោក វាថោកខ្លួន កុំឲ្យវេះពួន វាបាត់មុខ ។
៣. កុំមាន:ពេក វាបែកមិត្ត កុំឲ្យទ្រុស្ដស្ដិទ្ធ វាបាត់សុខ
កុំឲ្យលើកខ្លួន វាផ្ទួនទុក្ខ កុំឲ្យបាត់មុខ វាអប្រិយ ។
៤. កុំឲ្យបាត់ស្នេហ៍ វាបែរឃ្លាត កុំឲ្យទ្រុស្ដញាតិ វាកើតក្ដី
កុំឲ្យហ៊ានហួស អាយុខ្លី កុំឲ្យវាយស្រី វាខូចឫក ។
៥. កុំឲ្យស្ងៀមដៃ វាធ្លាប់ល្ងង់ កុំឱបជង្គង់ វាធ្លាប់ស្ពឹក
កុំឲ្យយឺតពេក វាទ្រមឹក កុំឲ្យឆ្ងើងឫក គេខ្ពើមស្អប់ ។
៦. កុំស៊ីច្រើនពេក វាបែកពោះ កុំឲ្យឡេះឡោះ វាខូចទ្រព្យ
កុំឲ្យខុសរឿយ វាអាម៉ាស់ កុំឲ្យលេលាប់ វាធ្លាប់ខ្លួន ។
៧. កុំតាំងខ្លួនខ្ពស់ ហួសក្ដីល្អ ធ្វើល្អខ្ពស់ជាង ទើបសមសួន
គុណធម៌បវរ ល្អមាំមួន ទើបជីវិតខ្លួន បានពិសិដ្ឋ ។
៨. កិច្ចការប្រុងធ្វើ គិតក្នុងចិត្ត គប្បីប្រុងប្រិត បិទឲ្យជិត
មិនគួរបញ្ចេញ វាចាពិត ព្រោះត្រឹមគំនិតក្នុងចិន្តា ។
៩. ឯកិច្ចការគ្រាន់ បានកំណត់ មិនទាន់បានបទ ច្បាស់ទីណា
ទីនោះមិនទាន់ កើតសាច់ការ កុំចេញវោហារ ឲ្យគេដឹង ។
១០. ទឹកស្រក់តក់ៗ ផ្ទុះផ្ទាំងថ្ម គឺជាគុណធម៌ ព្យាយាមប្រឹង
នាំភាពជោគជ័យន័យរឹងប៉ឹង ព្រោះចេះថ្លៃងថ្លឹងពិចារណា ។៖

កាំបិតចិតដងឯង

ពេលអ្នកស្រី រ៉ូហ្សា ត្រឡប់ពីផ្សារចូលដល់មាត់ទ្វារផ្ទះ

កុមារ ខាំថែល អាយុ ៧ ឆ្នាំប្រញាប់ទៅទូលពិត :

- ម៉ាក់.ម៉ាក់ ខ្ញុំឃើញលោកប៉ាអង្គុយឱបមឹងម៉ារីយ៉ានៅក្នុងសួនច្បារ

ម្ដាយរាដៃកាត់ :

- អើ...អើ.ប៉ុណ្ណឹងម៉ាក់យល់ហើយ។ ចាំយប់ពេលប៉ាត្រឡប់មកដល់ផ្ទះវិញ សឹមកូនឯងធ្វើជាប្រាប់ម៉ាក់ពីរឿងនេះ ដើម្បីឲ្យអ្នកឯទៀតបានដឹងផងយល់ហើយនៅ ?

យប់ឡើង ពេលអ្នកផ្ទះជួបជុំគ្នាអស់នៅតុបាយ កុមារខាំថែល នឹកឃើញបណ្ដាំម្ដាយពីថ្ងៃក៏និយាយទៀតបញ្ចប់ :

- ម៉ាក់.ម៉ាក់.... ព្រឹកមិញ ប៉ាអង្គុយឱបមឹងម៉ារីយ៉ាក្នុងសួនច្បារ ត្រង់កន្លែងដែលម៉ាក់ និងពូ ប៊ីនថេសឧស្សាហ៍ឱបគ្នាពេលប៉ាមិននៅផ្ទះ ចុះទៅខេត្តនោះអី ។៖

មិនបាច់ទេ

លោក ឡឹម ត្រូវឆ្កែឆ្ពុតដេញខាំរត់ជុំវិញធ្លាបាល់ទាត់អស់មួយជុំ ហើយមួយជុំទៀត។ ឃើញដូច្នេះម្ចាស់ផ្ទះ ដែលមានផ្ទះនៅជាប់ធ្លាបាល់ទាត់ស្រែកប្រាប់ពីបង្អួចជាន់ទី២ :

- អេហ៍បងប្រុសរត់ចូលផ្ទះខ្ញុំមក ទ្វាររបងខាងមុខកំពុងបើកចំហហើយ។

លោក ឡឹម មាត់ដកដង្ហើមឃូសខសៗបណ្ដើរឆ្លើយបណ្ដើរ :

- អរគុណ.អរគុណហើយ មិនបាច់ទេ ខ្ញុំរត់លឿនជាងវាដល់ទៅជាង ២ជុំឯណោះឃើញទេ។៖

ដេកមិនគ្រប់គ្រាន់

ព្រឹកនេះ នាយ ឆ្លាំង បានទៅគ្លីនិកតួញ ត្អែរប្រាប់លោកវេជ្ជបណ្ឌិតថារៀងរាល់យប់ខ្លួនដេកបានតិចតួចណាស់ មិនគ្រប់គ្រាន់សម្រាប់សុខភាពទេ។

ឮដូច្នោះ លោកវេជ្ជបណ្ឌិតសួរបញ្ជាក់ :

- ក្នុងមួយថ្ងៃមួយយប់ប្អូនដេកបានប៉ុន្មានម៉ោង ?

- បាទ...គឺខ្ញុំដេកបានប្រមាណតែ១០ ម៉ោងប៉ុណ្ណោះ !

- អុញ...ដល់ទៅ ១០ម៉ោង នៅថា មិនគ្រប់គ្រាន់ទៀត ?

- បាទ... វាពិតជាអ៊ីចឹងមែន ព្រោះរយៈពេល ១០ម៉ោង ដេកលក់នោះ ខ្ញុំតែងយល់សប្ដិឃើញ ខ្លួនឯងនៅភ្ញាក់ដើរលេង តាមគ្រប់កន្លែងនានា ។៖

កូនប្រុស-កូនស្រី

នាង ញ៉ន កំពុងដេកសម្រាលកូននៅក្នុងបន្ទប់ ឯនាយ ញ៉ុក ជាប្ដី និងឪពុកម្ដាយកំពុងរង់ចាំនៅខាងក្រៅយ៉ាងអន្ទះសា ។ មួយសន្ទុះ នាងគិលានុបដ្ឋាយិកា បើទារកចេញមក។ នាយ ញ៉ុក ស្ទុះទៅទទួលមុនគេ ព្រមទាំងទាញក្រណាត់គ្របចេញ ហើយស្រែក :

- អស្ចារ្យ...កូនប្រុស...កូនប្រុស ! ខ្ញុំបានកូនប្រុសហើយ ! ភ្លាមនោះ នាងគិលានុបដ្ឋាយិកាស្រែកវិញ !

- កូនប្រុសស្អី ? ម្រាមដៃខ្ញុំតើ ឆាប់លែងម្រាមដៃខ្ញុំភ្លាម ។៖

១:ម្ភ ឈិច

ពេលល្ងាចមួយវិចិត្រករ សំបូរ សួរនាង សម្ផត្ដិ ជាភរិយា ដែលបានដើរមកដាក់បង្ហុយក្បែរខ្លួនកំពុងគូរ :

- អ្នកសាកពិនិត្យគំនូរព្រះអាទិត្យដែលបងគូរនេះ ហើយទាយមើលតើព្រះអាទិត្យទើបនឹងរះ ឬហៀបនឹងលិច ?នាងសម្ផត្ដិ ក្រឡេកមាត់ញញឹមទើបឆ្លើយ :

- ចាំ: ព្រះអាទិត្យនេះគឺហៀបនឹងលិច !

- ម៉េចបានជាអ្នកហ៊ានអះអាងអ៊ីចឹង ?

- ចាំ: ព្រោះបងដេកមិនដែលក្រោកពីព្រលឹមណាម្ដងផង ម៉េចបានឃើញព្រះអាទិត្យរះ ដើម្បីគូរតាមបាន ។៖

ចោះពុម្ពដោយ រោងពុម្ព អរិយធម៌ ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

ក្រសួងសុខាភិបាល លទ្ធកម្មការិយាល័យ ប្រចាំខែ ១៧

១-	០១/០១/២០២០	០២	០២	[illegible]	១០០,០០០
២-	០១	០៤	០៤	[illegible]	១០០ ម្តង
៣-	០១	០៦	០៦	[illegible]	១០០ ម្តង
៤-	០១	០៧	០ជ	[illegible]	១០០ ម្តង
៥-	០១	១០	១០	[illegible]	១០០ ម្តង
៦-	០១	១២	១២	[illegible]	១០០ ម្តង
៧-	០១	១៤	១៤	[illegible]	១០០ ម្តង
៨-	០១	១៦	១៧	[illegible]	១០០ ម្តង
៩-	០១	១៨	១៩	[illegible]	១០០ ម្តង
១០-	០១	២០	២០	[illegible]	១០០ ម្តង
១១-	០១	២០	២០	[illegible]	១០០ ម្តង
១២-	០១	២០	២០	[illegible]	១០០ ម្តង
១៣-	០១	២០	២០	[illegible]	១០០ ម្តង
១៤-	០១	២០	២០	[illegible]	១០០ ម្តង
១៥-	០១	២០	២០	[illegible]	១០០ ម្តង
១៦-	០១	២០	២០	[illegible]	១០០ ម្តង
១៧-	[illegible]				១០០ ម្តង
១៨-	[illegible]				១០០ ម្តង
១៩-	[illegible]				១០០ ម្តង
២០-	[illegible]				៨០ ម្តង
២១-	[illegible]				៨០ ម្តង
២២-	[illegible]				៨០ ម្តង
២៣-	[illegible]				១០០,០០០
២៤-	០១	២០	២០	[illegible]	១០០,០០០
២៥-	០១	២០	២០	[illegible]	៨០ ម្តង
២៦-	០១	០៦	២០	[illegible]	២២,០០០
២៧-	០១	០៩	២០	[illegible]	៨០ ម្តង
២៨-	០១	២០	២០	[illegible]	៨០ ម្តង
២៩-	០១	២០	២០	[illegible]	១០០,០០០
៣០-	០១	២០	២០	[illegible]	១០០,០០០
៣១-	០១	២០	២០	[illegible]	៨០ ម្តង
៣២-	០១	២០	២០	[illegible]	៨០ ម្តង
៣៣-	០១	២០	២០	[illegible]	៨០ ម្តង
៣៤-	០១	២០	២០	[illegible]	១០០,០០០
៣៥-	០១	២០	២០	[illegible]	១០០,០០០
៣៦-	០១	២០	២០	[illegible]	១០០,០០០
៣៧-	០១	២០	២០	[illegible]	១០០,០០០
៣៨-	០១	២០	២០	[illegible]	១០០,០០០
៣៩-	០១	២០	២០	[illegible]	១០,០០០
៤០-	០១	២០	២០	[illegible]	១០,០០០
៤១-	០១	២០	២០	[illegible]	១០,០០០
៤២-	០១	២០	២០	[illegible]	១០,០០០

[illegible] [illegible] [illegible] [illegible] [illegible]

[illegible]	[illegible]	[illegible]	[illegible]	[illegible]	[illegible]

សម្តេចពញាចក្រី ហេង សំរិន
ជួបសំណេះសំណាលជាមួយ
សមាជិក ក្រុមប្រឹក្សាស្រុក / ឃុំ .....
* ជួយសម្រួលរាល់ការលំបាក
ក្នុងកិច្ចការផ្តល់សេវាសាធារណៈ ....

៥

សម្តេចតេជោ ហ៊ុន សែន :
ត្រូវតែហ៊ាននិយាយអំពីប្រទេស
ដែលបង្ករសោកនាដកម្មលើកុមារ,
ត្រូវមានអភិបាលខេត្តជាស្ត្រីមួយ.....,
កម្ពុជាចាំបាច់ត្រូវធ្វើ.....

៦

សម្តេចក្រឡាហោម :
ប្រទេសចិនជាដៃគូដ៏ពិសេស
ក្នុងការរួមចំណែក .....
* ពាក្យស្លោការបស់គណបក្ស
ប្រឆាំងបង្ករឲ្យមានការ .....

៨

សម្តេចកត្តិ សាយ ឈុំ
ជួបសំណេះសំណាលជាមួយ
គណៈប្រតិភូស្ត្រី
ក្នុងទិវានារីអន្តរជាតិ ៨ មីនា

៩

ចងចាំជានិច្ចនូវស្នាដៃ និង
គំរូវីរភាពដ៏ថ្លៃថ្លារបស់
សម្តេចវិបុលបញ្ញា សុខ អាន

១១

ក្រុមមុខ

សម្តេចតេជោ ហ៊ុន សែន
អញ្ជើញចូលរួមក្នុងពិធីសម្ពោធ
អគារសិក្សា វិទ្យាល័យ
សម្តេចតេជោ ហ៊ុន សែន
ក្រុងក្រចេះ
(ថ្ងៃទី ២៧.០៣.២០១៧)

មាតិកា
Contents

វិចារណកថា : ការរីកចម្រើនរបស់ឃុំ សង្កាត់ គឺជាកាលានុវត្តភាពដ៏ធំធេងសម្រាប់ឲ្យគណបក្សប្រជាជនកម្ពុជា បន្តពង្រឹងតួនាទីដឹកនាំនៅមូលដ្ឋាន ៣

Editorial : Communal/Sangkat Progresses – A Tremendous Opportunity for CPP to Continue Local Leadership Role .....

- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស* ១៣
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស* ១៦
- *កម្ពុជា-វៀតណាម ខិតខំពង្រឹងទំនាក់ទំនងលើគ្រប់វិស័យ* ១៨
- *សមិទ្ធផលសេដ្ឋកិច្ច-សង្គម ឆ្នាំ២០១៦* ២០
- *កំណែទម្រង់ក្នុងវិស័យពាណិជ្ជកម្មធ្វើឲ្យការប្រមូលចំណូលថវិកាជាតិ* ២២
- *ពង្រឹងវិស័យព័ត៌មាន ដោយខិតខំពង្រីកវិសាលភាព គុណភាព និងប្រសិទ្ធភាព* ២៤
- *ការយោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៤* ២៧
- *អត្ថបទមូលដ្ឋាន : ឃុំស្វាយស ដ៏ភ្ញាយតែនៅកៀកបង្កើយជាមួយយើង* ២៦
- *កំណាព្យ : កុំ.....សំណើច* ៣១

និពន្ធនាយក :
លោក តាក ស៊ុនអ៊ី
គណៈកម្មការនិពន្ធ
១. លោក ខ្សៀវ ណារី
២. លោក អ៊ីម សុន្ទរ:
៣. លោក រ៉ង្ស សារ៉ុធ
៤. លោក ទាវ សារ:មុនី
៥. លោក សុខ សុធន
លេខានិពន្ធ
១. លោក ជុំ សម្ប្ផត្ថិ
២. លោក ម៉ាក់ ឈិន
អ្នកបកប្រែភាសា
១. លោកស្រី ម៉ែន នារីសោភ័ត
អ្នកថតរូប
១. លោក សុផាត រ:មុនី
វិចិត្រករ
១. លោក ធា សារ៉ុធ

អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
Address :
No 203 Preah
Norodom Bld.
Phnom Penh Cambodia
Tel : 023 219 065

ទស្សនាវដ្ដី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី១០ លេខ ១៩០ ខែមីនា ឆ្នាំ ២០១៧

អគារសិក្សាថ្មីនៃវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន ក្រុងក្រចេះ

(សម្ពោធថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧)

ចែកជូនបោសសព្វគិតថ្ងៃ